ព្រឹត្តិបត្រ

# មេធាវី

# BULLETIN METHEAVY

ច្បាប់ចេញប្រចាំត្រីមាសខែ កក្កដា-កញ្ញា ឆ្នាំ២០១៧ លេខ១៤

# យុត្តិធម៌ JUSTICE

# និង AND

# ច្បាប់ LAW

ការផ្សាយរបស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

អាសយដ្ឋានអគារកាច់ជ្រុងផ្លូវលេខ ១១២៩ កែងផ្លូវ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៥៥-២៣) ៦២២ ៧០៧០   អ៊ីម៉ែល : info@bakc.org.kh   គេហទំព័រ : www.bakc.org.kh

លេខ ១៤
ព្រឹត្តិបត្រ មេធាវី BULLETIN METHEAVY
ច្បាប់ចេញប្រចាំត្រីមាសខែ កក្កដា-កញ្ញា ឆ្នាំ២០១៧

# ព្រឹត្តិបត្រមេធាវី

លេខ ១៤

ខែ កក្កដា-កញ្ញា ឆ្នាំ ២០១៧

រក្សាសិទ្ធិ © 2017 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនមែនបានសេចក្តីថាឆ្លុះបញ្ចាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទេ។

ស្របតាមគោលការណ៍សេរីភាពនៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

ទំព័រ

# មាតិកា


សារពីប្រធានគណៈមេធាវី ........ v

## ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

**គោលការណ៍នៃភាពប្រាកដប្រជានៃច្បាប់ និងផលវិបាកពាក់ព័ន្ធ** ........ 1

១. សេចក្តីផ្តើម ........ 1

២. គោលការណ៍ និងទ្រឹស្តីពាក់ព័ន្ធ ........ 1

៣. សន្និដ្ឋាន និងអនុសាសន៍ ........ 9

**មូលហេតុនៃបណ្តឹងសាទុក្ខ ក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា(តចប់)** ........ 13

១. អសមត្ថកិច្ចនៃតុលាការ ........ 13

២. ការរំលោភអំណាច ........ 14

៣.ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់ ........ 15

៤. ការបំពាន ឬភ្លេចទម្រង់ការដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ ........ 16

៥. ការមិនបានសម្រេចលើពាក្យសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្តឹងសុំនេះ ធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់ ........ 17

៦. ការបំភ្លែអង្គហេតុ ........ 17

៧.ការគ្មានសំអាងហេតុ ........ 18

៨. ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច ........ 19

៩. សេចក្តីសន្និដ្ឋាន ........ 20

## ផ្នែកពាណិជ្ជកម្ម

**ភតិសន្យាហិរញ្ញវត្ថុ** ........ 23

១. សេចក្តីផ្តើម ........ 23

២. ភតិសន្យាប្រតិបត្តិការ ........ 23

៣. ភតិសន្យាហិរញ្ញវត្ថុ ....................................................................................24

**កិច្ចព្រមព្រៀងមជ្ឈត្តការ** ....................................................................................27

១.ប្រភពនៃមជ្ឈត្តការ ....................................................................................27

២.ធាតុផ្សំនៃការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការ ....................................................................................29

៣. យុត្តាធិការ(សមត្ថកិច្ច)នៃមជ្ឈត្តការ ....................................................................................31

៣.១ យុត្តាធិការកំណត់ដោយកិច្ចព្រមព្រៀង ....................................................................................31

៣.២ យុត្តាធិការដែលកំណត់ដោយច្បាប់ ....................................................................................34

៣.៣ ការកំណត់យុត្តាធិការនៃមជ្ឈត្តការ ....................................................................................37

៤.ច្បាប់គ្រប់គ្រងជម្លោះ ....................................................................................38

៥. វិធានគ្រប់គ្រងនីតិវិធីមជ្ឈត្តការ ....................................................................................38

៦. អាសនៈនៃមជ្ឈត្តការ ....................................................................................39

៧. ភាសា ....................................................................................40

៨. ការតែងតាំងមជ្ឈត្តករ ....................................................................................40

**ចំណុចវិវាទដែលអាចសម្រេចសេចក្តីបានដោយ វេទិកាមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា** ....................................................................................41

១.សេចក្តីផ្តើម ....................................................................................41

២. សញ្ញាណទូទៅ នៃពាក្យ "ពាណិជ្ជកម្ម" ....................................................................................41

៣. សញ្ញាណមិនមែន "ពាណិជ្ជកម្ម" ....................................................................................44

៤. ការឆ្លុះបញ្ចាំងបទពិសោធន៍កម្ពុជា ជាមួយ ប្រទេសសឹង្ហបូរី (Singapore) និង អាហ្សង់ទីន (Argentina) ....................................................................................45

៥. សេចក្តីសន្និដ្ឋាន ....................................................................................48

**សិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ**

**យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ** ....................................................................................53

១. សេចក្តីផ្តើម ....................................................................................53

២. ក្រុមប្រឹក្សាសិទ្ធិមនុស្ស ..... 54

៣. ស្ថាប័នសន្ធិសញ្ញា ..... 66

៣.១. អនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ..... 66

៣.២ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ..... 67

៣.៣ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ..... 67

៣.៤ អនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ .. 68

៣.៥ អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ..... 68

៣.៦ អនុសញ្ញាស្តីពី សិទ្ធិកុមារ ..... 69

៣.៧ អនុសញ្ញាស្តីពី ការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូបនិងសមាជិកគ្រួសាររបស់ពួកគេ ..... 70

៣.៨ អនុសញ្ញាស្តីពី សិទ្ធិជនពិការ ..... 70

៣.៩ អនុសញ្ញាស្តីពី ការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ ..... 70

## សកម្មភាពរបស់គណៈមេធាវី

១. ទំនាក់ទំនងជាតិ និងអន្តរជាតិ ..... 77

១.១ ទំនាក់ទំនងជាតិ ..... 77

១.២ ទំនាក់ទំនងអន្តរជាតិ ..... 84

២. សិក្ខាសាលា ..... 88

៣. សេចក្តីជូនដំណឹងអំពីបណ្ណាល័យច្បាប់នៃគណៈមេធាវី ..... 89

# សារពីប្រធានគណៈមេធាវី




គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសាជាថ្មីសូមបោះផ្សាយបន្តនូវព្រឹត្តិបត្រមេធាវី លេខ ១៤ សម្រាប់ត្រីមាសខែកក្កដា-កញ្ញា ឆ្នាំ២០១៧ ។ ព្រឹត្តិបត្រមេធាវីនេះ បានសម្រេចឡើងដោយការប្រឹងប្រែងលះបង់ពេលវេលាដ៏មានតម្លៃរបស់អ្នកនិពន្ធនីមួយៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់ អ្នកនិពន្ធដែលបានរួមចំណែកវិភាគទានអត្ថបទរបស់ខ្លួន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរង ប្រធាន និងបុគ្គលិកនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ នៃគណៈមេធាវីដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានានៃច្បាប់ដូចជា យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី និងច្បាប់ពាណិជ្ជកម្មជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពីសកម្មភាព នៃគណៈមេធាវី ដើម្បីឲ្យសហភាតាជាមេធាវីបានជ្រាបពីកិច្ចដំណើរការនៃគណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី២ "ពង្រឹង និងការពារវិជ្ជាជីវៈ"** នៃ***ផែនការសកម្មភាពនៃគណៈមេធាវី*** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងប្រទេសកម្ពុជាយើង មានអ្នកជំនាញខាងច្បាប់ជាច្រើនដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើសេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់មេធាវី

និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។ គណៈមេធាវីស្វាគមន៍ជានិច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមអ៊ីម៉ែល info@bakc.org.kh ឬតាមរយៈលោកមេធាវី **កុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោក **កែ ប៊ុនធឿន** តាមអ៊ីម៉ែល bunthoeurn@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!



**សួន វិសាល**

ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

# ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

# គោលការណ៍ នៃភាពប្រាកដប្រជានៃច្បាប់ និងផលវិបាក ពាក់ព័ន្ធ

ដោយមេធាវី **មាស ប៊ូរ៉ា***

## ១. សេចក្តីផ្តើម

គោលការណ៍នៃភាពប្រាកដប្រជានៃច្បាប់ (គ.ប.ច) (Legal Certainty) ជាគោលការណ៍សំខាន់មួយដែលគួរលើកយកមកពិភាក្សាដើម្បីស្វែងយល់ជាពិសេសនូវខ្លឹមសារ និងភាពជាប់ពាក់ព័ន្ធជាមួយនឹងទ្រឹស្តីដទៃទៀត ក្នុងវិស័យបកស្រាយច្បាប់ ឬគោលការណ៍ច្បាប់។ គ.ប.ច. ពាក់ព័ន្ធទាំងទ្រឹស្តី និងការអនុវត្ត។ ផ្អែកលើមូលដ្ឋាននេះ អត្ថបទនេះត្រូវបានសរសេរឡើងដោយផ្តោតលើទ្រឹស្តី ក្នុងគោលបំណងបង្ហាញពីខ្លឹមសារនៃគោលការណ៍ និងចំណងទាក់ទងដែលមាន។ អត្ថបទស្រាវជ្រាវនេះ មានបីផ្នែកជាសំខាន់ដែលរាប់បញ្ចូលទាំងផ្នែកនេះ ខ្លឹមសារដែលបរិយាយអំពីគោលការណ៍ព្រមទាំងទ្រឹស្តីដែលពាក់ព័ន្ធ និងចុងបញ្ចប់ជាខ្លឹមសារសង្ខេបដែលមានអនុសាសន៍ សម្រាប់ធានាតាមផ្លូវច្បាប់នូវគោលការណ៍នេះ។

## ២. គោលការណ៍ និងទ្រឹស្តីពាក់ព័ន្ធ

គ.ប.ច សំដៅថា ខ្លឹមសារច្បាប់ត្រូវមានភាពច្បាស់លាស់ដែលប្រធាននៃច្បាប់ (subject of law) អាចដឹងពីខ្លឹមសារនៃច្បាប់ តាមរយៈការអាន ឬ ឮនូវទង្វើណាដែលច្បាប់ហាមឃាត់ ឬមិនហាមឃាត់ ដើម្បីងាយស្រួលដល់បុគ្គលណាម្នាក់ត្រូវធ្វើ ឬមិនត្រូវធ្វើនូវអំពើណាមួយ។ ប្រសិនបើ បុគ្គលធ្វើតាមឆន្ទៈតាមទង្វើអ្វីដែលច្បាប់ហាមឃាត់ដែលមានទោស ហើយនៅតែធ្វើតាមឆន្ទៈនូវទង្វើខុសនោះ គាត់នឹងប្រឈមនឹងការទទួលខុសត្រូវ និងទទួលទោសតាមច្បាប់។

* លោកមេធាវី **មាស ប៊ូរ៉ា** បានបញ្ចប់បរិញ្ញាបត្រច្បាប់នៅមហាវិទ្យាល័យច្បាប់ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចភ្នំពេញ ឆ្នាំ១៩៩៨។ ឆ្នាំ២០០៧ លោកទទួលបានបណ្ឌិតច្បាប់ ជំនាញច្បាប់អន្តរជាតិ ពីសាកលវិទ្យាល័យ ណាហ្គូយ៉ា ប្រទេសជប៉ុន។

ក្រៅពីការបង្រៀនច្បាប់សិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ លោកជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា (CUS) ទទួលបន្ទុកកិច្ចការងារស្រាវជ្រាវ និងជាប្រធានក្រុមអ្នកច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។

លោកមេធាវីបានសិក្សាស្រាវជ្រាវ និងសរសេរអត្ថបទជាច្រើន ពាក់ព័ន្ធនឹងច្បាប់ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ សិទ្ធិមនុស្ស ច្បាប់អន្តរជាតិទូទៅ និងបត្យាប័ន។

ជាទូទៅ វាមិនមានច្បាប់ច្រើនចែងអំពី គ.ប.ច ទេ តែមានច្បាប់ចែងអំពី គោលការណ៍នីត្យានុកូល។[1] គ.ប.ច នេះត្រូវប្រើនៅក្នុងសេចក្តីសម្រេច និងសាលក្រមរបស់តុលាការជាតិ[2] ឬអន្តរជាតិ។[3] គោលការណ៍នេះ ប្រើសម្រាប់គ្រប់វិស័យច្បាប់ទាំងអស់ ផ្ទុយពីគោលការណ៍នីត្យានុកូលដែលអនុវត្តជាចម្បងក្នុងវិស័យព្រហ្មទណ្ឌ។[4]

ដើម្បីដឹងថាអ្វីមួយត្រូវហាមឃាត់ ហើយដឹងតាមវិធីណា (Accessibility) និងដឹងទង្វើដែលបុគ្គលធ្វើក្នុងថ្ងៃនេះនាពេលនេះមិនខុសច្បាប់ និងមិនត្រូវទទួលការកាត់ទោសនាពេលខាងមុខ (Foreseeability) ដែលតាមរយៈនេះ ច្បាប់នាពេលមុខមិនអនុវត្តថយក្រោយចំពោះអំពើមិនខុសមុនវត្តមាននៃច្បាប់ (Retroactive Application of Law) ធាតុផ្សំនៃ គ.ប.ច មានចំណុចជាន់គ្នានឹងគោលការណ៍នីត្យានុកូលភាព (the Principle of Legality)[5] ដែលមានប្រភពចេញពីប្រទេសស៊ីវិលឡ (Civil Law)។[6] គោលការណ៍នីត្យានុកូលជាឧទាហរណ៍ចែងថា៖ *១. គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធភាពពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើ ឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ។ ដូចគ្នានេះមិនត្រូវដាក់ទោសឲ្យធ្ងន់ជាងទោសដែលបានអនុវត្តក្នុងខណៈពេលប្រព្រឹត្តបទល្មើសឡើយ។ ប្រសិនបើ ក្រោយពីការប្រព្រឹត្តបទល្មើសហើយ ច្បាប់បានបញ្ញត្តិឲ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលអត្ថប្រយោជន៍ពីការដាក់ទោសស្រាលជាងនេះ។ ២. គ្មានបញ្ញត្តិណាមួយក្នុងមាត្រានេះ ប្រឆាំងនឹងការជំនុំជម្រះក្តី ឬការផ្តន្ទាទោស*

[1] កតិកាសញ្ញាស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ ឆ្នាំ ១៩៧៧, មាត្រា ១៥។ ច្បាប់ស្តីពី អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្នាំ២០០៤, មាត្រា ២៣ ថ្មី។ ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣, មាត្រា ៣៨។ Bas Van Bockel, គោលការណ៍ the *ni bis in idem* ក្នុងច្បាប់សហគមន៍អ៊ឺរ៉ុប, European Monographs, ឆ្នាំ ២០១០, ទំ.២៣០។

[2] Conjoined cases C-187/01 and C-385/01, *Huseyin Gözütok and Klaus Brügge,* [2003] ECR I-5689 at para 40.

[3] អង្គបុរេជំនុំជម្រះ អវតក, សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចស្តីពី ភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ..., D11/3/4/2, ១៣ ខែកុម្ភៈ ឆ្នាំ ២០១៣, កថាខ័ណ្ឌ ១៧។ Ion PREDESCU and Marieta SAFTA, the Principle of Legal Certainty, Basis for the Rule of Law, Landmark Case-Law, *https://www.ccr.ro/ccrold/publications/buletin/8/predescuen.pdf,*

[4] ICCPR, *supra* note 1, Art. 15.

[5] Kenneth S. Gallant, the Principle of Legality in International and Comparative Criminal Law, 2008; Gabriel Hallevy, A Modern Treatise on the Principle of Legality in Criminal Law, 2010.

[6] ស៊ីវិលឡ នាទីនេះ មិនមែនសំដៅដល់ ច្បាប់គ្រប់គ្រងទំនាក់ទំនងបុគ្គល ដូចជាច្បាប់ឯកជន (ច្បាប់អាពាហ៍ពិពាហ៍ទេ)។ ស៊ីវិលឡ គឺសំដៅដល់ប្រព័ន្ធ ដែលមានកំណើតចេញមកពី រ៉ូម៉ង់ ហើយដែលសព្វថ្ងៃច្រើននិយាយ ដល់ប្រព័ន្ធច្បាប់បារាំង។ ក្នុងពិភពលោក ប្រទេសភាគច្រើនប្រកាន់តាមប្រព័ន្ធស៊ីវិលឡ (យ៉ាងតិច១២៩ ប្រទេស), see Ruth A. Kok, Statutory Limitations in International Criminal Law, 2007, p. 34.។

*ដល់ជនណាម្នាក់ ចំពោះអំពើជាបទល្មើសព្រហ្មទណ្ឌ ស្របតាមគោលការណ៍ទូទៅនៃច្បាប់ ដែលទទួលស្គាល់ដោយសហគមន៍នៃប្រជាជាតិ។*[7] គ.ប.ច ក៏មានទំនាក់ទំនងនឹងគោលការណ៍នៃការហាមឃាត់ការកាត់សេចក្ដីពីរដងផងដែរ។[8] ក្នុងន័យនេះ អ្នកស្រាវជ្រាវ និងយុត្តិសាស្ត្របានស្នើឲ្យប្រើពាក្យ «ការហាមឃាត់ការកាត់សេចក្ដីពីរដងក្នុងអង្គហេតុដូចគ្នា» ជំនួសឲ្យ «ការហាមឃាត់ការកាត់សេចក្ដីពីរដងលើបទល្មើសតែមួយ» ដោយសារបទល្មើសជាច្រើនអាចត្រូវបានចាត់ចេញពីអង្គហេតុតែមួយតាមច្បាប់ប្រទេសនីមួយៗ។[9] អាស្រ័យហេតុនេះ បុគ្គលអាចជួបនឹងភាពមិនប្រាកដប្រជា ដោយសារមិនដឹងថា ខ្លួននឹងទទួលរងនូវការកាត់សេចក្ដីប៉ុន្មានដង។

> «គោលការណ៍ (ហាមឃាត់ការកាត់សេចក្ដីពីរដង *ne bis in idem*) ស្ថិតនៅលើសរសរស្តម្ភពីរនៃប្រព័ន្ធច្បាប់នីមួយៗ។ មួយ គឺគោលការណ៍នៃភាពប្រាកដប្រជា និងទីពីរគឺសមធម៌ (Equity)។ នៅពេលជនល្មើសត្រូវបានកាត់សេចក្ដី និងផ្ដន្ទាទោស គាត់ត្រូវដឹងថា តាមការអនុវត្តទោសពិរុទ្ធភាពនឹងរលាយ (expiated) ហើយនឹងមិនចាំបាច់ភ័យខ្លាចនូវទោសថ្មីណាមួយទេ។ ប្រសិនបើ គាត់ត្រូវបានដោះលែង គាត់មានភាពប្រាកដប្រជាថា គាត់នឹងមិនត្រូវបានកាត់សេចក្ដីជាថ្មីក្នុងដំណើរការផ្សេងណាមួយទេ»។[10]

## ភាពអាចប្រមើលឃើញនៃច្បាប់ (Foreseeability)

គ.ប.ច មានវិសាលភាពទូលាយ។ ច្បាប់មិនបានចែងច្បាស់លាស់អំពីកត្តាយកមកពិចារណាសម្រាប់ការដាក់ទោស ក៏ប៉ះនឹងគោលការណ៍នេះផងដែរ។[11] វាទាមទារឲ្យអ្នកធ្វើច្បាប់កំណត់និយមន័យ និងទោសឲ្យបានជាក់លាក់ ដើម្បីជៀសបាននូវការប្រើប្រាស់ដោយបំពាន ធានាថាច្បាប់មិនត្រូវអនុវត្តប្រតិសកម្ម ហើយការផ្ទេរអំណាចធ្វើច្បាប់ដល់នីតិប្រតិបត្តិ

---

[7] កតិកាសញ្ញាស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ, មាត្រា ១៥។ ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣, មាត្រា ៣៨។

[8] Scottish Law Commission, Discussion Paper No 141 on Double Jeopardy, 2009, p. 14; Bas Van Bockel, *supra* note 1, 6.10.3.

[9] Bas Van Bockel, *supra* note 1, 6.10.3.

[10] Conjoined cases C-187/01 and C-385/01, *Huseyin Gözütok and Klaus Brügge,* [2003] ECR I-5689, para. 40។ ស្រដៀងគ្នានេះ អាចឃើញមានក្នុងមាត្រា ២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៩ របស់កម្ពុជា។ មាត្រា ៨ នៃក្រមព្រហ្មទណ្ឌគំរូបានចែងថា៖ បុគ្គលម្នាក់មិនអាចត្រូវបានកាត់ទោសចំពោះបទល្មើសព្រហ្មទណ្ឌ ដែលគាត់ត្រូវបានកាត់ទោស ឬឲ្យរួចទោសរួចហើយ លុះត្រា៖ ក. ក្នុងគោលបំណងនៃការបិទបាំងបុគ្គលដែលពាក់ព័ន្ធ ពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬមិនត្រូវបានធ្វើឡើងដោយឯករាជ្យ និងមិនលំអៀង អនុលោមតាមវិធានត្រឹមត្រូវទទួលស្គាល់ដោយ ច្បាប់អន្តរជាតិ និងប្រព្រឹត្តក្នុងលក្ខណៈដែលក្រោមស្ថានភាពមិនស្របតាមចេតនាក្នុងការនាំបុគ្គលពាក់ព័ន្ធឲ្យទទួលខុសត្រូវ។ សូមមើល Vivienne O'Connor, Model Codes for Post-Conflict Criminal Justice, 2007.

[11] Silvia D'Ascoli, Sentencing in International Criminal Law: the UN ad hoc Tribunals and Future Perspectives for the ICC, 2011,p. 42.

ត្រូវមានតិចតួចបំផុតតាមតែអាចធ្វើបាន។[12] ក្នុងន័យនេះហើយ រដ្ឋាភិបាលមិនអាចធ្វើឯកសារដាក់ទោសទណ្ឌធ្ងន់ធ្ងរដល់ជនណាមួយ លើកលែងបទលហុ ឬបទល្មើសដែលទទួលពិន័យអន្តរការណ៍។ លិខិតគតិយុត្តរបស់រដ្ឋាភិបាលអាចត្រឹមត្រូវនិយាយយោងដល់បទល្មើស និងទោសទណ្ឌដែលមានក្នុងច្បាប់ជាធរមានតែប៉ុណ្ណោះ។ ខ្លឹមសារដកស្រង់នេះ បង្ហាញនូវការអះអាងដែលទើបបង្ហាញជូន។ *ក្នុងករណីចាំបាច់បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។*[13]*...ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ ៥០០.០០០ រៀល ទៅ ៥.០០០.០០០ រៀល ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឲ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសមួយដូចខាងក្រោម៖ ១. មិនរុះរើ និងដកចេញពីទីតាំងនេសាទក្នុងឡូត៍នេសាទ តាមកាលកំណត់ក្នុងច្បាប់នេះ។...ជនណាប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រានេះចាប់ពីពីរដងឡើងទៅត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដង នៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ។*[14] ការធ្វើហួសពីសមត្ថកិច្ចនេះ វាមិនគ្រាន់តែប៉ះពាល់ដល់គោលការណ៍នេះទេ វាក៏នឹងប៉ះនូវគោលការណ៍នៃការបែងចែកអំណាចផងដែរ។

គ.ប.ច តម្រូវឲ្យមានច្បាប់ដែលអនុម័តដោយសភាដែលមានភាពលម្អិត[15] ហើយខ្លឹមសារនៃបទប្បញ្ញត្តិត្រូវមានភាពជាក់លាក់[16] ស៊ីសង្វាក់ និងងាយយល់ដែលសាធារណជនអាចដឹងថា មានច្បាប់ដែលហាមឃាត់អំពើតាមមធ្យោបាយ ឬយន្តការផ្សេងៗ ដូចជាការផ្សព្វផ្សាយច្បាប់។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានប្រើប្រាស់ពាក្យ «គុណភាពនៃច្បាប់»។[17]បន្ថែមពីលើនេះ តុលាការនេះបានអះអាងថា៖ *ច្បាប់ត្រូវតែអាចទទួលបានគ្រប់គ្រាន់៖ ប្រជាពលរដ្ឋត្រូវតែអាចមានការចង្អុលបង្ហាញថា វាគ្រប់គ្រាន់ក្នុងកាលៈទេសៈដែលវិធានច្បាប់អនុវត្តចំពោះករណីណាមួយ... វិធានណាមួយនឹងមិនអាចចាត់ថាជាច្បាប់ទេ លុះត្រាវាត្រូវបានរៀបចំឡើងក្នុងភាពជាក់លាក់គ្រប់គ្រាន់ ដើម្បីជួយឲ្យប្រជាពលរដ្ឋ កែសម្រួលអំពើរបស់ពួកគេ៖ ប្រសិនបើ ត្រូវការការប្រឹក្សា*

[12] Robert J. Reinstein, *the Limits of Executive Power*, 59 (2) American University Law Review, 336 (2009).

[13] ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩,កម្ពុជា, មាត្រា ១១

[14] ច្បាប់ស្តីពី ជលផល ឆ្នាំ ២០០៦ របស់កម្ពុជា, មាត្រា ៩៧។

[15] Taha Ayhan, *the Principle of Legal Certainty in EU Case Law*, 4 (3) *Today's Review of Public Administration*, 2010, p. 12.

[16] *Sunday Times v. the United Kingdom of Great Britain and Northern Ireland*, 1979, para. 49.

[17] *Malone v. United Kingdom*, (1985) 7 EHRR 14, para.67.

*យោបល់សមស្រប ប្រជាពលរដ្ឋត្រូវតែអាចមើលឃើញក្នុងកម្រិតសមហេតុផលក្នុងកាលៈទេសៈដែលផលវិបាកដែលទង្វើណាមួយអាចមាន។*[18]

មាត្រា ២៤ នៃច្បាប់របស់ប្រទេស រ៉ូម៉ានី ចែងថា ច្បាប់ត្រូវតែសរសេរឡើង ដោយប្រើប្រាស់ភាសាច្បាប់ជាក់លាក់ក្នុងទម្រង់ដែលបានចែង ដើម្បីបំបាត់នូវភាពមន្ទិល។[19] តុលាការសិទ្ធិមនុស្សរបស់ទ្វីបអឺរ៉ុបក៏បាន អះអាងផងដែរថា៖ *«វិធានមិនអាចត្រូវបានចាត់ថាជាច្បាប់ទេ លុះត្រាតែ វាត្រូវបានបង្កើតឡើងជាមួយភាពជាក់លាក់គ្រប់គ្រាន់ ជួយឲ្យប្រជាពលរដ្ឋកែតម្រង់ទង្វើរបស់ពួកគេ»*។[20] វិធានដែលអាចព្យាករណ៍ (Foreseeable) បាន នៅពេលដែលវាបានផ្តល់នូវការការពារគ្រប់គ្រាន់ទល់នឹងការជ្រៀតជ្រែកដោយបំពារបំពានដោយ អាជ្ញាធរសាធារណៈ។ ជាប្រយោល គ.ប.ច ហាមនូវការកែប្រែច្បាប់តាមតែទំនើងចិត្តដោយ គ្មានហេតុផលសមស្រប។[21] ប្រសិនបើ មានការលើកលែង ការកម្រិត ការកែប្រែ ដោយមិនចាំបាច់ វាមិនគួរដាក់ក្នុងច្បាប់ទេ...។[22] ទោះបីជាយ៉ាងនេះក្តី គេមិនត្រូវរំពឹងថា ច្បាប់ត្រូវតែមានភាពច្បាស់លាស់ដាច់ខាតទេ។ អ្នកធ្វើច្បាប់មិនអាចទាយទុកជាមុន នូវគ្រប់ស្ថានភាពដែលច្បាប់នឹងអនុវត្តបានទេ។[23] ការមិនទាមទារនូវជាក់លាក់ដាច់ខាតនេះ ដើម្បីកុំឲ្យរឹងកំព្រឹស (rigidity) ពិបាកបត់បែនពេក។[24]

មាត្រានិរាករណ៍ក៏ត្រូវមានភាពជាក់លាក់ ដើម្បីឲ្យដឹងថាច្បាប់ណាមួយ ឬមាត្រាណាមួយត្រូវបាននិរាករណ៍ ឬលែងមានសុពលភាពរួចហើយ។[25] ក្នុងន័យនេះ មាត្រាដែលចែងទូលាយ៖ *បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍*[26] ទំនងជា

---

[18] *Silver v. United Kingdom* (1983) 5 EHRR 347, paras. 87-88, …the law must be adequately accessible: the citizen must be able to have an indication that it is adequate, in the circumstances, of the legal rules applicable in a given case…a norm can not be regarded as a 'law' unless it is formulated with sufficient precision to enable the citizen to regulate his conduct: he must be able-if need be with appropriate advice-to foresee, to a degree that is reasonable in the circumstances, the consequences which a given action my entail, quoted in Richard Gordon and Tim Ward, Judicial Review and the Human Rights Act, 2000, p. 65.

[19] Ion PREDESCU and Marieta SAFTA, *supra* note 3, p. 11.

[20] *Sunday Times v. the United Kingdom of Great Britain and Northern Ireland*, *supra* note 16, para. 49.

[21] Ion PREDESCU and Marieta SAFTA, *supra note* 3, p.9.

[22] Ion PREDESCU and Marieta SAFTA, *supra note* 3, p. 18.

[23] Gabriel Hallevy, *supra* note 5, p. 140.

[24] Ion PREDESCU and Marieta SAFTA, *supra note* 3, p. 12.

[25] Venice Commission of the Council of Europe, the Rule of Law Checklist, 2016, p. 27.

[26] ច្បាប់ស្តីពី ជលផល ឆ្នាំ ២០០៦ របស់កម្ពុជា, មាត្រា ១០៨។

មិនត្រឹមត្រូវទេ បើអនុលោមទៅតាម គ.ប.ច។ អ្វីដែលនឹងប្រសើរជាងនេះ អាចចែងថា៖ *បទប្បញ្ញត្តិដូចតទៅនេះ ត្រូវទុកជានិរាករណ៍៖ -រាល់បទប្បញ្ញត្តិស្តីពី នីតិវិធីព្រហ្មទណ្ឌមុនឆ្នាំ ១៩៩២... បទប្បញ្ញត្តិស្តីពី នីតិវិធីនៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ពុំអាចអនុវត្តចំពោះរឿងព្រហ្មទណ្ឌបានឡើយ។*[27]

ដោយសារមានករណីមិនច្បាស់លាស់នេះហើយ ទើបទាមទារឲ្យមានការបកស្រាយច្បាប់ដោយតុលាការ ព្រមទាំងមានការសន្មតថា តុលាការត្រូវតែប្រើប្រាស់ច្បាប់ ឬបកស្រាយច្បាប់ ដោយមិនអាចនិយាយថា គ្មានច្បាប់ចែង ដូចនេះគាត់បដិសេធបណ្តឹងដោយងាយៗនោះទេ។ តួនាទីសម្រេចសេចក្តីត្រូវបានជូនដល់តុលាការ ដើម្បីដកចេញនូវភាពមន្ទិលក្នុងច្បាប់ដែលកើតមានតាមរយៈការបកស្រាយវិធាន។[28] ករណីដែលចៅក្រមបដិសេធការពិចារណាដោយលេសថា ច្បាប់មិនចែង ឬចែងមិនច្បាស់អាចត្រូវបានចោទពីបទបដិសេធយុត្តិធម៌ (denial of justice)។[29] ចៅក្រមបកស្រាយច្បាប់ តែមិនបង្កើតច្បាប់ជំនួសសភាទេ។[30] ប្រសិនបើវិធានច្បាប់ព្រហ្មទណ្ឌត្រូវបានចែងមិនច្បាស់ ហើយការបកស្រាយនាំឲ្យមានការបកស្រាយដែលផ្តល់ប្រយោជន៍ដល់បុគ្គលនឹងត្រូវចោទប្រកាន់។[31]

បន្ថែមពីលើភាពប្រាកដប្រជានៃបទបញ្ញត្តិនៃច្បាប់ ទាំង គ.ប.ច និងគោលការណ៍នីត្យានុកូលទាមទារឲ្យមានការបកស្រាយច្បាប់ដោយតឹងរឹង ជាពិសេសក្នុងវិស័យព្រហ្មទណ្ឌ។ *ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ។*[32] ក្រៅពីនេះ វាពាក់ព័ន្ធការដាក់កម្រិតលើសិទ្ធិសេរីភាពបុគ្គល ក្នុងរឿងព្រហ្មទណ្ឌ តាមរយៈការចាប់ខ្លួន ឬឃុំខ្លួនបណ្តោះអាសន្ន ការបកស្រាយច្បាប់ដោយតុលាការ ឬអាជ្ញាធរ ម្តងយ៉ាងនេះ ម្តងយ៉ាងនោះ ដោយសារមិនបានដឹងខ្លឹមសារច្បាប់ ឬដោយសារខ្វះនូវលិខិតគតិយុត្តណែនាំពីការបកស្រាយច្បាប់ នឹងនាំឲ្យបុគ្គលពិបាកដឹងអំពីការប្រែប្រួលនូវខ្លឹមសារច្បាប់។ នេះអាចមកពីចៅក្រមបកស្រាយហួសពីវិសាលភាពនៃច្បាប់ ឬហួសពីចេតនារបស់អ្នកធ្វើច្បាប់ នាំទៅដល់ការបង្កើតបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវថ្មីដែលបុគ្គលមិនអាចព្យាករណ៍ជាមុនបាន។ ក្នុងទង្វើរបស់តុលាការអាចបង្កើតជាបទល្មើសថ្មីដែលជាសមត្ថកិច្ចរបស់សភាអាចប៉ះនឹងគោលការណ៍ នៃការបែងចែកអំណាច។ ចៅក្រម

[27] ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ កម្ពុជា មាត្រា ៦១១ ស្តីពី និរាករណ៍នៃអត្ថច្បាប់ស្តីពី នីតិវិធីពីមុន។

[28] Ion PREDESCU and Marieta SAFTA, *supra note* 3, p. 12.

[29] Ion PREDESCU and Marieta SAFTA, *supra note* 3, p. 15.

[30] Ion PREDESCU and Marieta SAFTA, *supra note* 3, p. 16.

[31] Gabriel Hallevy, *supra* note 5, p. 138។ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣, កម្ពុជា, មាត្រា ៣៨។

[32] ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ កម្ពុជា, មាត្រា ៥។

តុលាការកំពូលមានកាតព្វកិច្ចធានានូវការបកស្រាយច្បាប់ ប្រកបដោយស៊ីសង្វាក់គ្នា(Unitary)។[33] នេះអាចនឹងកាន់តែធ្ងន់ធ្ងរសម្រាប់ចៅក្រមប្រទេសស៊ីវិលឡូ ដែលមានការហាមឃាត់ការបស្រាយតាមសទិសភាព។[34] ការទាមទារឲ្យបង្កើតច្បាប់មានវិធានជាក់លាក់ គឺជាតម្រូវការចាំបាច់ដើម្បីឲ្យបុគ្គលដឹងអំពីច្បាប់ដែលនឹងនាំឲ្យមានប្រសិទ្ធផលនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ។[35]

ក្នុងកម្រិតអនុវត្ត ជាពិសេស ដោយតុលាការ វាទាមទារការបកស្រាយតុលាការមានភាពស៊ីង្វាក់គ្នាឲ្យបានជាអតិបរមាលើខ្លឹមសារនៃមាត្រាដដែល អនុវត្តក្នុងអង្គហេតុដោយឡែកៗ។ គោលការណ៍នេះក៏អនុវត្តផងដែរ ចំពោះសេចក្តីសម្រេចរបស់អាជ្ញាធរដែលទាមទារឲ្យការសម្រេចមានភាពស៊ីសង្វាក់គ្នាដើម្បីងាយស្រួលដល់បុគ្គល ដឹងថាការធ្វើទង្វើនេះនឹងមិនផ្ទុយសេចក្តីសម្រេចកន្លងមកចេញដោយអាជ្ញាធរ (legitimate expectation) ហើយខ្លួនខ្លាចនឹងមានការដាក់ទោសទណ្ឌ។[36]

ការអនុវត្តប្រទេសខ្លះ៖ ពាក់ព័ន្ធនឹងការត្រួតពិនិត្យដោយតុលាការជាន់ខ្ពស់ (Judicial Review) តុលាការបានប្រកាន់ថា ច្បាប់មិនច្បាស់នាំឲ្យមានអសុពលភាព (*Void for vagueness*)[37]។ តុលាការធម្មនុញ្ញរបស់ រ៉ូម៉ានី ទាក់ទងនឹងការពិចារណាច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការស៊ីវិលបានបដិសេធមោឃភាពដោយបានអះអាងថា៖ ច្បាប់ស្ថិតនៅក្រោមដែលជាកម្មវត្ថុនៃការពិនិត្យនេះ ..ការធ្វើសេចក្តីព្រាងមិនបានល្អ មិនបានត្រឹមត្រូវតាមលក្ខខណ្ឌនៃបច្ចេកទេស ក្នុងការធ្វើច្បាប់ជាក់លាក់សម្រាប់វិធានច្បាប់។[38]

គោលការណ៍នៃភាពប្រាកដប្រជានេះ នឹងមិនមានបញ្ហាច្រើនសម្រាប់ប្រព័ន្ធស៊ីវិលឡូទេ ប្រសិនបើច្បាប់មានភាពលម្អិត និងជាក់លាក់។ ផ្ទុយទៅវិញប្រសិនបើ ច្បាប់មិនជាក់លាក់ និងលម្អិត ហើយសាលក្រមមិនត្រូវបានផ្សព្វផ្សាយខុសពីប្រទេសកុំមិនឡូ (Common Law) ដែលច្បាប់មួយចំនួនមិនមែនជាច្បាប់សរសេរ (Unwritten Law) បង្កើតឡើងដោយចៅក្រម

[33] Ion PREDESCU and Marieta SAFTA, *supra note* 3, p. 17.

[34] ច្បាប់ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ កម្ពុជា, មាត្រា ៥។

[35] Gabriel Hallevy, *supra* note 5, p. 139.

[36] Ion PREDESCU and Marieta SAFTA*, supra note* 3, p.9.

[37] Robert Batey, *Vagueness and the Construction of Criminal Statutes-Balancing Acts*, 5 Va. J. Soc. Pol΄ y & L. 1(1997); Ernst Freund, *the Use of Indefinite Terms in Statutes*, 30 Yale L. J. 437 (1921).

[38] Ion PREDESCU and Marieta SAFTA, *supra* note 3, p.11.

(Judge Made Law)[39] សាធារណៈជនពិតជាពិបាកដឹងនូវខ្លឹមសារនៃច្បាប់ ហើយនេះនឹងមិនបំពេញនូវសមាសធាតុនៃការប្រមើលទុកជាមុន (Forese-eability) នៃ គ.ប.ច ឡើយ។

## ការទទួលបានច្បាប់ (Accessibility)

ការផ្សព្វផ្សាយដោយវិធីណាក៏ដោយ ពិតជាចាំបាច់ដើម្បីឆ្លើយតបទៅនឹងការអះអាងថា មិនបានដឹងច្បាប់ដែលតែងតែលើកឡើងជាការដោះសារដោយអ្នកដែលត្រូវបានចោទថាបានរំលោភច្បាប់។[40] គ.ប.ច ក៏អាចពាក់ព័ន្ធ ពេលណាដែលច្បាប់ត្រូវចូលជាធរមាន ពីព្រោះថា ប្រជាពលរដ្ឋគួរត្រូវបានទុកពេលដើម្បីអាចដឹងអំពីវត្តមាន និងខ្លឹមសារច្បាប់ ហើយអាជ្ញាធរក៏ត្រូវតែមានពេលគ្រប់គ្រាន់ក្នុងការដឹង ដើម្បីជួយធានាកុំឲ្យសេចក្តីសម្រេចដែលនឹងត្រូវធ្វើមិនផ្ទុយនឹងច្បាប់។ ក្នុងន័យនេះ ការប្រកាសច្បាប់ជាការប្រញាប់ លើកលែងច្បាប់ដាក់ប្រទេសក្នុងភាពអាសន្នអាចមិនមានមូលដ្ឋានរឹងមាំទេ ក្នុងក្របខ័ណ្ឌនៃភាពជាក់លាក់។ និយាយជាសាមញ្ញមិនមែនច្បាប់ទាំងអស់គួរតែត្រូវបានដាក់ឲ្យអនុវត្តជាលក្ខណៈប្រញាប់ទេ ដោយសារ វាតម្រូវឲ្យមានពេលវេលាសម្រាប់សាធារណៈជនបានដឹងឮអំពីខ្លឹមសារនៃច្បាប់ តាមរយៈការបណ្តុះបណ្តាលច្បាប់ដោយអាជ្ញាធរមានសមត្ថកិច្ច។ មាត្រា ១៣០៥ នៃក្រមរដ្ឋប្បវេណីរបស់កម្ពុជា ដោយប្រយោល ទុកពេលវេលាសម្រាប់គោលដៅនេះ៖ *ក្រមនេះត្រូវអនុវត្តចាប់តាំងពីថ្ងៃដែលកំណត់ដោយច្បាប់ផ្សេង។* ខ្លឹមសារកាន់តែច្បាស់ជាងនេះគឺ៖ *ក្រោយពេលចូលជាធរមាននៅទូទាំងប្រទេស ច្បាប់នេះត្រូវផ្សព្វផ្សាយក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ ទើបត្រូវអនុវត្ត។*[41]

ពាក់ព័ន្ធការទទួលបានព័ត៌មានស្តីពីច្បាប់ វាមានការពិបាកសូម្បីសម្រាប់រដ្ឋដឹងអំពីច្បាប់អន្តរជាតិដែលយន្តការនៃការផ្សព្វផ្សាយមិនមានភាពជាក់លាក់ និងទូលំទូលាយ។ ដូចនេះ

---

[39] Because abstract of unwritten law, common law seems to follow Civil law approach, the common law and civil law traditions, see *https://www.law.berkeley.edu/library/robbins/pdf/CommonLawCivilLawTraditions.pdf* p. 4 (accessed on 14 July 2017)។សម្រាប់ករណី ចុងក្រោយនេះ ដើម្បីឲ្យដឹងថា តើយុត្តិសាស្ត្រណាមួយ ត្រូវបានលុបរួច ហើយ (Precedent), except strong reason, as well settled jurisprudence in Civil Law makes law; that is why we have common law crime and statutory crime, common law, Statutory law, and administrative law, *www.swlearning.com/pdfs/chapter/0324016581_3.PDF,* p. 8 (accessed on 15 July 2017).

[40] Wikipedia, *Ignorantia juris non excusat* (ignorance of the law is no excuse), https://en.wikipedia.org/wiki/Ignorantia_juris_non_excusat (accessed on 17 July); S.S. Peloubet, Collection of Legal Maxim in the law and Equity with English Translations, 1880, p. 99.

[41] ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១, កម្ពុជា, មាត្រា ៨៤។

បុគ្គលពិតជាមិនអាចដឹងច្បាស់ពីច្បាប់អន្តរជាតិទេ។ បញ្ហាកើតមានកាន់តែខ្លាំង ប្រសិនបើនិយាយយោងដល់ការដឹងឮអំពីវត្តមាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ច្បាប់មិនក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ)។ ទោះបីជាយ៉ាងនេះក្តី ក្នុងប្រទេសខ្លះពាក់ព័ន្ធជាមួយនឹងសង្គ្រាម មានច្បាប់ក្នុងស្រុកដែលនិយាយអំពីវិធីសាស្រ្ត វិន័យ ឬវិធាននៃការធ្វើសង្គ្រាម ដែលគេអាចនិយាយថា ទាហាន ឬ មេបញ្ជាការ អាចដឹងអំពីអ្វីដែលត្រូវ ឬខុសនឹងច្បាប់ទាហាន ដែលអាចនាំឲ្យមានការទទួលខុសត្រូវក្រោមច្បាប់មនុស្សធម៌អន្តរជាតិ។ បន្ថែមពីនេះ គេអាចអះអាងថាសម័យនេះ ប្រព័ន្ធផ្តល់ព័ត៌មាន ដូចជា Internet ទូលំទូលាយ ដែលបុគ្គលអាចដឹងអំពីច្បាប់អន្តរជាតិ។ ទោះបីជាយ៉ាងនេះ ក៏មិនមានអ្នកដឹងយ៉ាងច្រើនទេ ហើយក៏មិនអាចដឹងច្បាប់អន្តរ-ជាតិស្ទើរគ្រប់ទាំងអស់ផងដែរទេ។ អ្នកស្រាវជ្រាវ ឬចៅក្រមបានទាញសន្និដ្ឋាន ដោយប្រយោលថាទោះបីបុគ្គលមិនបានដឹងច្បាប់អន្តរជាតិ ក៏ប៉ុន្តែទង្វើណាមួយ នោះត្រូវបានចែងដោយច្បាប់ជាតិ (ឧទាហរណ៍ ការសម្លាប់មនុស្ស) ដូចនេះបុគ្គលអាចដឹងថា ទង្វើសម្លាប់ជនស៊ីវិលដែលមិនចូលរួមផ្ទាល់ក្នុងជម្លោះប្រដាប់អាវុធត្រូវទទួលខុសត្រូវ ពីព្រោះការសម្លាប់មានដូចគ្នា ហើយមិនអាចដោះសារថា មិនបានដឹងថាច្បាប់មនុស្សធម៌អន្តរជាតិបានចែងហាមអំពើទាំងនោះទេ។[42]

## ៣. សន្និដ្ឋាន និងអនុសាសន៍

គ.ប.ច ត្រូវបានឃើញ ឬនិយាយទូទៅក្នុងសេចក្តីសម្រេចរបស់តុលាការ។ គោលការណ៍នេះមានទំនាក់ទំនងគ្នាជាមួយនឹងទ្រឹស្តី ឬគោលការណ៍ជាច្រើន ដូចជា ការហាមឃាត់ការកាត់សេចក្តីពីរដង និងគោលការណ៍នីត្យានុកូលជាដើម។ គោលការណ៍នេះពាក់ព័ន្ធជាមួយនឹងទ្រឹស្តី ការអនុវត្ត និងខ្លឹមនៃយន្តការអនុវត្តច្បាប់ ការធ្វើច្បាប់ដើម្បីធានាឲ្យច្បាប់ច្បាស់លាស់ និងការអនុវត្តច្បាប់ឲ្យមានសង្គតភាព។ ជាសរុប វាទាមទារឲ្យច្បាប់មានគុណភាពជួយធានានូវស្ថេរភាព និងប្រសិទ្ធផលនៃច្បាប់។ នេះទាមទារនូវវិធីសាស្រ្តអនុម័តច្បាប់សមស្រប។[43] ជាលម្អិតវាពាក់ព័ន្ធនឹងសកម្មភាពនៃការពន្យល់ពាក្យពេចន៍ ការធ្វើវិសោធនកម្មច្បាប់ ការចែងពីនិរាករណ៍នៃច្បាប់ ការរៀបចំច្បាប់ឲ្យមានលក្ខណៈជាប្រព័ន្ធស្រួលរកបាន។ ជាក់លាក់ជាងនេះ នៅក្នុងកម្រិតនៃការអនុវត្ត វាទាមទារឲ្យមានប្រព័ន្ធនៃការបកស្រាយច្បាប់ឯកភាពមួយ។[44]

អ្នកនិពន្ធយល់ថា គោលការណ៍នេះ ជាពាក្យខ្លី ងាយស្រួលនិយាយ ក៏ប៉ុន្តែមិនងាយនឹងអនុវត្តទេ។ ទោះបីជាយ៉ាងនេះក្តី ភាគីពាក់ព័ន្ធត្រូវតែខិតខំ រៀបចំយន្តការ កែសម្រួលដើម្បីឲ្យប្រព័ន្ធច្បាប់បានល្អប្រសើរ ជាបណ្តើរៗ។ ប្រសិនបើ មិនដូចនេះទេ ៥ ឬ១០ឆ្នាំក្រោយអាច

[42] *R v. Imre Finta*, Canada Supreme Court, 24 March 1994, Cory J, para. 215.

[43] Ion PREDESCU and Marieta SAFTA, *supra note* 3, p.2.

[44] Ion PREDESCU and Marieta SAFTA, *supra* note 3, p.4.

នឹងមិនមានអ្វីប្រែប្រួល ហើយនឹងពិបាកប្រកួតប្រជែង ឬដើរឲ្យទាន់ភាពរីកចម្រើននៃវិស័យច្បាប់ក្នុងពិភពលោក។ ដើម្បីជួយជាគំនិត អត្ថបទនឹងបង្ហាញជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

១. វិធានគ្រប់គ្រង និងនីតិវិធីនៃការរៀបចំច្បាប់៖ មុននឹងសម្រេចរៀបចំច្បាប់ណាមួយ ទាមទារឲ្យមានការសិក្សាលម្អិតនៃផលវិបាក ផលចំណេញ និងខាតការអាចអនុវត្តបាន ព្រមទាំង ការសិក្សាប្រៀបធៀបជាមួយច្បាប់មុនៗ ដើម្បីបញ្ចៀសកុំឲ្យមានទំនាស់រវាងលិខិតគតិយុត្ត។

២. អ្នកចូលរួមរៀបចំច្បាប់ យ៉ាងហោចណាស់មានសមត្ថភាព ឬចំណេះដឹងច្បាប់ជាមូលដ្ឋាន និងដឹងអំពីវិធីសាស្ត្រធ្វើច្បាប់។

៣. កិច្ចប្រជុំពិភាក្សាច្បាប់នីមួយៗ ត្រូវបានកំណត់ត្រាឲ្យបានលម្អិតជាក់លាក់ និងចងក្រង[45] នូវខ្លឹមសារវិវត្ត ពាក្យពេចន៍ និងបទប្បញ្ញត្តិ ឬចេតនារបស់អ្នកធ្វើច្បាប់ សម្រាប់ជួយក្នុងការបកស្រាយច្បាប់ នៅពេលមានខ្លឹមសារមិនច្បាស់។ ជាក់ស្តែងមាត្រា ៣១ នៃច្បាប់រដ្ឋ-ធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ប្រើពាក្យ «ប្រជាពលរដ្ឋខ្មែរ» ដែលធ្វើឲ្យអ្នកបកស្រាយខ្លះថា មានចរិតរើសអើងលើជនបរទេស។ ក្រោយពីពិនិត្យមើល កំណត់ត្រានៃការតាក់តែងច្បាប់ធម្មនុញ្ញ អ្នកស្រាវជ្រាវបានរកឃើញថា ពាក្យនេះមានន័យទូលាយ ដោយរាប់បញ្ចូលទាំងការធានាសិទ្ធិដល់ជនបរទេសផងដែរ។

៤. វាក៏ទាមទារផងដែរ នូវការចូលរួមទូលំទូលាយពី ភាគីពាក់ព័ន្ធរួមទាំង អ្នកសិក្សាស្រាវជ្រាវច្បាប់។

៥. វាទាមទារឲ្យមានវិធានគ្រប់គ្រង ចង្អុលបង្ហាញនូវនីតិវិធីធ្វើច្បាប់។ ខ្លឹមសារច្បាប់ចុងក្រោយមុននឹងអនុម័តសម្រេច ត្រូវជាក់លាក់ លម្អិត និងមានសន្ទានុក្រមនៃពាក្យ ប្រសិនបើចាំបាច់។ ចុងបញ្ចប់ បទប្បញ្ញត្តិស្តីពី និរាករណ៍ ត្រូវតែមានភាពជាក់លាក់ ចង្អុលបង្ហាញច្បាប់អ្វីបទប្បញ្ញត្តិណាដែលនឹងត្រូវបាននិរាករណ៍។

៦. គោលការណ៍នៃភាពប្រាកដប្រជា ទាមទារឲ្យខ្លឹមសារច្បាប់ជាមូលដ្ឋានបានដឹងដល់សាធារណជន អាស្រ័យហេតុនេះ វាទាមទារឲ្យមានការផ្សព្វផ្សាយច្បាប់។ វាជាការផ្សព្វផ្សាយច្បាប់ ដោយស្ថាប័នមួយជាក់លាក់បន្តជារហូតគ្រប់ច្បាប់ចម្បងទាំងអស់ ដល់គ្រប់ស្រទាប់សាធារណជន។ អ្នកបណ្តុះបណ្តាលត្រូវមានជំនាញ មានឯកសារបណ្តុះបណ្តាលសមស្របគ្រប់គ្រាន់សម្រាប់ចែកជូន និងធ្វើឡើងក្នុងពេលវេលាសមស្រប មុនពេលច្បាប់ដាក់ឲ្យអនុវត្ត។ ពាក់ព័ន្ធនឹងចំណុចនេះ ការប្រកាសច្បាប់ជាការប្រញាប់គួរជៀសវៀង ប្រសិនបើអាចធ្វើបាន។

[45] Kai Hauerstein, ed., Introduction to Legislative Drafting: References and Techniques, 2016, p. 63.

៧. ច្បាប់មានហើយ ប្រជាជនដឹងច្បាប់ហើយ ក៏ប៉ុន្តែតួនាទីរបស់តុលាការ នៅតែសំខាន់ជៀសមិនរួចក្នុងការបកស្រាយច្បាប់ ជួយស្រាយបំភ្លឺខ្លឹមសារច្បាប់។ ទោះបីជាយ៉ាងណាក្តី បើការបកស្រាយនាំឲ្យមានភាពកាន់តែមិនច្បាស់លាស់ វានឹងនាំឲ្យសាធារណជនកាន់តែច្រឡំខ្លឹមសារ។ អាស្រ័យហេតុនេះគួរតែមានវិធាន ឬច្បាប់សម្រាប់ណែនាំការបកស្រាយច្បាប់។ នៅពេលច្បាប់មានចន្លោះប្រហោងដែលទាមទារឲ្យសភាធ្វើច្បាប់ តុលាការត្រូវជូនដំណឹងដល់សភា ហើយសភាត្រូវធ្វើច្បាប់បន្ថែមឲ្យបានឆាប់។

៨. ការចូលរួមពីស្ថាប័នស្រាវជ្រាវ ពិតជាមានសារប្រយោជន៍។ អាស្រ័យហេតុនេះ សាលក្រម គួរត្រូវបានបោះពុម្ពផ្សាយ ដើម្បីឲ្យអ្នកស្រាវជ្រាវទទួលបាន យកមកវិភាគ ផ្តល់ជាអនុសាសន៍ល្អៗ ក្នុងន័យស្ថាបនា។

៩. ជាចុងក្រោយ ការបណ្តុះបណ្តាលច្បាប់ នៅតាមសាកលវិទ្យាល័យ ឬជាពិសេសសាលាបណ្តុះបណ្តាលមេធាវី ចៅក្រម និងព្រះរាជអាជ្ញា ត្រូវផ្តល់ការបណ្តុះបណ្តាលពួកគេឲ្យបានស៊ីជម្រៅ ជាពិសេសលើទ្រឹស្តី ហេតុផលច្បាប់ វិធីសាស្រ្តគតិតយុត្តិ ការបកស្រាយច្បាប់ជាជាងផ្តោតលើការអនុវត្ត។ ឯកសារច្បាប់ ត្រូវបានផ្តល់គ្រប់គ្រាន់ដល់ ចៅក្រម និងព្រះរាជអាជ្ញា។ ភាពប៉ិនប្រសព្វ និងពូកែរបស់ផ្នែកណាមួយនឹងជំរុញឲ្យយន្តការទាំងមូលប្រព្រឹត្តដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

# មូលហេតុនៃ បណ្ដឹងសាទុក្ខ ក្នុងនីតិវិធីព្រហ្មទណ្ឌកម្ពុជា
## ( តចប់ )

ដោយមេធាវី **សូ មូស្សេទ្នី**[*]

## ១. អសមត្ថកិច្ចនៃតុលាការ

សមត្ថកិច្ចតុលាការព្រហ្មទណ្ឌតុលាការសំដៅលើ សមត្ថកិច្ចដែនដី[46] និងសមត្ថកិច្ចសម្ភារៈ (រួមមាន ចំណាត់ថ្នាក់បទល្មើស[47] ដូចជា បទល្មើសឧក្រិដ្ឋ ឬមជ្ឈិម និងប្រភេទនៃបទល្មើស ដូចជាបទល្មើសសាមញ្ញ ឬយោធា[48])។ សេចក្ដីសម្រេចដែលចេញដោយ តុលាការដែលមិនមាន សមត្ថកិច្ចដូចខាងលើ អាចនឹងត្រូវបដិសេធចោលដោយតុលាការកំពូល ដោយមូលហេតុអសមត្ថកិច្ច នៃតុលាការ[49]។

កាលណាតុលាការជាន់ក្រោម ទទួលចាត់ការរឿងក្ដីក្រៅពីសមត្ថកិច្ចរបស់ខ្លួន ដូចជា តុលាការយោធាកាត់សេចក្ដីបទល្មើសសាមញ្ញ ធ្វើឲ្យតុលាការកំពូលបដិសេធចោលសេចក្ដីសម្រេច របស់តុលាការនេះដោយ មូលហេតុអសមត្ថកិច្ចនៃតុលាការ[50]។ ម្យ៉ាងទៀត ច្បាប់កំណត់អំពី

---

[*] លោក សូ មូស្សេទ្នី បច្ចុប្បន្នគឺជាសហមេធាវីការពារក្ដីជាតិក្នុងសំណុំរឿង០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយក៏ជាស្ថាបនិក និងជាមេធាវីនៅការិយាល័យមេធាវី អេសភីខ្មែរឡេហ្គាល ដែលមានអាសយដ្ឋានផ្ទះលេខ ១៥អា ផ្លូវលេខ៣២០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

[46] សូមមើលមាត្រា ២៩០ និង២៨៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។ សូមមើលផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១២៣ អំពីសមត្ថកិច្ចស៊ើបសួរតាមដែនដីរបស់ចៅក្រមស៊ើបសួរ, មាត្រា ៣៩ អំពីសមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញា និងមាត្រា ២៩០ អំពីសមត្ថកិច្ចតាមដែនដីរបស់សាលាដំបូង។

[47] សូមមើលមាត្រា២៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌ។ សូមមើលផងដែរ សមត្ថកិច្ចស៊ើបសួរតាមករណីឧក្រិដ្ឋ និងមជ្ឈឹម មាត្រា ១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ។

[48] សូមមើល មាត្រា ៨៩ ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៤ ("ច្បាប់ចាត់តាំងតុលាការ ឆ្នាំ២០១៤") ។ មាត្រានេះកំណត់ថាច្បាប់ពីមុនច្បាប់ទាក់ទងនឹងតុលាការយោធា និងអយ្យការអមតុលាការយោធា និងបញ្ញត្តិនីតិវិធី និងសមត្ថកិច្ចនៃរឿងក្ដីបទល្មើសយោធា នៅបន្តមានអានុភាពក្រោយច្បាប់នេះចូលជាធរមាន។ ពាក់ព័ន្ធនឹងតុលាការយោធា និងបទល្មើសយោធា សូមមើលផងដែរ មាត្រា ១១ នៃច្បាប់ស្ដីពី ប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩២ (ដែលគេស្គាល់ផងដែរថា ជា"ច្បាប់អ៊ុនតាក់") និង មាត្រា ២ និងមាត្រា ៩ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា ចុះថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ("ច្បាប់ចាត់តាំងតុលាការរដ្ឋកម្ពុជា១៩៩៣")។

[49] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ២។

[50] *ដូចយោងខាងលើ*។ សម្រាប់បទល្មើសអ្វីដែលកំណត់បានជាបទល្មើសយោធា សូមមើលមាត្រា ២ នៃច្បាប់អ៊ុនតាក់ និងមាត្រា ៩ នៃច្បាប់ចាត់តាំងតុលាការរដ្ឋកម្ពុជា១៩៩៣។

សមត្ថកិច្ចរបស់តុលាការខេត្តក្រុង ទៅតាមដែនដីដែលតុលាការនោះតាំងនៅ[51]។ លើសពីនេះ ច្បាប់កំណត់ថា កាលណាបទល្មើសដែលបានប្រព្រឹត្តឡើងចូលជាបទល្មើសឧក្រិដ្ឋ ព្រះរាជ-អាជ្ញាមិនអាចបញ្ជូនរឿងទៅជំនុំជម្រះដោយមិនបានឆ្លងកាត់ ចៅក្រមស៊ើបសួរបានឡើយ[52]។ តុលាការដែលទទួលបណ្តឹងឱ្យជំនុំជម្រះផ្ទាល់ ឬតាមនីតិវិធីនៃការបង្ហាញមុខភ្លាម កាលណារឿងនោះជាបទឧក្រិដ្ឋត្រូវបង្វិលរឿងទៅឱ្យព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ[53]។ បើសិនជាតុលាការធ្វើផ្សេងពីនេះ បន្តចាត់ការជំនុំជម្រះលើបណ្តឹងរបស់ព្រះរាជអាជ្ញាបញ្ជូនជនជាប់ចោទទៅជំនុំជម្រះលើករណីបទឧក្រិដ្ឋ ដោយមិនបានឆ្លងកាត់តាមការស៊ើបសួរ ករណីនេះតុលាការកំពូលនឹងច្រានចោលដោយមូលហេតុអសមត្ថកិច្ច[54]។

## ២. ការរំលោភអំណាច

តុលាការកំពូលអាចបដិសេធសាលដីកាសាលាឧទ្ធរណ៍ ដែលសម្រេចដោយរំលោភអំណាច[55]។ ការរំលោភអំណាចកើតមានឡើង ពេលដែលតុលាការអនុវត្តអំណាចរបស់ខ្លួនលើសពីច្បាប់បានកំណត់ឱ្យ។ ឧទាហរណ៍៖ នៅក្នុងករណីរឿងនៅមុនអង្គសេចក្តីដែលពាក់ព័ន្ធនឹងការសម្រេចឃុំខ្លួន ឬនៅក្រៅឃុំ តុលាការទទួលបណ្តឹងឧបាស្រ័យពីការសម្រេចនេះមិនអាចសម្រេចប៉ះពាល់ទៅលើអង្គសេចក្តីបានឡើយ ដូចជាការសន្និដ្ឋានថា បទល្មើសចោទប្រកាន់ពុំមានភស្តុតាងគ្រប់គ្រាន់ជាអាទិ៍ ព្រោះតុលាការជាន់ក្រោមពុំទាន់សម្រេចដល់អង្គសេចក្តី ហើយការសម្រេចផ្ទុយពីនេះជាការរំលោភអំណាច។ ជាក់ស្តែង តុលាការកំពូលបានបដិសេធសាលដីកាសាលាឧទ្ធរណ៍ ដោយសារមូលហេតុរំលោភអំណាច ដោយហេតុថា "ការដែលសាលាឧទ្ធរណ៍សម្រេចបដិសេធដីកាលេខ...របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាប ហើយសម្រេចឱ្យជនជាប់ចោទឈ្មោះ...នៅក្រៅឃុំបណ្តោះអាសន្នដោយសំអាងហេតុថា ពុំមានភស្តុតាងដាក់បន្ទុកគ្រាន់គ្រាន់ក្នុងបទឧក្រិដ្ឋ ដូចការចោទប្រកាន់ ហើយអាចមានអំពើបៀតបៀនកេរ្តិ៍ខ្មាស់ ដែលជាបទមជ្ឈិមប៉ុណ្ណោះ នេះគឺជាការខុសឆ្គងមួយដ៏ធ្ងន់ធ្ងរ ពីព្រោះសាលាឧទ្ធរណ៍បានរំលោភអំណាច

[51] សូមមើលមាត្រា ១២ នៃច្បាប់ចាត់តាំងតុលាការ ២០១៤ ។ សូមមើលផងដែរ មាត្រា ៣៥ នៃច្បាប់នេះ ដែលកំណត់ពីសមត្ថកិច្ចសាលាឧទ្ធរណ៍តំបន់។ សូមមើលផងដែរ មាត្រា ២៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[52] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៨៤។ ក្រមនេះកំណត់ថា ក្រៅពីបទល្មើសឧក្រិដ្ឋ ព្រះរាជអាជ្ញាអាចមានជម្រើស ដោយបើកការស៊ើបសួរ ឬ បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅមុខតុលាការជាន់ដំបូង តាមមាត្រា៤៦ ឬបង្គាប់ឲ្យនាំជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង តាមមាត្រា៤៧ និង៤៨។ សូមមើលផងដែរ មាត្រា ៣០៤។

[53] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៨ និង មាត្រា ៣០៤។

[54] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ២។

[55] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ៣។

នៅលើអង្គសេចក្តីដែលស្ថិតនៅក្នុងសមត្ថកិច្ចតុលាការខេត្តសៀមរាបនៅឡើយ"[56]។ ហើយម្យ៉ាងវិញទៀត តុលាការកំពូលយល់ឃើញថា "ជនជាប់ចោទឈ្មោះ... ត្រូវចោទពីបទល្មើសជាច្រើនរួមមានទាំងបទមជ្ឈិម និងបទឧក្រិដ្ឋ គឺបទល្មើសដែលមានចែងក្នុងមាត្រា៧ និងមាត្រា៨ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើពង្រត់ និងលក់ដូចមនុស្ស និងធ្វើអាជីវកម្មលើមនុស្ស និងមាត្រា៣៣ និង៤២នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល[57]ព្រមទាំងមាត្រា៩៨ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ប៉ុន្តែចៅក្រមស៊ើបអង្កេតតុលាការខេត្តសៀមរាបមិនទាន់បញ្ចប់ការស៊ើបអង្កេតផង បែរជាសាលាឧទ្ធរណ៍យល់ថា ពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទទៅវិញ"[58]។

ដូច្នេះការសម្រេចសេចក្តីដោយរំលោភអំណាចដែលច្បាប់ប្រគល់ឱ្យ គឺមូលហេតុដែលនាំតុលាការកំពូលបដិសេធសេចក្តីសម្រេចតុលាការថ្នាក់ក្រោម។

## ៣.ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់

សេចក្តីសម្រេចតុលាការជាន់ក្រោមអាចត្រូវបានច្រានចោល ដោយតុលាការកំពូល ដោយសារសេចក្តីសម្រេចទាំងនោះធ្វើឡើងដោយបំពានច្បាប់ ឬអនុវត្តខុសច្បាប់[59]។ ការបំពានច្បាប់ ឬអនុវត្តខុសច្បាប់មានជាអាទិ៍ នៅពេលដែលសាលាឧទ្ធរណ៍ចេញសេចក្តីសម្រេចបង្គាប់ឱ្យមានការអនុវត្តភ្លាមៗនូវខ្លឹមសារនៃសេចក្តីសម្រេចរបស់ខ្លួន ទោះបីជាច្បាប់មានចែងផ្សេងពីនេះថា ការប្តឹងសាទុក្ខមានអានុភាពផ្អាកការអនុវត្តសាលដីកាសាលាឧទ្ធរណ៍ក៏ដោយ។ ជាឧទាហរណ៍ តុលាការកំពូលបានយល់ឃើញថា "ការបង្គាប់ឲ្យដោះលែងជនជាប់ចោទឈ្មោះ... ជាបន្ទាន់ចេញពីមន្ទីឃុំឃាំងដែលស្ថិតក្នុងរយៈពេលប្តឹងសាទុក្ខ គឺរំលោភលើមាត្រា២១៧ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ[60] ដោយមាត្រានេះចែងច្បាស់ថាបណ្តឹងសាទុក្ខ និងរយៈពេលសម្រាប់ប្តឹងសាទុក្ខមានអានុភាពផ្អាកការអនុវត្តសាលដីកាសាលាឧទ្ធរណ៍ រហូតដល់ចេញសាលដីកាតុលាការកំពូល ប៉ុន្តែដោយកំហុសនេះជាកំហុសអង្គច្បាប់សុទ្ធសាធ។ ដូច្នេះតុលាការកំពូលទុកជាមោឃៈ ដោយឥតបង្វិលនូវចំណុចទី៤នេះ[61]"។ ម្យ៉ាងវិញទៀត ជាការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់ នៅពេលដែលច្បាប់ចែងឲ្យការដោះលែងជនជាប់ចោទនៅក្រៅឃុំបណ្តោះអាសន្ន នៅក្នុងលក្ខខណ្ឌ

---

[56] សូមមើល សាលដីកាតុលាការកំពូលលេខ ០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៣ សំណុំរឿងព្រហ្មទណ្ឌលេខ ១៥ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៣ ទំព័រ ៨ ("សាលដីកាលេខ ០៩, ២៦.០៣.០៣")។

[57] ច្បាប់នេះគឺសំដៅលើច្បាប់អ៊ុនតាក់ដែលបានយោងខាងមុខ។

[58] ដូចយោងខាងលើ។

[59] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ៤។

[60] ច្បាប់នេះគឺសំដៅលើច្បាប់នីតិវិធីព្រហ្មទណ្ឌ (រដ្ឋកម្ពុជា) ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣ ("ច្បាប់នីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា១៩៩៣")។

[61] សូមមើល សាលដីកាលេខ ០៩, ២៦.០៣.០៣ ទំព័រ ៨។

ដូចជា ជនជាប់ចោទមានការងារធ្វើ មានគ្រួសារ មានទីលំនៅពិតប្រាកដជាអាទិ៍។ ជាឧទាហរណ៍ តុលាការកំពូលបានយល់ឃើញថា ខណៈដែល "ជនជាប់ចោទ ពុំមានទីលំនៅអចិន្ត្រៃយ៍ និងពិតប្រាកដលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទេ ហើយក៏ពុំមានទ្រព្យសម្បត្តិ ឬប្រាក់កាសសម្រាប់ធានាសំណងដល់ជនរងគ្រោះដើម្បីសុំនៅក្រៅឃុំដែរ ជាក់ស្តែងពេលដែលសាលាឧទ្ធរណ៍សម្រេចឱ្យជននេះនៅក្រៅឃុំ ជននេះបានគេចខ្លួន និងពុំបានមកចូលរួមសវនាការនេះទេ។ ដូច្នេះការដែលសាលាឧទ្ធរណ៍សម្រេចឱ្យជនជាប់ចោទឈ្មោះ...នៅក្រៅឃុំបណ្តោះអាសន្ន គឺជាការរំលោភលើលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល[62] ព្រមទាំងពុំបានសម្រេចឱ្យជនជាប់ចោទដាក់ប្រាក់ធានាដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី មានការទុកចិត្តនៅពេលដែលតុលាការសម្រេចសេចក្តីជាស្ថាពរដែរ[63]"។

## ៤. ការបំពាន ឬភ្លេចទម្រង់ការដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ[64]

កាលណាសេចក្តីរបស់តុលាការជាន់ក្រោមធ្វើឡើងដោយបំពាន ឬភ្លេចទម្រង់ការដែលច្បាប់បញ្ញត្តិថា ត្រូវទុកជាមោឃៈ[65] តុលាការអាចនឹងបដិសេធចោលសេចក្តីសម្រេចទាំងនោះ[66]។ ករណីមួយចំនួនច្បាប់កំណត់ថាមោឃៈភាព វិសមិតភាពរវាងមុខងារបណ្តឹងអាជ្ញា មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះ[67]ជាអាទិ៍ ដូចជា ចៅក្រមដែលទទួលស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌមួយមិនអាចទទួលជំនុំជម្រះក្នុងរឿងដដែលនេះបានទេ។ ហេតុដូច្នេះ សេចក្តីសម្រេចទាំងឡាយរបស់តុលាការជាន់ក្រោមដែលធ្វើឡើង ដោយចៅក្រមដែលមានវិសមិតភាពធ្វើឲ្យសេចក្តីសម្រេចនោះអាចត្រូវបដិសេធចោលដោយតុលាការកំពូល ដោយមូលហេតុបែបនេះ។

---

62 ច្បាប់នេះគឺសំដៅលើច្បាប់អ៊ុនតាក់ដែលបានយោងខាងមុខ។

63 សូមមើល សាលដីកាលេខ ០៩, ២៦.០៣.០៣ ទំព័រ ៨។

64 សូមមើលមាត្រា ៧៨ ច្បាប់ចាត់តាំងតុលាការ ២០១៤។

65 សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣០៤, មាត្រា ៣៤២ ជាអាទិ៍។ គួរកត់សម្គាល់ផងដែរថា ក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ថា ដីកាដំណោះស្រាយលុបលាងមោឃៈភាពនៃកិច្ចនីតិវិធីក្នុងអំឡុងពេលស៊ើបសួរ រារាំងការលើកឡើងអំពីមោឃៈភាពនៅចំពោះមុខតុលាការជំនុំជម្រះ ប៉ុន្តែមិនមានចែងថា កិច្ចនីតិវិធីធ្វើឡើង នៅមុនកិច្ចស៊ើបសួរ អាចត្រូវបានលុបលាងដោយដីកាដំណោះស្រាយដែរឬអត់។ សូមមើលផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៥៦ និងមាត្រា ២៥២។

66 សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ៥។

67 សូមមើល ច្បាប់ចាត់តាំងតុលាការ២០១៤ មាត្រា ៧៤ ។ សូមមើលផងដែរមាត្រា ៧៤ ដល់ ៧៨ នៃច្បាប់ដដែល។ សូមមើលផងដែរ មាត្រា ៥៥៥ ដល់៥៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សូមមើលមាត្រា ៥៤, មាត្រា ៥៥, មាត្រា ២៨៨, មាត្រា ៣៧៤ ។

## ៥. ការមិនបានសម្រេចលើពាក្យសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្តឹងសុំនេះ ធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់[68]

សេចក្តីសម្រេចរបស់តុលាការជាន់ក្រោមដែលមិនបានពិចារណា និងសម្រេចលើការស្នើសុំរបស់ភាគី ខណៈដែលការស្នើសុំបានធ្វើជាលាយលក្ខណ៍អក្សរ[69] និងមានន័យច្បាស់លាស់ ធ្វើឲ្យតុលាការកំពូលអាចសម្រេចបដិសេធសេចក្តីសម្រេចបែបនេះ របស់តុលាការជាន់ក្រោមបានដែរ។

ជាក់ស្តែង តុលាការកំពូលបានច្រានចោលសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដោយហេតុថា "កាលពីនៅសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ...បានស្នើសុំដល់មហាអយ្យការអមសាលាឧទ្ធរណ៍ឲ្យធ្វើការសាកសួរសាក្សីរបស់ខ្លួនចំនួន៣រូប តាមលិខិតចុះថ្ងៃទី....ហើយក៏ដូចជានៅពេលសវនាការជាន់សាលាឧទ្ធរណ៍កាលពីថ្ងៃទី...ដែរ គឺជនជាប់ចោទនៅតែសំណូមពរដដែល តែសាលាឧទ្ធរណ៍ពុំបានលើកយកទៅពិចារណា និងសម្រេចឡើយ ចំណុចនេះបានបំពានលើមាត្រា២០៩[70] ចំណុចទី៣ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ១៩៩៣ ហើយ"[71]។

## ៦. ការបំភ្លៃអង្គហេតុ[72]

តុលាការកំពូលអាចច្រានចោលសេចក្តីសម្រេចរបស់តុលាការជាន់ក្រោម ដោយមូលហេតុការបំភ្លៃអង្គហេតុ។ អង្គហេតុ[73]គឺជាធាតុមួយសំខាន់ដើម្បីកំណត់អំពីអង្គច្បាប់ ដូចជាធាតុផ្សំ

---

[68] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ៦។

[69] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៥៧។

[70] ច្បាប់នីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា១៩៩៣ ។ ចំណុចទី៣ នៃមាត្រា២០៩ នេះ គឺមានខ្លឹមសារប្រហាក់ប្រហែលនឹងមាត្រា ៤១៩ចំណុច៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែរ។ មាត្រា ២០៩ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌរដ្ឋកម្ពុជា១៩៩៣ នេះចែងថា៖ ករណីដែលបើកឲ្យតុលាការកំពូលសម្រេចបដិសេធនោះគឺ៖ ១. សមាសភាពនៃសាលាជំរះក្តីមិនត្រឹមត្រូវតាមច្បាប់ ដោយគ្មានចំនួនចៅក្រមគ្រប់គ្រាន់ក្តី ដោយមានហេតុដទៃទៀតក្តីដែលកើតចេញពីការមិនគោរពបញ្ញត្តិច្បាប់។ ២. ការបំពាន ឬការខ្វះចន្លោះមិនបានបំពេញនូវទម្រង់ច្បាប់ដែលច្បាប់ចាត់ទុកជាមោឃៈ ដូចជា សវនាការមិនបានធ្វើជាសាធារណៈ។ *៣. ការប្រកែក ឬការខ្វះខាតមិនបានសម្រេចលើពាក្យសុំ ឬសេចក្តីសន្និដ្ឋានមួយ ឬច្រើនរបស់ភាគីណាមួយ រួមមានអយ្យការផង ដែលប្រើសិទ្ធិ ឬសេរីភាពរបស់ខ្លួនត្រឹមត្រូវតាមច្បាប់ ឬដែលច្បាប់ប្រគល់ឲ្យ*។ ៤. អសមត្ថកិច្ច។ ៥. ការគ្មានសំអាងហេតុ ឬភាពផ្ទុយរវាងសំអាងហេតុ និងសេចក្តីសម្រេច។ ៦. ការបំពាន ឬការអនុវត្តខុសច្បាប់នៃអង្គសេចក្តី។ ៧. ការបំពានអត្ថន័យនៃអង្គហេតុ។ ៨. ការរំលោភអំណាច។ (គូសបញ្ជាក់បន្ថែម)។

[71] សូមមើល សាលដីកាតុលាការកំពូលលេខ ១៩ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ សំណុំរឿងព្រហ្មទណ្ឌលេខ ១៩ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៤ ទំព័រ ៧ ។

[72] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ៧។

នៃបទល្មើសជាអាទិ៍។ ការប្រែប្រួលនៃអង្គហេតុធ្វើឲ្យមានការសន្និដ្ឋានលើអង្គច្បាប់ផ្សេងដែរ ដូចជា ពីមានបទល្មើសទៅជាគ្មានបទល្មើស។

ជាឧទាហរណ៍ តុលាការកំពូលបានបដិសេធសាលដីកាសាលាឧទ្ធរណ៍ ដោយឈរលើមូលដ្ឋាននៃការបំភ្លៃអង្គហេតុ ព្រោះថា "ការដែលសាលាឧទ្ធរណ៍ សម្រេចលើកលែងចោទប្រកាន់លើជនជាប់ចោទឈ្មោះ....ដោយសំអាងថា ជនជាប់ចោទពុំមានបំណងអសុទ្ធចិត្តណាមួយធ្វើឲ្យប៉ះពាល់ដល់កិត្តិយសកូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយជារឿងក្នុងរង្វង់គ្រួសារនោះ មានកំហុសឆ្គងដូចមានចែងក្នុងមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជាការបំភ្លៃអង្គហេតុហើយ ព្រោះថា ការពោលអះអាងរបស់ជនជាប់ចោទ ប្រាប់ដល់សាក្សីពីររូបឈ្មោះ...នូវពាក្យដែលថា "កូនស្រីជនរងគ្រោះកំពុងកាច់កកូននៅផ្ទះយាយម៉ប តែកាច់មិនធ្លាក់ ហើយឥឡូវកំពុងរលេះរលួយនោះ" ជាការទំលាក់កំហុសធ្វើឲ្យប៉ះពាល់ដល់កិត្តិយសកូនស្រីដើមបណ្តឹងរដ្ឋប្បវេណីហើយ"[74]។

## ៧.ការគ្មានសំអាងហេតុ[75]

សេចក្តីសម្រេចរបស់តុលាការជាន់ក្រោម ដែលធ្វើឡើងដោយគ្មានសំអាងហេតុ អាចត្រូវបានបដិសេធចោលដោយ តុលាការកំពូល។ ជាគោលការណ៍ គ្រប់ការសម្រេចសេចក្តីរបស់តុលាការត្រូវមានសំអាងហេតុ[76]។ សំអាងហេតុគឺសំដៅទៅលើអំណះអំណាងនៃអង្គហេតុ និងអំណះអំណាងនៃអង្គច្បាប់[77]។ ការសម្រេចសេចក្តីដោយ មានសំអាងហេតុធ្វើឲ្យគេមាន

---

[73] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៥៧។

[74] សូមមើល សាលដីកាតុលាការកំពូលលេខ ៩៧ ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០៧ សំណុំរឿងព្រហ្មទណ្ឌលេខ ១១ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៧ ទំព័រ ៤ ។

[75] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ៨។ អ្នកនិពន្ធយល់ថា បើបកស្រាយតាមពាក្យពេចន៍ "គ្មានសំអាងហេតុ" គឺស្មើនឹងសេចក្តីសម្រេចមួយដែលគ្មានសំអាងហេតុសោះពោលគឺ គ្មានអំណះអំណាងអង្គហេតុ និងអង្គច្បាប់។ ការបកស្រាយបែបនេះហាក់មានលក្ខណៈតឹងរឹង ព្រោះថាចំណុចទី៨នៃមាត្រា ៤១៩ គឺប្រើប្រាស់តែទៅលើករណីដែលសេចក្តីសម្រេចរបស់តុលាការជាន់ក្រោម សម្រេចដោយគ្មានសំអាងអ្វីទាំងអស់ ចុះបើករណី ដែលមានតែសំអាងហេតុដែលមានតែទឡ្ហីករណ៍អង្គច្បាប់ តែខ្វះទឡ្ហីករណ៍អង្គហេតុវិញ គឺគេមិនអាចប្រើមាត្រានេះបានឡើយ។ តែបើគេបកស្រាយតាមរយៈការពិនិត្យលើគោលគំនិតរបស់អ្នកតាក់តែងច្បាប់ គឺយើងអាចពិនិត្យមើលលើអត្ថបទដើមនៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌនេះ ជាភាសាបារាំងដោយហេតុថា រដ្ឋាភិបាលបារាំងបានជួយដល់កម្ពុជាក្នុងការតាក់តែងក្រមនេះ។ ក្នុងសេចក្តីព្រាងជាភាសាបារាំង គឺគេប្រើពាក្យ "defaut de motif" ឬបកប្រែថា "កង្វះសំអាងហេតុ"។ ហេតុដូច្នេះតាមរយៈការបកស្រាយតាមគោលគំនិតដើមរបស់អ្នកតាក់តែងច្បាប់ គេគួរបកស្រាយថា "គ្មានសំអាងហេតុ" ទៅជា "កង្វះសំអាងហេតុ" វាហាក់ដូចជាសមហេតុផលជាង។

[76] មាត្រា ៧ វាក្យខណ្ឌ៥ ច្បាប់ចាត់តាំងតុលាការ ២០១៤។

[77] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៥៧។

ទំនុកចិត្តទៅលើសេចក្ដីសម្រេចនោះ ដោយហេតុថាជាការសម្រេចសេចក្ដីដែលមានហេតុផល ហើយធ្វើឲ្យអ្នកដែលមិនពេញចិត្តនឹងការសម្រេចសេចក្ដីនោះ មានមូលដ្ឋានដើម្បីអាចប្ដឹងតវ៉ាទៅតុលាការជាន់ខ្ពស់។ ឧទាហរណ៍ តុលាការជាន់ក្រោមបានសម្រេចធ្វើសវនាការជាអសាធារណៈ ដោយសារសាធារណៈភាពនេះអាចមានគ្រោះថ្នាក់ដល់សណ្ដាប់ធ្នាប់សាធារណៈ[78] ប៉ុន្តែតុលាការជាន់ក្រោមមិនផ្ដល់ទឡ្ហីករណ៍អង្គហេតុអ្វីដែលនាំឲ្យខ្លួនយល់ឃើញថា តើកត្តាអ្វីបង្កជាគ្រោះថ្នាក់ដោយសារសវនាការជាសាធារណៈ។ ដូច្នេះ ភាគីមិនអាចដឹងថាតើមូលហេតុនោះត្រឹមត្រូវ ឬសមហេតុផលដែរឬអត់ បើសិនតុលាការមិនបង្ហាញហេតុផលនោះផង។ ករណីមួយទៀតគឺ ការសម្រេចឃុំខ្លួនដោយគ្រាន់តែយោងលើ លក្ខខណ្ឌដែលមានចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដូចជា ថាការឃុំជាករណីចាំបាច់ដើម្បីបង្ការកុំឲ្យជនជាប់ចោទគាបសង្កត់ បំភិតបំភ័យសាក្សី ឬក៏ថាការឃុំខ្លួនគឺ ជាជម្រើសតែមួយគត់ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈជាអាទិ៍[79] ពោលគឺជាអំណះអំណាងអង្គច្បាប់ប៉ុណ្ណោះ ប៉ុន្តែវាពុំមែនជាសេចក្ដីសម្រេចដែលមានសំអាងហេតុគ្រប់គ្រាន់ឡើយ ដោយហេតុថា តុលាការដែលចេញសេចក្ដីសម្រេចពុំផ្ដល់អ្វីដែលខ្លួនជាទឡ្ហីករណ៍អង្គហេតុសម្រាប់ការពិចារណានិងសម្រេចឃុំខ្លួន តាមមាត្រា២០៥នេះឡើយ[80] ។

## ៨. ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្ដីសម្រេច

ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្ដីសម្រេច ក៏ជាមូលហេតុមួយដែលតុលាការកំពូលអាចច្រានចោលសេចក្ដីសម្រេចរបស់តុលាការជាន់ក្រោម[81]។ សំអាងហេតុ ជាការយល់ឃើញរបស់តុលាការ តាមរយៈការសន្និដ្ឋានទៅលើអង្គហេតុ អង្គច្បាប់ ដើម្បីឈានទៅដល់ការសម្រេចសេចក្ដីមួយ[82]។ ជាទូទៅ ដើម្បីឲ្យគេយល់បានពីមូលហេតុដែលនាំឲ្យដល់ការសម្រេចសេចក្ដីមួយគឺ គេតោងមើលទៅលើការយល់ឃើញ ឬសំអាងហេតុនៃសេចក្ដីសម្រេចនោះ។ សំអាងហេតុត្រូវតែស៊ីសង្វាក់គ្នាជាមួយនឹងសេចក្ដីសម្រេច។ កាលណាការសម្រេចសេចក្ដីដែលផ្ទុយគ្នាពីសំអាងហេតុធ្វើឲ្យគេមិនអាចដឹងថា តើសេចក្ដីសម្រេចឈរលើមូលដ្ឋានអ្វីពិតប្រាកដ។

[78] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣១៦។

[79] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៥ ចំណុចទី ២ និង៦។

[80] សម្រាប់មូលហេតុនៃការឃុំខ្លួន ដែលអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងករណីនៅអន្តរជាតិ សូមមើល សេចក្ដីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖ សេចក្ដីពន្យល់ស្ដីពីករណីយុត្តិសាស្ត្រ (អ.វ.ត.ក) និងអន្តរជាតិសម្រាំង, បោះពុម្ពផ្សាយលើកទីពីរ នៅខែធ្នូ ឆ្នាំ២០១៥ ទំព័រ ១៣០ ដល់១៤២។

[81] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១៩ ចំណុចទី ៩។

[82] សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៥៧។

តុលាការកំពូលបានច្រានចោលសេចក្តីសម្រេចតុលាការជាន់ក្រោម ដោយសារមានភាពផ្ទុយគ្នាពីសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដែលសម្រេចមិនធ្វើការចាត់របៀប (អញ្ញត្រកម្ម) ដើម្បីរង់ចាំសេចក្តីសម្រេចបន្ទាន់បង្ខំលើរឿងក្តីរដ្ឋប្បវេណីអំពីកម្មសិទ្ធិ មុននឹងសម្រេចទៅលើការរំលោភបំពានទៅលើកម្មសិទ្ធិដែលជាបទល្មើសព្រហ្មទណ្ឌ ដែលសាលាឧទ្ធរណ៍យល់ឃើញក្នុងសំអាងហេតុរបស់ខ្លួនពីបញ្ហាវិវាទកម្មសិទ្ធិ[83]។ ក្នុងរឿងក្តីនេះ តុលាការកំពូលយល់ឃើញថា ការណ៍ដែលសាលាឧទ្ធរណ៍មានសំអាងហេតុថា "រឿងនេះមានលក្ខណៈជារឿងព្រហ្មទណ្ឌរង់ចាំរឿងរដ្ឋប្បវេណីដែលគប្បីដោះស្រាយរឿងក្តីរដ្ឋប្បវេណីសិន ប៉ុន្តែបែរជាសម្រេចតម្កល់ដីកាសម្រេចលេខ...របស់តុលាការខេត្តបាត់ដំបង[84]នោះ ជាការបំពានលើមាត្រា៤១៩ ចំណុចទី៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ....ការដែលតុលាការខេត្តបាត់ដំបង សម្រេចមិនលើកយកបញ្ហាបន្ទាន់បង្ខំចំពោះបណ្តឹងក្នុងរឿងនេះ ដោយសំអាងហេតុថា ជនជាប់ចោទឈ្មោះ...ពុំមានលិខិតស្នាមត្រឹមត្រូវ និងគ្រប់គ្រាន់ទៅតាមច្បាប់នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះតាមការបញ្ជាក់របស់គូភាគីនាពេលសវនាការនៅតុលាការកំពូលថា ដីទំនាស់ដែលឈ្មោះ...បានសង់ផ្ទះចូលនោះមានប្តឹងគ្នាតាំងតែពីឆ្នាំ១៩៩៣មកម្ល៉េះ ដូចនេះគប្បីមានការសម្រេចពីវិវាទសិទ្ធិលើ សិទ្ធិកាន់កាប់ពីតុលាការរដ្ឋប្បវេណីជាមុនសិន"[85]។

## ៩. សេចក្តីសន្និដ្ឋាន

ដោយហេតុថា តាមរយៈបណ្តឹងសាទុក្ខទៅតុលាការកំពូល មេធាវី (ឬភាគី) មានឱកាសតែមួយគត់[86]ដើម្បីស្នើសុំឲ្យតុលាការកំពូល បដិសេធចោលសេចក្តីសម្រេចតុលាការជាន់ក្រោម ព្រោះថា សេចក្តីសម្រេចតុលាការកំពូលគឺ ជាសេចក្តីសម្រេចចុងក្រោយ ហើយបិទផ្លូវតវ៉ា។ ដូច្នេះហើយ ការយល់ដឹងបន្ថែមអំពីមូលដ្ឋានដែលនាំឲ្យតុលាការកំពូលបដិសេធសេចក្តីសម្រេចតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានសារៈសំខាន់ ។ យ៉ាងណាក៏ដោយ មិនមែនមូលហេតុទាំង ៩ នៃមាត្រា ៤១៩ នឹងកើតមានគ្រប់ករណីនោះទេ។ ការកំណត់ច្បាស់លាស់អំពីមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំង៩ ក្នុងសារណានៃបណ្តឹងសាទុក្ខជួយដល់តុលាការដើម្បីពិនិត្យពិចារណាលើបណ្តឹងសាទុក្ខឲ្យបានឆាប់ និងត្រឹមត្រូវ ចំណេញពេលវេលា និងសន្សំសំចៃដល់តុលាការ និងរដ្ឋ ។

---

83 សូមមើល សាលដីកាតុលាការកំពូលលេខ ៨៩ ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០០៧ សំណុំរឿងព្រហ្មទណ្ឌលេខ ១៦ ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៦ ទំព័រ ៥ ។

84 *ដូចយោងខាងលើ* ទំព័រ ៥។ តុលាការខេត្តបាត់ដំបងចេញដីកាសម្រេចមិនលើកបញ្ហាបន្ទាន់បង្ខំក្នុងរឿងព្រហ្មទណ្ឌ។

85 *ដូចយោងខាងលើ*។

86 សម្រាប់ករណីពិសេសផ្សេងពីនេះ សូមមើល សេចក្តីផ្តើមខាងដើម។

# ផ្នែកពាណិជ្ជកម្ម

# ភតិសន្យាហិរញ្ញវត្ថុ

ដោយមេធាវី **កុយ គន្ធី***

## ១. សេចក្តីផ្តើម

បន្ថែមពីលើកម្លាំងពលកម្ម អាជីវកម្មត្រូវការឧបករណ៍ សម្ភារៈផ្សេងៗដើម្បីផលិតរបស់របរ ឬសេវាកម្មរបស់ខ្លួនដើម្បីធ្វើឲ្យសម្រេចបានគោលដៅរបស់ខ្លួន។ ឧបករណ៍ទាំងនោះមានដូចជា ម៉ាស៊ីន រថយន្ត ត្រាក់ទ័រ ម៉ាស៊ីនឈូស ម៉ាស៊ីនបោះពុម្ពល។ល។ ឧបករណ៍ និងសម្ភារៈទាំងនេះអាចបានមកពីការទិញ ការខ្ចី ឬការជួលពីបុគ្គល ឬពីក្រុមហ៊ុនណាមួយ។ ឧបករណ៍ខ្លះមានតម្លៃខ្ពស់ ជាហេតុធ្វើឲ្យអាជីវកម្មមួយត្រូវចំណាយដើមទុនច្រើន ដើម្បីទិញឧបករណ៍នោះយកមកប្រើការ។ បើចំណាយប្រាក់ច្រើនដើម្បីទិញឧបករណ៍មកប្រើប្រាស់ នោះអាជីវកម្មនឹងត្រូវខើចដើមទុនដើម្បីយកទៅចំណាយសម្រាប់ប្រតិបត្តិការផ្សេងៗ។ ដើម្បីកាត់បន្ថយការប្រើប្រាស់ដើមទុនច្រើននៅក្នុងការទិញឧបករណ៍ អាជីវកម្មអាចទិញដោយ បង់ជាវគ្គៗ។ ប៉ុន្តែការទិញលក់ជាវគ្គៗនេះ ទាមទារឲ្យអាជីវកម្មមានជំហរឥណទានល្អ មានន័យថា អាជីវកម្មមានស្ថានភាពហិរញ្ញវត្ថុមួយដែលឲ្យអ្នកលក់ជឿថា អាជីវកម្មអាចមានប្រាក់បង់រំលោះដល់ចប់ចុងចប់ដើមនៃការទិញឧបករណ៍នោះ។ ជំនួសឲ្យការទិញផ្តាច់ ឬការទិញដោយបង់ថ្លៃទិញជាវគ្គ អាជីវកម្មនៅមានវិធីជំនួសមួយ គឺការជួលឧបករណ៍ប្រើ។ ការជួលឧបករណ៍ប្រើនេះមានពីរប្រភេទ៖ ការជួលប្រតិបត្តិការ និងការជួលហិរញ្ញវត្ថុ ឬហៅតាមភាសាច្បាប់ថា ភតិសន្យាប្រតិបត្តិការ និងភតិសន្យាហិរញ្ញវត្ថុ។

## ២. ភតិសន្យាប្រតិបត្តិការ

ភតិសន្យាប្រតិបត្តិការដែលភាសាអង់គ្លេស ហៅថា Operating Lease គឺជាភតិសន្យា ឬជាកិច្ចសន្យាជួលមួយដែលនៅក្នុងនោះម្ចាស់របស់ ឬភតិបតីជួលឧបករណ៍ទៅឲ្យមនុស្សម្នាក់ទៀតជាអ្នកជួល ឬភតិកៈសម្រាប់ប្រើ ហើយភតិបតីមានសិទ្ធិកម្មសិទ្ធិលើឧបករណ៍នោះរួចហើយ ភតិកៈមានកាតព្វកិច្ចត្រូវប្រគល់ឧបករណ៍ទៅឲ្យភតិបតីវិញនៅដំណាច់រយៈពេលនៃកិច្ចសន្យា។ បើនិយាយឲ្យងាយស្តាប់ ភតិសន្យាប្រតិបត្តិការមានន័យស្មើនឹងភតិសន្យាធម្មតាដែលចែងនៅ

---

* លោក **កុយ គន្ធី** ជាមេធាវីនៅការិយាល័យមេធាវី ខេអិន ពិគ្រោះច្បាប់។ លោក **កុយ គន្ធី** ប្រកបវិជ្ជាជីវៈមេធាវីនៅក្នុងវិស័យភតិសន្យាហិរញ្ញវត្ថុ, ប្រតិបត្តិការអចលនវត្ថុ, ការសាងសង់, រដ្ឋប្បវេណី និងព្រហ្មទណ្ឌ។

ក្នុងមាត្រា៥៩៦ នៃក្រមរដ្ឋប្បវេណី។ ភតិកៈមានកាតព្វកិច្ចត្រូវបង់ថ្លៃជួលឧបករណ៍ជាវគ្គៗទៅតាមការកំណត់នៅក្នុងកិច្ចសន្យា។

នៅក្នុងភតិសន្យាប្រតិបត្តិការ ដោយសារភតិកៈមិនមែនជាម្ចាស់ឧបករណ៍ ភតិកៈត្រូវចុះក្នុងគណនេយ្យរបស់ខ្លួននូវប្រាក់ថ្លៃជួលថា ជាការចំណាយ ហើយគណនេយ្យរបស់ភតិកៈមិនបង្ហាញឧបករណ៍នោះនៅក្នុងខ្ទង់ទ្រព្យសកម្មរបស់ភតិកៈទេ។ តាមគណនេយ្យបែបនេះ ភតិកៈត្រូវចុះថ្លៃជួលជាការចំណាយ។ ជាមួយនឹងការចំណាយផ្សេងៗទៀត គេយកការចំណាយលើថ្លៃជួលនេះទៅកាត់ចេញពីប្រាក់ចំណូល ដែលនាំឲ្យមានកាត់បន្ថយចំណូលដែលជាប់ពន្ធ។ ភតិកៈមានអត្ថប្រយោជន៍មួយទៀត គឺការជួសជុលជាមូលដ្ឋាន (ដូចជាការជួសជុលប្រចាំ) ការចុះបញ្ជី ឬសោហ៊ុយផ្នែករដ្ឋបាលនានាលើឧបករណ៍ (ដូចជាការបង់ពន្ធប្រចាំឆ្នាំ បើមាន) ត្រូវជាបន្ទុករបស់ភតិបតី។ ភតិបតីត្រូវចុះឧបករណ៍នៅក្នុងខ្ទង់ទ្រព្យសកម្មរបស់ខ្លួន។ ភតិបតីទទួលបានអត្ថប្រយោជន៍នៃការចុះតម្លៃទ្រព្យដែលត្រូវគិតជាការចំណាយ និងដែលនាំឲ្យមានការកាត់បន្ថយចំណូលដែលជាប់ពន្ធ។

## ៣. ភតិសន្យាហិរញ្ញវត្ថុ

ភតិសន្យាហិរញ្ញវត្ថុជាកិច្ចសន្យាកូនកាត់រវាងការទិញដោយ បង់ជាវគ្គៗ និងភតិសន្យាប្រតិបត្តិការ។ តាមនិយមន័យ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៦០៩/០០៨ចុះថ្ងៃទី២០មិថុនាឆ្នាំ២០០៩ ភតិសន្យាហិរញ្ញវត្ថុគឺជាកិច្ចសន្យាជួលឧបករណ៍រវាងភតិបតី និងភតិកៈដែលភតិកៈមានកាតព្វកិច្ចត្រូវបង់ថ្លៃជួលឧបករណ៍ជាវគ្គៗ ក្នុងរយៈពេលមួយមិនតិចជាងមួយឆ្នាំ ហើយនៅដំណាច់រយៈពេលនៃកិច្ចសន្យា ភតិកៈត្រូវមានសិទ្ធិទិញ ឬមិនទិញឧបករណ៍ដែលជួលនោះ។

ដើម្បីធ្វើឲ្យសម្រេចបានភតិសន្យាហិរញ្ញវត្ថុមានតួអង្គបីដែលដើរតួ គឺ(១) អ្នកផ្គត់ផ្គង់ឧបករណ៍ (២) ភតិបតី និង (៣) ភតិកៈ ហើយត្រូវធ្វើតាមនីតិវិធីដូចមាននៅក្នុងឌីយ៉ាក្រាមខាងក្រោមនេះ៖



នៅក្នុង**ជំហានទី ១** ភតិកៈត្រូវចរចាជាមួយអ្នកផ្គត់ផ្គង់ដើម្បីជ្រើសរើសយកឧបករណ៍ណាដែលខ្លួនពេញចិត្តសម្រាប់យកមកប្រើប្រាស់ឲ្យត្រូវគោលបំណងនៃអាជីវកម្មរបស់ខ្លួន។

នៅក្នុង**ជំហានទី ២** ភតិកៈត្រូវចរចាសុំចុះភតិសន្យាជួលឧបករណ៍ (ភតិសន្យាហិរញ្ញវត្ថុ) ជាមួយភតិបតី ដោយចង្អុលប្រាប់ពីឧបករណ៍ និង អ្នកផ្គត់ផ្គង់ប្រាប់ភតិបតី។

នៅក្នុង**ជំហានទី ៣** ភតិកៈ និង ភតិបតីឈានដល់កិច្ចព្រមព្រៀងនិងចុះភតិសន្យាហិរញ្ញវត្ថុ។

នៅក្នុង**ជំហានទី ៤** ភតិបតី និង អ្នកផ្គត់ផ្គង់ចុះកិច្ចសន្យាទិញលក់ឧបករណ៍សម្រាប់យកមកជួលឲ្យភតិកៈ។

នៅក្នុង**ជំហានទី ៥** អ្នកផ្គត់ផ្គង់ដឹកជញ្ជូន ឬ ប្រគល់ឧបករណ៍មកឲ្យភតិកៈ។

នៅក្នុង**ជំហានទី ៦** ភតិកៈចុះហត្ថលេខាទទួលយកឧបករណ៍ រួចចេញសេចក្តីបញ្ជាក់មួយឲ្យ ភតិកៈថា ខ្លួនបានទទួលឧបករណ៍ហើយ។

នៅក្នុង**ជំហានទី ៧** ភតិបតី បង់ថ្លៃទិញឧបករណ៍ឲ្យអ្នកផ្គត់ផ្គង់។

នៅក្នុង**ជំហានទី ៨** អ្នកផ្គត់ផ្គង់និង ភតិកៈចុះហត្ថលេខាលើកិច្ចសន្យាថែទាំ ឧបករណ៍ជាមួយភតិកៈ (ប្រសិនជាគេចង់ធ្វើដូច្នេះ)។

គួរកត់សំគាល់ថា នៅក្នុងភតិសន្យាហិរិញ្ញវត្ថុ ភតិកៈជាអ្នកជ្រើសរើសយកអ្នកផ្គត់ផ្គង់និងឧបករណ៍ដែលខ្លួនឯងចង់បានដោយខ្លួនឯង។ ភតិកៈមិនពឹងផ្អែកលើការវិនិច្ឆ័យ ឬជំនាញរបស់ភតិបតីឡើយ។ ហេតុដូច្នេះ បើឧបករណ៍នោះបែរជាប្រើការមិនកើត ដោយសារលក្ខណៈបច្ចេកទេសរបស់វា មិនត្រូវនឹងកិច្ចការដែលឧបករណ៍នោះ ត្រូវបំពេញនៅក្នុងអាជីវកម្មរបស់ភតិកៈ ភតិកៈមិនអាចទៅរករឿងភតិបតីថា ទិញឧបករណ៍មិនត្រូវហើយទាមទារលុបចោលកិច្ចសន្យា ឬទាមទារឲ្យភតិកៈសងការខូចខាតទេ។ នៅពេលចរចាជួលឧបករណ៍ ភតិបតី ឬភ្នាក់ងារ ឬបុគ្គលិករបស់ខ្លួនមិនត្រូវឲ្យឱវាទ ឬកិច្ចប្រឹក្សាណាមួយដល់ភតិកៈអំពីលក្ខណៈបច្ចេកទេស ឬលក្ខណៈប្រើប្រាស់របស់ឧបករណ៍ឡើយ។ នេះជារឿងមួយសំខាន់ដោយសារ ឧបករណ៍ខ្លះមានតម្លៃដល់ទៅរាប់សែន ឬរាប់លានដុល្លារ។ នៅពេលដែលយកមកប្រើមិនត្រូវតាមគោលដៅរបស់ខ្លួន ភតិកៈអាចប្តឹងទាមទាររំលាយកិច្ចសន្យា ឬទាមទារសំណងខូចខាត។ ដើម្បីការពារទប់ទល់នឹងបញ្ហាដែលអាចកើតឡើងជាយថាហេតុ នៅក្នុងភតិសន្យាហិរញ្ញវត្ថុ គេតែងតែចែងប្រការមួយ ដើម្បីឲ្យភតិបតីបដិសេធការធានាថាឧបករណ៍ទៅនឹងគោលបំណងប្រើប្រាស់របស់វា ព្រោះការជ្រើសរើសឧបករណ៍ គឺជាវិនិច្ឆ័យរបស់ភតិកៈខ្លួនឯង។ គេអាចចែងឧបដិសេធមួយដែលអាចមានសេចក្តីថា៖

> ភតិកៈជួលឧបករណ៍ក្នុងសភាពជាក់ស្តែង ហើយដោយសារភតិបតីមិនមែនជាអ្នកផលិតឧបករណ៍ ឬជាភ្នាក់ងាររបស់អ្នកផលិត ឬជាភ្នាក់ងារនៃអ្នកលក់ឧបករណ៍ ភតិបតីមិនធ្វើការធានា ឬការអះអាងបែបណាមួយ ទោះបីជាក់ច្បាស់ក្តី ដោយ

គុណ្ហភាពក្តី ថាឧបករណ៍នោះអាចយកទៅលក់ដូរបាន ឬឧបករណ៍នោះសក្តិសម នឹងយកទៅប្រើបានសម្រាប់គោលបំណងណាមួយឡើយ។ ភតិបតីមិនទទួលខុសត្រូវ ចំពោះការខូចខាតណាមួយ ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ឬដោយសារផល វិបាកក្តី ដែលកើតចេញពីការកាន់កាប់ ឬការប្រើប្រាស់ឧបករណ៍នេះទេ។

ចំពោះរយៈពេលនៃការជួលវិញ នៅក្នុងច្បាប់ខ្មែរ គេមិនត្រូវកំណត់តិចជាងមួយឆ្នាំទេ (មាត្រា ១០)។ នៅក្នុងច្បាប់នៃប្រទេសខ្លះ គេកំណត់ថា រយៈពេលនៃភតិសន្យាហិរញ្ញវត្ថុមិនត្រូវតិចជាង៧៥% នៃអាយុកាលនៃឧបករណ៍ទេ។ រយៈពេលតិចជាងនេះ គេចាត់ទុកជាការលក់ដោយបង់ជាវគ្គ។ ឧបមាថា ម៉ាស៊ីនមួយដែលមានអាយុប្រើការបានរបស់វា ១០ ឆ្នាំ រយៈពេលនៃភតិសន្យាហិរញ្ញវត្ថុមិនត្រូវតិចជាង៨ឆ្នាំបានទេ។ ការចាត់ចូលជាការលក់ឧបករណ៍តាមការបង់ជាវគ្គ ឬជាភតិសន្យាហិរញ្ញវត្ថុគឺ ជាសំខាន់ព្រោះវាផលប៉ះពាល់ដល់គណនេយ្យឧបករណ៍ និងការកំណត់ពន្ធដារលើប្រាក់ចំណេញនៃអាជីវកម្មទាំងរបស់ភតិបតី ទាំងរបស់ភតិកៈ។

សង្ខេបមកវិញ ភតិសន្យាហិរញ្ញវត្ថុមានធាតុផ្សំដូចតទៅនេះ៖

១. ភតិបតីមិនមែនជាអ្នកលក់វត្ថុដែលត្រូវជួលនោះទេ
២. ភតិបតីជាអ្នកធ្វើហិរញ្ញប្បទានដើម្បីអាចឲ្យភតិកៈទទួលបានវត្ថុជួលនោះ
៣. ភតិបតីជាម្ចាស់កម្មសិទ្ធិលើវត្ថុដែលជួល
៤. កិច្ចសន្យាជួល ឬភតិសន្យានេះមិនអាចតិចជាងមួយឆ្នាំឡើយ
៥. ភតិកៈជាអ្នកបង់ថ្លៃជួលវត្ថុ
៦. ភតិកៈមានសិទ្ធិទិញ ឬមិនទិញវត្ថុដែលជួលនោះ
៧. ភតិបតីមានសិទ្ធិកាន់កាប់ឡើងវិញនូវវត្ថុជួលនោះ ប្រសិនបើភតិកៈមិនគោរពកាតព្វកិច្ចរបស់ខ្លួននៅក្រោមភតិសន្យាហិរញ្ញវត្ថុនោះ។

ការចាត់ចែងភតិសន្យាហិរញ្ញវត្ថុដែលមិនត្រឹមត្រូវតាមច្បាប់ អាចធ្វើឲ្យភតិបតីបាត់បង់ឋានៈជាអ្នកជួល/ភតិបតី ហើយក្លាយទៅជាអ្នកលក់ជាវគ្គៗវិញ។ កាលណាភតិបតីក្លាយជាអ្នកលក់ ភតិបតីអាចបាត់បង់អត្ថប្រយោជន៍ និងកិច្ចការពារតាមផ្លូវច្បាប់ផ្សេងៗ ដែលច្បាប់ស្តីពីភតិ-សន្យាហិរញ្ញវត្ថុផ្តល់ឲ្យ។ ឧទាហរណ៍ ភតិបតីអាចបាត់បង់អត្ថប្រយោជន៍ខាងពន្ធដារ និងកិច្ចការពារតាមផ្លូវច្បាប់នៅពេលទាមទារការកាន់កាប់ឡើងវិញជាដើម។

# កិច្ចព្រមព្រៀងមជ្ឈត្តការ

កុយ នាម*

## ១.ប្រភពនៃមជ្ឈត្តការ

ការដោះស្រាយជម្លោះនៅតុលាការ ស្ថិតក្រោមនីតិវិធីច្បាប់ដែលភាគីជម្លោះត្រូវតែគោរពតាម ទោះបីជានីតិវិធីនោះស្មុគស្មាញយ៉ាងណាក៏ដោយ។ ការមិនគោរពតាមនីតិវិធីដែលច្បាប់បានកំណត់មកស្រាប់នោះ អាចធ្វើឲ្យភាគីថ្លោះសិទ្ធិនៅក្នុងការទាមទាររបស់ខ្លួន។ វេទិកាមជ្ឈត្តការគឺជាវេទិកាស្វែងរកយុត្តិធម៌ដោយ ការព្រមព្រៀងគ្នា (Consensual Justice) ដែលខុសគ្នាពីនីតិវិធីតុលាការដែលភាគីគ្មានការត្រួតត្រាលើដំណើរការរកយុត្តិធម៌ទេ។ យុត្តិធម៌ដោយការព្រមព្រៀងជាមូលដ្ឋានគឺ យុត្តិធម៌មួយដែលភាគីជាអ្នកកំណត់វេទិកា និងត្រួតត្រានីតិវិធី។ ផ្ទុយពីនីតិវិធីតុលាការដែលមានភាពរឹងកំព្រឹសដែលមិនអាចកែប្រែបាន នីតិវិធីនៅក្នុងមជ្ឈត្តការមានភាពទន់ភ្លន់ដែលអាចបត់បែនបានច្រើនទៅតាមការចង់បានរបស់ភាគី។ ដោយសារភាគីជាអ្នកកំណត់វេទិកា វេទិកាមជ្ឈត្តការកើតចេញមកពីការព្រមព្រៀងរបស់ភាគីនៃជម្លោះ តាមរយៈការព្រមព្រៀងបង្កើតវេទិកាមជ្ឈត្តការ។ ភាគីមានការព្រមព្រៀងគ្នាក្នុងការបង្កើតវេទិកានេះ ដែលផ្ទុយពីវេទិកាតុលាការ ដែលច្បាប់ជាអ្នកកំណត់ឲ្យ។

គេអាចរកឃើញការព្រមព្រៀងបង្កើតវេទិកាមជ្ឈត្តការនេះនៅក្នុងកិច្ចសន្យាគោល និងកិច្ចព្រមព្រៀងដោយឡែកមួយ។ កិច្ចសន្យាគោលគឺជាកិច្ចសន្យាដែលបង្កើតសិទ្ធិ និងកាតព្វកិច្ចនៅក្នុងប្រតិបត្តិការណាមួយ ឧទាហរណ៍ កិច្ចសន្យាផ្គត់ផ្គង់ទំនិញ កិច្ចសន្យាការងារ កិច្ចសន្យាជួលរោងចក្រ។ល។ នៅក្នុងកិច្ចសន្យាគោលនេះ ក្រៅពីមានខចែងពីសិទ្ធិនិងកាតព្វកិច្ចផ្តល់ទំនិញ និងសិទ្ធិទទួលការបង់ប្រាក់ដើម កិច្ចសន្យាផ្គត់ផ្គង់នោះអាចចែងពីខដោះស្រាយជម្លោះមួយ (Dispute Resolution Clause) ដែលបញ្ជាក់ពីរបៀបដោះស្រាយជម្លោះបែបទូលំទូលាយរួមមានការដោះស្រាយជម្លោះជាដំណាក់ៗ ចាប់ពីការចរចាគ្នាដោយផ្ទាល់ រហូតការផ្សះផ្សាគ្នាដោយមានជំនួយពីភាគីទីបី និងទីបញ្ចប់ ការដោះស្រាយតាមវេទិកាមជ្ឈត្តការ។ ជួនកាលភាគីមិនបានចែងពីខដោះស្រាយជម្លោះបែបទូលំទូលាយទេ តែគេចែងពីខមជ្ឈត្តការ (Arbitration Clause) តែម្តង។ ដោយការភ្លេច ឬដោយប្រការណាមួយ ភាគីមិនបានចែងខដោះស្រាយជម្លោះទេ ដូច្នេះនៅពេលមានជម្លោះក្រោយពីចុះកិច្ចសន្យាគោល ភាគីបានព្រមព្រៀងគ្នាជ្រើសរើសយកវេទិកាមជ្ឈត្តការដើម្បីដោះស្រាយជម្លោះរបស់ខ្លួន។ ដើម្បីអាចឲ្យវេទិកាមជ្ឈត្តការ

* កុយ នាម ជាមជ្ឈត្តករពាណិជ្ជកម្ម, អាជ្ញាកណ្តាលការងារ និងជាមេធាវីនៅការិយាល័យ KN Legal Consulting.

មានសមត្ថកិច្ចលើជម្លោះរបស់គេបាន ភាគីត្រូវចុះកិច្ចព្រមព្រៀង ដោយឡែកមួយដើម្បីដោះស្រាយជម្លោះ។ កិច្ចព្រមព្រៀងដោយឡែកនោះអាចជាខដោះស្រាយជម្លោះបែបទូលំទូលាយ ឬអាចជាកិច្ចព្រមព្រៀងធ្វើមជ្ឈត្តការតែម្តង (Agreement to arbitrate)។

ទោះបីខដោះស្រាយជម្លោះត្រូវបានបញ្ចូលនៅក្នុងកិច្ចសន្យាគោល ឬ នៅក្នុងកិច្ចព្រមព្រៀងដោយឡែកក្តី ច្បាប់ទទួលស្គាល់ការជ្រើសរើសរបស់ភាគីជានិច្ច។ ឧទាហរណ៍ មាត្រា ៧ នៃច្បាប់ស្តីពីមជ្ឈត្តការកម្ពុជាចែងថា៖

> កិច្ចព្រមព្រៀងផ្សះផ្សា [មជ្ឈត្តការ] [Arbitration Agreement or Agreement to arbitrate] រួមមានខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា ឬ នៅក្នុងកិច្ចព្រមព្រៀងដោយឡែក។

មាត្រា ៧ ខាងលើនេះចែងថា "កិច្ចព្រមព្រៀងផ្សះផ្សា" ដែលអាចជាការច្រឡំក្នុងការបកប្រែពីភាសាអង់គ្លេស Arbitration Agreement ព្រោះសេចក្តីនៃមាត្រានេះចង់និយាយដល់កិច្ចព្រមព្រៀងធ្វើមជ្ឈត្តការ។

## ខនៃការដោះស្រាយជម្លោះបែបទូលំទូលាយ

ឧទាហរណ៍ ខ នៃការដោះស្រាយជម្លោះទូទៅ៖

> "បើសិនជាជម្លោះកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ឬកើតចេញពីការល្មើសកិច្ចសន្យានេះ ហើយបើសិនជាជម្លោះមិនអាចដោះស្រាយតាមរយៈការចរចាបានទេ ភាគីព្រមព្រៀងដោះស្រាយតាមរយៈសន្ទានកម្មដោយសុទ្ធចិត្ត ដែលត្រូវចាត់ធ្វើដោយ[ស្ថាប័ន ឬបុគ្គលដែលជ្រើសរើស] ស្របតាមនីតិវិធីនៃសន្ទានកម្មនៃ[ស្ថាប័ន ឬបុគ្គលដែលជ្រើសរើស] មុននឹងបញ្ជូនទៅដោះស្រាយដោយមជ្ឈត្តការដោយ [ស្ថាប័នឬ បុគ្គលដែលជ្រើសរើស]"។

ដូចបានពិពណ៌នាខាងលើ គេអាចប្រមូលផ្តុំមធ្យោបាយដោះស្រាយជម្លោះនានា នៅក្នុងខនៃការដោះស្រាយជម្លោះតែមួយ ដោយឆ្លងពីមធ្យោបាយមួយទៅមធ្យោបាយមួយកាលណាការដោះស្រាយនោះត្រូវបរាជ័យក្នុងមធ្យោបាយណាមួយ។ ប៉ុន្តែនៅទីបញ្ចប់គេប្រើមធ្យោបាយដោះស្រាយដោយ មជ្ឈត្តការ។

### ខ មជ្ឈត្តការ

ឧទាហរណ៍ នៅក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញមួយ ភាគីអាចបញ្ចូលខមជ្ឈត្តការដែលចែងថា នៅពេលណាមានជម្លោះ ភាគីត្រូវយកជម្លោះនោះទៅដោះស្រាយនៅឯវេទិកាមជ្ឈត្តការតែម្តង។ ខមជ្ឈត្តការជាទូទៅមានសេចក្តីជាស្តង់ដាដូចខាងក្រោមនេះ៖

> វិវាទ ឬការទាមទារណាមួយដែល**កើតចេញពី** ឬ **ទាក់ទងនឹង**កិច្ចសន្យានេះ ឬការល្មើសកិច្ចសន្យានេះ ត្រូវដោះស្រាយដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការពាណិជ្ជកម្មស្របតាមវិធាននៃមជ្ឈមណ្ឌលនេះ។

#### គំរូ ខ មជ្ឈត្តការនៃសមាគមមជ្ឈត្តការអាមេរិកកាំង

> Any controversy or claim **arising out of** or **relating to** this contract, or the breach thereof, shall be settled by arbitration administered by the American Arbitration Association in accordance with its Commercial [or other] Arbitration Rules, and judgment on the award rendered by the arbitrator(s) may be entered in any court having jurisdiction thereof.

## ២.ធាតុផ្សំនៃការបង្កើតកិច្ចព្រមព្រៀងមជ្ឈត្តការ

ដោយសារខមជ្ឈត្តការជាប្រភេទ នៃកិច្ចសន្យាមួយដែរនោះ ដូច្នេះខមជ្ឈត្តការនេះត្រូវបំពេញតាមធាតុផ្សំនៃការបង្កើតកិច្ចសន្យា។ ប្រសិនបើ ខមជ្ឈត្តការជ្រើសរើសយកច្បាប់ខ្មែរជាច្បាប់សម្រាប់គ្រប់គ្រង (Governing law) នោះធាតុផ្សំនៃការបង្កើតកិច្ចសន្យាត្រូវស្របតាមក្រមរដ្ឋប្បវេណីខ្មែរ៖ (១) ភាគីបានព្រមព្រៀងគ្នាដោយសេរីដើម្បីបង្កើតខមជ្ឈត្តការនេះ,ខនេះស្របច្បាប់ ឬមិនផ្ទុយនឹងច្បាប់, ភាគីមានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យា, ខនោះស្របតាមទម្រង់ដែលច្បាប់កំណត់។

### ក. កិច្ចព្រមព្រៀងដោយសេរី

កិច្ចព្រមព្រៀងដោយសេរីនេះ កើតឡើងដោយសំណើ និងស្វីការស្របតាមក្រមរដ្ឋប្បវេណីមាត្រា៣៣៦ និងមាត្រា៣៣៧)។ ស្វីការត្រូវស៊ីគ្នាជាមួយនឹងសំណើ។ ការស៊ីគ្នានេះបង្កើតបានជាកិច្ចព្រមព្រៀងដោយសេរី។ កិច្ចព្រមព្រៀងកើតឡើងដោយសេរី កាលណាគ្មានវិការៈនៅក្នុងការធ្វើសំណើ និងការធ្វើស្វីការ។ តឹកតាងមួយនៃការព្រមព្រៀងដោយសេរីគឺការចុះហត្ថលេខាលើកិច្ចព្រមព្រៀងធ្វើមជ្ឈត្តការ ឬលើកិច្ចសន្យាគោលដែលមានខមជ្ឈត្តការ។ ប៉ុន្តែដោយសារទំនើបកម្មនៃគមនាគមន៍ ជួនកាលការធ្វើសំណើ និងការធ្វើស្វីការអាចប្រព្រឹត្តទៅនៅកន្លែងផ្សេងគ្នា ជាពិសេស នៅពេលដែលភាគីនៅក្នុងប្រទេសផ្សេងគ្នា។ ភាគីអាចព្រមព្រៀងគ្នាចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀង ដោយផ្លាស់ប្តូរឯកសារតាមរយៈមធ្យោបាយអេឡិចត្រូនិច។ ដើម្បីសម្រួលដល់ការធ្វើប្រតិបត្តិការពាណិជ្ជកម្ម ច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនតម្រូវថា

កិច្ចសន្យា ឬកិច្ចព្រមព្រៀងត្រូវតែមានហត្ថលេខារបស់ភាគីទើបចាត់ទុកថាកិច្ចសន្យា ឬកិច្ចព្រមព្រៀងនោះមានសុពលភាពនោះទេ។ ភាគីអាចផ្តោះប្តូរឯកសារគ្នាតាមមធ្យោបាយអេឡិចត្រូនិច។ មាត្រា៧ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម សំណើ និងស្ទីការត្រូវបានសន្មតថា បានកើតមាននៅពេលដែលភាគី៖

- ភាគីបានឆ្លងឆ្លើយគ្នា តាមរយៈការផ្ញើលិខិតទៅគ្នាទៅវិញទៅមកហើយទោះបីនៅក្នុងលិខិតឆ្លងឆ្លើយនោះគ្មាន**ហត្ថលេខាចុះរួមគ្នា**ក៏ដោយ តែបើលិខិតឆ្លងឆ្លើយទាំងនោះបញ្ជាក់ឲ្យឃើញថា ភាគីបានព្រមព្រៀងថានឹងដោះស្រាយជម្លោះដោយវេទិកាមជ្ឈត្តការនោះលិខិតឆ្លងឆ្លើយ នោះបង្កើតបានជាកិច្ចព្រមព្រៀងធ្វើមជ្ឈត្តការ។ ឧទាហរណ៍ ភាគីមួយបានសរសេរទៅភាគីមួយទៀតស្នើសុំដោះស្រាយជម្លោះតាមវេទិកាមជ្ឈត្តការ។ រួចហើយភាគីមួយទៀតឆ្លើយខ្លួនមិនយល់ទាស់ទេ។ ដូច្នេះ កិច្ចព្រមព្រៀងមជ្ឈត្តការបានកើតឡើង។
- សារឆ្លងឆ្លើយតាមមធ្យោបាយអេឡិចត្រូនិច ដូចជាអ៊ីមែល ឬ ហ្វាក់ស៊ីមីលី ក៏បង្កើតជាកិច្ចព្រមព្រៀងមជ្ឈត្តការបានដែរ
- ការដែលភាគីមួយបានដាក់ពាក្យទាមទារមួយ ហើយភាគីមួយទៀតនោះបានផ្ញើពាក្យឆ្លើយតបមកវិញ ហើយភាគីមួយបានប្រកាន់ថា មានការព្រមព្រៀងគ្នានៅក្នុងពាក្យទាមទារ ឬពាក្យឆ្លើយតបថានឹងលើករឿងទៅមជ្ឈត្តការ ហើយភាគីមួយទៀតមិនបានប្រកែក។ សូមមើលទំព័រ២៥៖ UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration ដែលអាចទាញយកពី៖

  http://www.uncitral.org/pdf/english/clout/MAL-digest-2012-e.pdf
- កិច្ចសន្យានិយាយយោងទៅឯកសារណាមួយ ដូចជាកិច្ចសន្យាធានារ៉ាប់រងដែលយោងទៅឯកសារដែលចែងពីលក្ខខណ្ឌទូទៅ ហើយក្នុងលក្ខខណ្ឌទូទៅនោះមានចែងពីខមជ្ឈត្តការ។

## ខ. កម្មវត្ថុស្របច្បាប់

ដូចកិច្ចសន្យាដទៃទៀតដែរ ខ មជ្ឈត្តការមិនអាចចែងពី ការដោះស្រាយជម្លោះដែលខុសច្បាប់បានទេ។ ឧទាហរណ៍ ការធ្វើមជ្ឈត្តការលើជម្លោះនៃការបែងចែកទ្រព្យដែលបានមកពីការលួច ឬពុករលួយ។ ចំពោះជម្លោះលើកម្មវត្ថុណាច្បាប់ចែងថាត្រូវតែដោះស្រាយតាមផ្លូវតុលាការ ខមជ្ឈត្តការមិនអាចគ្រប់ដណ្តប់លើកម្មវត្ថុនៃជម្លោះបែបនោះបានទេ។

### គ. ភាគីមានសមត្ថភាពចុះខមជ្ឈត្តការ

ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ភាគីត្រូវតែមានសមត្ថភាពក្នុងការសំដែងឆន្ទៈ(មាត្រា ១៤ និងមាត្រា១៥)។ នេះមានន័យថា ភាគីត្រូវស្ថិតនៅក្នុងស្ថានភាពដែលខ្លួនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីលទ្ធផលផ្លូវច្បាប់នៃការចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀងធ្វើមជ្ឈត្តការ ឬទទួល យកខមជ្ឈត្តការនោះ។

### ឃ. លក្ខខណ្ឌនៃទម្រង់

ដូចមានចែងនៅក្នុងមាត្រា ៧ ខាងលើ ខមជ្ឈត្តការត្រូវតែសរសេរ។ ប៉ុន្តែកិច្ចព្រមព្រៀង មិនចាំបាច់ទាល់តែមានចុះហត្ថលេខាទេ ដូចជាការឆ្លងឆ្លើយដែលបានពោលខាងលើមិនចាំបាច់ មានហត្ថលេខាទេ ជាពិសេសការឆ្លងឆ្លើយតាមមធ្យោបាយអេឡិចត្រូនិច។

### ង. ភាពដាច់ចេញពីកិច្ចសន្យាគោល

ទោះបីកិច្ចសន្យាគោលបានបញ្ចូលនូវខមជ្ឈត្តការ ហើយកិច្ចសន្យាគោលនោះត្រូវ បានវិនិច្ឆ័យ ឬចាត់ថា គ្មានសុពលភាពក៏ដោយ ខ មជ្ឈត្តការនៅតែមានសុពលភាព ឬអាយុ បន្តទៅទៀត ដែលបើកឲ្យមជ្ឈត្តការប្រព្រឹត្តទៅបាន (មាត្រា ២៤ នៃច្បាប់ស្តីពីមជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម)។ នេះជាគោលការណ៍នៃភាពដាច់ដោយឡែកនៃខមជ្ឈត្តការ (Separability of the arbitration clause)។ ឧទាហរណ៍ នៅក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញមួយ ភាគីមជ្ឈត្តការអាច ធ្វើសេចក្តីវិនិច្ឆ័យបន្តទៅទៀតថា តើខមជ្ឈត្តការមាន ឬគ្មានសុពលភាព។

## ៣. យុត្តាធិការ(សមត្ថកិច្ច)នៃមជ្ឈត្តការ

### ៣.១ យុត្តាធិការកំណត់ដោយកិច្ចព្រមព្រៀង

យុត្តាធិការនៃមជ្ឈត្តការគឺជា ទំហំនៃអំណាចដែលវេទិកាមជ្ឈត្តការមួយអាចសម្រេច លើជម្លោះមួយបាន។ យុត្តាធិការនៃមជ្ឈត្តការនេះត្រូវបានកំណត់ដោយខមជ្ឈត្តការ និងច្បាប់។ ខមជ្ឈត្តការកំណត់វិសាលភាពនៃការធ្វើមជ្ឈត្តការ (Scope of arbitration)។ នៅពេលមានជម្លោះ ភាគីតែងបកស្រាយអត្ថបទនៃ ខមជ្ឈត្តការដើម្បីសន្និដ្ឋានថា តើមជ្ឈត្តករមានអំណាចដោះស្រាយ ជម្លោះបានត្រឹមកម្រិតណា។ ឧទាហរណ៍ កាលណាខមជ្ឈត្តការសរសេរថា "វិវាទទាំងឡាយណា ដែលកើតឡើង**នៅក្រោម**កិច្ចសន្យានេះ ត្រូវដោះស្រាយដោយមជ្ឈត្តការ..." (Dispute arising "under" this contract) ដោយសារមានពាក្យ "នៅក្រោម" គេអាចបកស្រាយថា ខមជ្ឈត្តការនោះបើក អំណាចឲ្យមជ្ឈត្តករដោះស្រាយវិវាទទាក់ទងតែនឹងសិទ្ធិ និងកាតព្វកិច្ចដែលភាគីបានបង្កើតនៅ ក្នុងកិច្ចសន្យានោះប៉ុណ្ណោះ។ និយាយម្យ៉ាងទៀត កាលណាវិវាទដែលភាគីណាមួយលើកឡើង

ដែលមិនមែនជាវិវាទទាក់ទងដោយផ្ទាល់នឹងសិទ្ធិ និងកាតព្វកិច្ចដែលចែងក្នុងកិច្ចសន្យានោះទេ មជ្ឈត្តករមិនអាចដោះស្រាយវិវាទនោះបានទេ។ បើមជ្ឈត្តករនៅតែទទូចដោះស្រាយវិវាទនោះ គេចោទថា មជ្ឈត្តការនោះត្រូវបានធ្វើហួសពីអំណាចដែលភាគីបានប្រគល់ឲ្យ។

ឧទាហរណ៍មួយទៀត កាលណាខមជ្ឈត្តការសរសេរថា "វិវាទទាំងឡាយណាដែលកើតឡើងទាក់ទងនឹងកិច្ចសន្យានេះ" (Dispute arising "in connection with" or "in relation to" this contract) នោះមានការបកស្រាយថា វិវាទដែលកើតឡើងមិនត្រឹមតែវិវាទទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ចដែលកិច្ចសន្យាបានបង្កើតប៉ុណ្ណោះទេ តែរួមបញ្ចូលទាំងបញ្ហានានាមុនពេលកើតកិច្ចសន្យានោះទៀតផង (ដូចជាក្នុងតំណាក់ការចរចាជាដើម)។ ឧទាហរណ៍មួយទៀត កាលណាខមជ្ឈត្តការសរសេរថា "វិវាទទាំងឡាយណាដែលកើតចេញពីកិច្ចសន្យានេះ" (Dispute "arising of" or "arising from") នោះគេអាចបកស្រាយថា វិវាទដែលកើតឡើងមិនត្រឹមតែទាក់ទងនឹងការទាមទារតាមកិច្ចសន្យាប៉ុណ្ណោះទេ តែថែមទាំងការទាមទារផ្អែកលើអំពើអនីត្យានុកូល (ជាឧទាហរណ៍)ដែលមានចំណងទាក់ទងជិតស្និទ្ធនឹងការទាមទារក្រោមកិច្ចសន្យាផងដែរ។

ដើម្បីជាឧទាហរណ៍ នៃការបកស្រាយខមជ្ឈត្តការទាក់ទងនឹងអំណាចរបស់វេទិកាមជ្ឈត្តការ សូមពិចារណាលើវិវាទមួយ Fiona Trust v. Privalov (2015)។ អង្គហេតុនៃវិវាទនេះមានដូចខាងក្រោម៖

ជម្លោះមួយបានកើតឡើងរវាងបណ្តុំក្រុមហ៊ុនរុស្ស៊ីឈ្មោះ Sovcomflot ដែលជាម្ចាស់កប៉ាល់ និងក្រុមហ៊ុនបីដែលជាអ្នកជួលកប៉ាល់។ ម្ចាស់កប៉ាល់ និងអ្នកជួលកប៉ាល់បានចុះកិច្ចសន្យាជួលកប៉ាល់ចំនួនប្រាំបីកិច្ចសន្យា។ បន្ទាប់មកមានការចោទប្រកាន់ថា កិច្ចសន្យានោះកើតឡើងដោយសារ ការសូកប៉ាន់អភិបាលក្រុមហ៊ុនជាម្ចាស់កប៉ាល់ដើម្បីទទួលបានខ និងលក្ខខណ្ឌជួលដែលលំអៀង និងផ្តល់ផលប្រយោជន៍ខ្លាំងទៅឲ្យក្រុមហ៊ុនជួល។ ក្នុងកិច្ចសន្យាជួលកប៉ាល់ទាំងអស់មានខចែងពី មជ្ឈត្តការដែលតម្រូវឲ្យភាគីដោះស្រាយជម្លោះ ក្នុងវេទិកាមជ្ឈត្តការក្រុងឡុងប្រទេសអង់គ្លេស។ ដោយសារតែមានភាពមិនប្រក្រតីនៅក្នុងការធ្វើកិច្ចសន្យាទាំងនេះ ទើបក្រុមហ៊ុនជាម្ចាស់កប៉ាល់បានលុបកិច្ចសន្យាទាំងនោះចោល ជាហេតុនាំឲ្យមានជម្លោះនេះកើតឡើង។

កិច្ចសន្យាជួលកប៉ាល់នេះមានខដោះស្រាយជម្លោះមួយដែលចែងថា៖

" [...] (ខ) ជម្លោះដែល**កើតឡើងក្រោម**កិច្ចសន្យាជួលកប៉ាល់នេះត្រូវដោះស្រាយដោយតុលាការជាន់ខ្ពស់ (High Court) នៅទីក្រុងឡុង ដែលភាគីទាំងពីរទទួលស្គាល់យុត្តាធិការតុលាការនេះ...។

(គ) ទោះជាមានសេចក្តីចែងដូចខាងដើមនេះក៏ដោយ ...ភាគីណាមួយអាចជ្រើសរើសយកជម្លោះបែបនោះដាក់ជូន...ឲ្យមជ្ឈត្តការនៅក្រុងឡុងដោះស្រាយ តាមរយៈការជូនដំណឹង

ជាលាយលក្ខណ៍អក្សរអំពីការជ្រើសរើសនោះទៅភាគីម្ខាងទៀត ដោយមជ្ឈត្តករមួយត្រូវជ្រើសរើសដោយម្ចាស់កប៉ាល់ និងមជ្ឈត្តករម្នាក់ទៀតជ្រើសរើសដោយអ្នកជួលកប៉ាល់...។ មជ្ឈត្តការត្រូវធ្វើនៅក្រុងឡុងស្របតាម...។

(១) ភាគីមួយត្រូវបាត់បង់សិទ្ធិធ្វើការជ្រើសរើស[យកមជ្ឈត្តការ] លុះត្រាណាតែៈ (1)ខ្លួនទទួលពីភាគីម្ខាងទៀត នូវសេចក្តីជូនដំណឹងអំពីជម្លោះដែលចែងជាក់ច្បាស់ថាជម្លោះមួយបាន**កើតឡើងចេញពី**កិច្ចសន្យាជួលកប៉ាល់នេះ...៉

ក្រុមហ៊ុនជួលកប៉ាល់បានដាក់ពាក្យប្តឹងនៅមជ្ឈត្តការក្រុងឡុង ដើម្បីដោះស្រាយជម្លោះនេះ ប៉ុន្តែក្រុមហ៊ុនម្ចាស់កប៉ាល់បែរជាដាក់ពាក្យប្តឹងទៅតុលាការអង់គ្លេស ដើម្បីសុំបញ្ឈប់នីតិវិធីមជ្ឈត្តការ ដោយសំអាងថាខ្លួនបានលុបកិច្ចសន្យានោះរួចអស់ហើយ ដោយសារកិច្ចសន្យានោះពាក់ព័ន្ធនឹងការសូកប៉ាន់ ហើយការលុបចោលកិច្ចសន្យាត្រូវបានធ្វើដោយហេតុផលត្រឹមត្រូវ។ ជាការឆ្លើយតប ក្រុមហ៊ុនជួលកប៉ាល់ ដាក់ពាក្យទៅតុលាការដើម្បីសុំបញ្ឈប់នីតិវិធីតុលាការ រួចសុំឲ្យបន្តដំណើរការនីតិវិធីមជ្ឈត្តការ។

តុលាការបដិសេធសំណើសុំរបស់ក្រុមហ៊ុនជួលកប៉ាល់ និងហាមឃាត់ការដំណើរការនីតិវិធីមជ្ឈត្តការ ប៉ុន្តែសេចក្តីសម្រេចនេះត្រូវបានក្រុមហ៊ុនជួលកប៉ាល់ប្តឹងឧទ្ធរណ៍។ តុលាការឧទ្ធរណ៍ប្រានចោលសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមដោយ ផ្អែកលើសំអាងដូចខាងក្រោមនេះ[87]៖

១. ខមជ្ឈត្តការនៅក្នុងកិច្ចសន្យាទាំងនោះមានឃ្លាពីរដែលកំណត់វិសាលភាពនៃជម្លោះដោយម្តងចែងថា ៉ជម្លោះកើតនៅក្រោមកិច្ចសន្យា៉ (disputes arising under this charter) ត្រូវដោះស្រាយដោយ តុលាការជាន់ខ្ពស់នៅក្រុងឡុង និងម្តងទៀតចែងថា ៉ជម្លោះដែលបានកើតចេញពីកិច្ចសន្យា៉ (disputes which have arisen out of this charter)។ ដោយ សារខមជ្ឈត្តការមានរូបមន្តពីរខុសគ្នាដូច្នេះ តើរូបមន្តមួយណាដែលមានអានុភាពធំជាងគេ។

២. តុលាការចោទជាសំណួរថា តើភាគីចង់ឲ្យជម្លោះទាំងអស់ត្រូវដោះស្រាយដោយសាលាតែមួយ ឬក៏ជម្លោះខ្លះដោះស្រាយនៅសាលាមួយ ហើយជម្លោះខ្លះទៀត ដោះស្រាយនៅសាលាផ្សេង?

៣. តុលាការសរុបមកថា ពាណិជ្ជករធម្មតា ប្រហែលជាមិនត្រូវអំពល់ទុក្ខខ្លួនឯងអំពីភាសាជាក់លាក់នៃខមជ្ឈត្តការទេ។ ខមជ្ឈត្តការនៅក្នុងកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិត្រូវតែ

[87] ចំពោះសេចក្តីសម្រេចរបស់តុលាការឧទ្ធរណ៍សូមមើលៈ
http://www.nadr.co.uk/articles/published/ArbitLRe/Fiona%20v%20Privalov%202007.pdf

បកស្រាយឲ្យទូលាយដើម្បីលើកស្ទួយភាពប្រាកដប្រជាផ្នែកគតិយុត្ត (legal certainty) ហើយការបកស្រាយបែបនេះត្រូវបានស្ថិតនៅជាប់ម៉ឺងជាផ្នែកមួយនៃច្បាប់ពាណិជ្ជកម្មអន្តរជាតិ។

## ៣.២ យុត្តាធិការដែលកំណត់ដោយច្បាប់

មានជម្លោះខ្លះអាចដោះស្រាយដោយមជ្ឈត្តការ (Arbitrability of disputes) ប៉ុន្តែមានរឿងខ្លះទៀតដែល ច្បាប់ហាមឃាត់មិនឲ្យដោះស្រាយដោយមជ្ឈត្តការ។ មាត្រា១ កថាខណ្ឌទី២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា៖

> ច្បាប់នេះមិនប៉ះពាល់ដល់អានុភាពគតិយុត្ត នៃច្បាប់នានាឯទៀតរបស់ព្រះរាជាណាចក្រកម្ពុជាដែលនៅក្នុងនោះ ករណីវិវាទខ្លះផ្សះផ្សា [ធ្វើមជ្ឈត្តការ]បាន ឬដោះស្រាយបានតាមនីតិវិធីផ្សេងៗទៀត និងវិវាទខ្លះទៀតផ្សះផ្សា [ធ្វើមជ្ឈត្តការ] មិនបាន។

ឧទាហរណ៍ ភាគីពីរបានចុះកិច្ចសន្យាលក់ទិញអចលនទ្រព្យ។ កិច្ចសន្យានេះបានចែងថា ជម្លោះដែលកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះត្រូវដោះស្រាយដោយ មជ្ឈត្តការ។ បន្ទាប់ពីចុះកិច្ចសន្យារួចហើយ ភាគីទិញបានបង់ប្រាក់ថ្លៃទិញចំនួន ២០% នៃថ្លៃលក់។ នៅពេលចាប់ផ្តើមផ្ទេរអចលនទ្រព្យស្រាប់តែមានភាគីទីបី ទាមទារកម្មសិទ្ធិលើអចលទ្រព្យនោះដែរ ជាហេតុឲ្យការផ្ទេរកម្មសិទ្ធិចោទជាបញ្ហា។ សំណួរសួរថា តើវេទិកាមជ្ឈត្តការមានសមត្ថកិច្ចដោះស្រាយលើវិវាទនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុបានដែរឬទេ?។ ជាវិធានទូទៅនៃក្រមនីតិវិធីរដ្ឋប្បវេណី រឿងក្តីរដ្ឋប្បវេណីត្រូវអនុវត្តតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី លើកលែងតែមានច្បាប់ពិសេសកំណត់ផ្សេង។ មាត្រា ១ នៃក្រមនីតិវិធីរដ្ឋប្បវេណីចែងថា៖

> នីតិវិធីដែលទាក់ទងទៅនឹងបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើតាមបញ្ញត្តិនៃក្រមនេះ លើកលែងតែក្នុងករណីដែលច្បាប់ផ្សេងបានកំណត់ពិសេស។

លើសពីនេះទៀត ក្រមនីតិវិធីរដ្ឋប្បវេណីនេះ បានចែងជាគោលការណ៍ទូទៅថា បណ្តឹងរដ្ឋប្បវេណីត្រូវដោះស្រាយដោយតុលាការ។ មាត្រា ២ ចែងថា៖

> ១. បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឲ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។
>
> ២. ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី។

ដោយផ្អែកលើមាត្រាទាំងពីរ គេហាក់ដូចជាឃើញថា វិវាទលើបញ្ហាកម្មសិទ្ធិនេះមិនអាចដោះស្រាយដោយមជ្ឈត្តការបានទេ។ ជាងនេះទៀត មាត្រា១នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអនុញ្ញាតឲ្យវេទិកាមជ្ឈត្តការមានសមត្ថកិច្ចលើរឿង "ពាណិជ្ជកម្ម" ប៉ុណ្ណោះ ហើយមាត្រា ២.ឈ កំណត់និយមន័យនៃពាក្យ "**ពាណិជ្ជកម្ម**" ថាជា៖

> ...ធុរកិច្ច[transactions]ដែលមានប្រភេទជាពាណិជ្ជកម្ម ទោះបីជាមានកិច្ចសន្យាក្តី ឬគ្មានកិច្ចសន្យាក៏ដោយ។ ធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្ម មានជាអាទិ៍៖ កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬការផ្លាស់ប្តូរទំនិញ ឬសេវាផ្សេងៗ, កិច្ចព្រមព្រៀងនៃការចែកចាយ,តំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម, ការទិញ-លក់គណនីក្រុមហ៊ុន, ការជួលទីតាំង ឬសម្ភារៈវត្ថុ, ការងារស្ថាបនា, ការពិគ្រោះយោបល់វិស្វកម្ម, ការចេញអាជ្ញាប័ណ្ណ, ការវិនិយោគទុន,ការផ្តល់ហិរញ្ញវត្ថុ, ការធ្វើអាជីវកម្មធនាគារ, ការធានារ៉ាប់រង, កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទានក្រុមហ៊ុនចម្រុះ និងប្រភេទផ្សេងទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរ តាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក។

នៅក្នុងករណីសម្មតិកម្មខាងលើ ធុរកិច្ចរវាងអ្នកទិញ និងអ្នកលក់ដីគឺ ជាធុរកិច្ចធម្មតាដែលមិនមានលក្ខណៈជាពាណិជ្ជកម្ម ហើយអ្នកទាំងពីរមិនមែនជាពាណិជ្ជករទៀតផង។

តែទោះជាយ៉ាងណាក្តីមាត្រា២.ឈ ខាងលើទាមទារឲ្យមាន**ការបកស្រាយទូលំទូលាយ**ចំពោះពាក្យ "ពាណិជ្ជកម្ម"។ បើសិនជាបញ្ជីសកម្មភាពដែលរៀបរាប់ខាងលើមិនអាចគ្របដណ្តប់លើប្រតិបត្តិការខ្លះ តើគេអាចពឹងផ្អែកលើនិយមន័យនៃពាក្យ "ពាណិជ្ជកិច្ច" ដែលមានចែងនៅក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មបានដែរឬទេ?។ មាត្រា១ នៃច្បាប់នេះចែងថា៖

> ពាណិជ្ជកិច្ចជាសកម្មភាព ទិញលក់ទំនិញ ឬ សេវាដែលត្រូវបានអនុវត្តជាប្រចាំក្នុងគោលដៅធ្វើការដោះដូរនិងស្វែងរកចំណេញ។

មាត្រា២ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មលំអិតបន្ថែមអំពីសកម្មភាពជាទម្លាប់ខ្លះ (មិនមែនធ្វើម្តងម្កាល) ដែលចាត់ទុកថាជាពាណិជ្ជកិច្ចគឺ៖

- ការទិញដើម្បីលក់ទៅវិញ រួមទាំងការ**ទិញលក់អចលនវត្ថុ**
- សកម្មភាពនៃសហគ្រាសជួល[88], សហគ្រាសការណកម្ម[89], សហគ្រាសយកកម្រៃជើងសារ, សហគ្រាសដឹកជញ្ជូន, សហគ្រាសបោះពុម្ពផ្សាយ, និង សេវាដទៃទៀត
- ប្រតិបត្តិការនៃធនាគារប្តូររូបិយវត្ថុ
- ការផ្តល់សេវាអន្តរការ, សេវាទីភ្នាក់ងារ, ការិយាល័យសម្របសម្រួលកិច្ចការសេវាវប្បធម៌ និងការចាត់ចែងនូវទស្សនីយភាពជាសាធារណៈ
- ប្រតិបត្តិការនៃសហគ្រាសសំណង់, ការទិញឬការជួលកប៉ាល់ដឹកជញ្ជូនក្នុងប្រទេស ឬក្រៅប្រទេស, ការដឹកជញ្ជូននិងការផ្ញើបញ្ជូនតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស
- ការធានារ៉ាប់រងគ្រប់ប្រភេទ
- អាជីវកម្មនេសាទ, អាជីវកម្មព្រៃឈើនិងរ៉ែ។

មួយវិញទៀត ក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតឲ្យភាគីជ្រើសរើសយកតុលាការដែលមានសមត្ថកិច្ចដើម្បីវិនិច្ឆ័យបណ្តឹងរបស់ខ្លួន ប៉ុន្តែលុះត្រាណាវិវាទនោះជាវិវាទរវាងពាណិជ្ជករ និងពាណិជ្ជករ/នីតិបុគ្គល នៅក្នុងការជំនុំជម្រះក្តីលើកទី១។ មាត្រា១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីចែងថា៖

> ១.ការព្រមព្រៀងដែលកំណត់តុលាការ ដែលមានសមត្ថកិច្ចជម្រះក្តី នឹងមានអានុភាព លុះត្រាតែការព្រមព្រៀងនោះ ត្រូវបានធ្វើឡើងរវាងពាណិជ្ជករ និងពាណិជ្ជករ ឬនីតិបុគ្គលនិងនីតិបុគ្គល ឬពាណិជ្ជករនិងនីតិបុគ្គល ចំពោះតែការជំនុំជម្រះក្តីលើកទី ១។
>
> ២. ការព្រមព្រៀងដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ នឹងមានអានុភាព លុះត្រាតែការព្រមព្រៀងនោះត្រូវបានធ្វើឡើងចំពោះបណ្តឹងដែលផ្អែកលើទំនាក់ទំនងគតិយុត្តដែលបានកំណត់ ហើយត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ។

មាត្រានេះមានអត្ថន័យស្រដៀងគ្នានឹង មាត្រា ១ និង២.ឈ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែរ។ ប៉ុន្តែមានពាក្យមួយដែលគួរឲ្យកត់សំគាល់គឺ "តុលាការដែលមានសមត្ថកិច្ច"។ តើតុលាការមានសមត្ថកិច្ចនេះសំដៅដល់ "សាលាជម្រះក្តី" ទូទៅ ដែលរួមទាំង

[88] ជាការជួលសហគ្រាសមួយដើម្បីយកមកចាត់ការ និងធ្វើអាជីវកម្មលើសហគ្រាសនោះ ដើម្បីបានចំណេញ រួចឲ្យប្រាក់ឈ្នួលជាថ្នូរនឹងការជួលនោះ។ ឧទាហរណ៍ ការជួលសណ្ឋាគារពីម្ចាស់ រួចយកមកចាត់ចែងទទួលភ្ញៀវខ្លួនឯង។ នេះជាសហគ្រាសជួល។

[89] ជាសហគ្រាសកម្មន្តសាល ដូចជាសហគ្រាសផលិតស្បែកជើងផ្ទាត់ កៅស៊ូកង់ឡាន។ល។

វេទិកាមជ្ឈត្តការដែរ ឬទេ?។ មាត្រា៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឲ្យនិយមន័យនៃពាក្យ "តុលាការមានសមត្ថកិច្ច" ថាជា "តុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្ដឹង វិនិច្ឆ័យលើរឿងក្ដី ហើយអាចចេញសាលក្រម ឬសាលដីកាបាន"។ នៅក្នុងសេចក្ដីអធិប្បាយនៃមាត្រានេះ តុលាការដែលមានសមត្ថកិច្ច គឺសាលាជម្រះក្ដីដែលមានសមត្ថកិច្ច។ ដូច្នេះ មាត្រា១៣ ចែងថា ការកំណត់សមត្ថកិច្ចរបស់សាលាជម្រះក្ដីអាចធ្វើបានលុះត្រាតែ ភាគីជាពាណិជ្ជករ ឬជាពាណិជ្ជករ និងនីតិបុគ្គល។ អាស្រ័យហេតុនេះ យោងតាមមាត្រា១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគីក្នុងករណីជាសម្មតិកម្មខាងលើ មិនអាចដាក់ពាក្យបណ្ដឹងនៅវេទិកាមជ្ឈត្តការបានទេ។

រឿងមួយទៀតដែលស្មុគ្រស្មាញចំពោះករណីនេះ គឺភាគីទីបី ដែលមិនមែនជាភាគីនៃខមជ្ឈត្តការ។ ដូចបានពោលខាងដើម មជ្ឈត្តការគឺ ជាវេទិកាយុត្តិធម៌ដែលមានការព្រមព្រៀង។ ដោយសារ ភាគីទីបីមិនមែនជាភាគីនៃខមជ្ឈត្តការ វេទិកាមជ្ឈត្តការមិនអាចបង្ខំឲ្យភាគីនោះមកឆ្លើយនៅក្នុងនីតិវិធីរបស់ខ្លួនបានឡើយ។

កម្មវត្ថុនៃជម្លោះណាដែលមិនអាចយកមកដោះស្រាយតាមវេទិកាមជ្ឈត្តការ គឺជាមូលដ្ឋានសម្រាប់ឲ្យភាគីណាមួយស្នើសុំតុលាការកុំឲ្យទទួលស្គាល់មជ្ឈត្តវិនិច្ឆ័យបាន(មាត្រា៤៤ខ.ខ-១ នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម)។

## ៣.៣ ការកំណត់យុត្តាធិការនៃមជ្ឈត្តការ

នៅពេលដែលភាគីណាមួយបានដាក់សេចក្ដីជូនដំណឹងពីមជ្ឈត្តការ (Notice of arbitration) ឬពាក្យទាមទារ (Statement of claim) ភាគីម្ខាងទៀតអាចធ្វើការជំទាស់ចំពោះយុត្តាធិការនៃមជ្ឈត្តការ (Jurisdictional challenge) បើសិនគេយល់ថាខមជ្ឈត្តការមិនបានអនុញ្ញាតឲ្យមានការធ្វើមជ្ឈត្តកម្មលើកម្មវត្ថុនៃជម្លោះនោះ។ តែទោះជាយ៉ាងណាក្ដី ការជំទាស់នឹងយុត្តាធិការនេះ ត្រូវធ្វើឡើងនៅមុនពេល ដែលភាគីនោះ ដាក់ពាក្យការពារ (Statement of defense) របស់ខ្លួន បើពុំនោះទេ ភាគីនោះត្រូវបានសន្មតថាទទួលស្គាល់យុត្តាធិការរបស់មជ្ឈត្តការ។

ដូចបានពិពណ៌នាខាងលើ កិច្ចសន្យាភាគច្រើនបានបញ្ចូលខមជ្ឈត្តការជាផ្នែកមួយនៃកិច្ចសន្យាគោល។ ភាគីដែលជំទាស់យុត្តាធិការ មិនអាចលើកយកអសុពលភាពនៃកិច្ចសន្យាដើម្បីទាញយកលទ្ធផល (Imply) ថាខមជ្ឈត្តការក៏បាត់បង់សុពលភាពជាមួយកិច្ចសន្យាគោលដែរនោះទេ (មាត្រា ២៤.១ ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម)។ ដោយសារខមជ្ឈត្តការត្រូវបានការពារដោយច្បាប់ មជ្ឈត្តការអាចបន្តធ្វើមជ្ឈត្តការបាន និងមានអំណាចសម្រេចពីយុត្តាធិការនៃវេទិកាមជ្ឈត្តការលើជម្លោះដែលដាក់ជូនមជ្ឈត្តការធ្វើសេចក្ដីសម្រេច។

មជ្ឈត្តការអាចធ្វើសេចក្ដីសម្រេចថាខ្លួនមានយុត្តាធិការលើជម្លោះនោះបាន ឬមិនបាន។ សេចក្ដីសម្រេចពីយុត្តាធិការនេះ អាចធ្វើឡើងនៅពេលនីតិវិធីត្រៀមក៏បាន (មានន័យថានីតិវិធី

មុនការធ្វើសវនាការ) ដោយចាត់ទុកជាការសម្រេចលើបញ្ហាដំបូង (Preliminary question) ឬនៅពេលចេញសេចក្តីបង្គាប់ក៏បាន (មាត្រា ២៤.៣ច្បាប់ស្តីពី មជ្ឈត្តកការផ្នែកពាណិជ្ជកម្ម) ។

ភាគីដែលជំទាស់នឹងសេចក្តីសម្រេចរបស់មជ្ឈត្តករថាមានយុត្តាធិការនេះ អាចប្តឹងទៅតុលាការពាណិជ្ជកម្ម/ឧទ្ធរណ៍/កំពូល) (មាត្រា ២៤(៣)) ដើម្បីសម្រេចជាចុងក្រោយ។

ការសម្រេចពីយុត្តាធិការនេះជារឿងសំខាន់ ព្រោះមជ្ឈត្តការដែលប្រព្រឹត្តទៅដោយគ្មានយុត្តាធិការគឺជា មូលដ្ឋានមួយដែលបើកឲ្យតុលាការច្រានចោលមជ្ឈត្តវិនិច្ឆ័យ(មាត្រា ៤៤.ក.ក-៣)។

## ៤.ច្បាប់គ្រប់គ្រងជម្លោះ

**មាត្រា ៣៦** នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា ភាគីមានសេរីភាពក្នុងការជ្រើសរើសយក**វិធានច្បាប់**ណាមួយក៏បាន ដើម្បីអនុវត្តទៅលើអង្គសេចក្តីនៃជម្លោះរបស់គេ។ នេះជាវិធានច្បាប់សារធាតុនៃយុត្តាធិការណាមួយនៅក្នុងពិភពលោកនេះ។ ឧទាហរណ៍ ភាគីពីរនៃកិច្ចសន្យា ដែលមានសញ្ជាតិខ្មែរ និង ថៃ អាចជ្រើសរើសយកច្បាប់ប្រទេសខ្មែរ ថៃ ឬសិង្ហបូរី ដើម្បីយកមកអនុវត្តលើជម្លោះរបស់គេ ដោយចែងជម្រើសនេះនៅក្នុងខមជ្ឈត្តការ។ មិនត្រឹមតែវិធាននៃច្បាប់ជាតិប៉ុណ្ណោះទេ ភាគីអាចជ្រើសរើសយកវិធាននៃច្បាប់អន្តរជាតិបានផងដែរ ដូចជាអនុសញ្ញានៃអង្គការសហប្រជាជាតិស្តីពីការទិញលក់ទំនិញជាអន្តរជាតិ (United Nations Convention on Contracts for the International Sale of Goods--CISG) ជាដើម។

ប៉ុន្តែ មានពេលខ្លះ ភាគីមិនបានចែងបញ្ជាក់ពីវិធានច្បាប់នៅក្នុងខមជ្ឈត្តការទេ។ ក្នុងករណីបែបនេះ មជ្ឈត្តករគឺជាអ្នកសម្រេច ថាតើវិធានច្បាប់ណាមួយដែលសមស្របជាងគេនៅក្នុងជម្លោះនេះ។ នៅក្នុងសេចក្តីពន្យល់លើមាត្រា ២៨ នៃ UNCITRAL Model Law on International Commercial Arbitration មជ្ឈត្តការត្រូវអនុវត្តច្បាប់ជាតិដែលកំណត់ពីវិធាន នៃច្បាប់ទំនាស់គ្នា (Conflict-of-law rules)។

មជ្ឈត្តការអាចសម្រេចរឿងក្តីបានតាមគោលការណ៍ណាមួយ ដែលមជ្ឈត្តករយុត្តិធម៌ដោយមិនបាច់យោងទៅលើអង្គច្បាប់ណាមួយ (ex aequo et bona or amicable compositeur) បើសិនជាភាគីអនុញ្ញាតយ៉ាងច្បាស់ៗនៅក្នុងខមជ្ឈត្តការឲ្យមជ្ឈត្តករសម្រេច តាមគោល-ការណ៍នោះ។ មានន័យថាជាគោលការណ៍ដែលឈរលើយុត្តិធម៌ និងសមរម្យដែលស្រមតាមសមធម៌និងមនសិកាល្អ។

## ៥. វិធានគ្រប់គ្រងនីតិវិធីមជ្ឈត្តការ

មាត្រា២៧ នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា ភាគីមានសេរីភាពដើម្បីជ្រើសរើសយកវិធាន នៃនីតិវិធីដើម្បីដំណើរការមជ្ឈត្តការ។ ដូចគ្នានឹងការជ្រើសរើសច្បាប់សារធាតុ

ដើម្បីអនុវត្តទៅលើជម្លោះរបស់គេដែរ កាលបើភាគីមិនបានជ្រើសរើសនៅក្នុងខមជ្ឈត្តការ ហើយមិនព្រមព្រៀងលើវិធាននីតិវិធីណាមួយនោះ នោះមជ្ឈត្តករជាអ្នកជ្រើសរើសយកវិធានណាមួយដែលគេចាត់ទុកថាសមស្របចំពោះរឿងក្តីនៅចំពោះមុខ ឧទាហរណ៍ វិធានស្តីពីការទទួលយកបាននៃភស្តុតាង (admissibility) ភាពទាក់ទងនៃភស្តុតាង (relevance), ភាពសំខាន់នៃ ភស្តុតាង (materiality), និងទម្ងន់នៃភស្តុតាង (weight)។ វិធាននីតិវិធីមិនចាំបាច់ជាវិធានដែលចែងនៅក្នុងច្បាប់រដ្ឋ/អន្តរជាតិនោះទេ តែអាចជាវិធាននៃស្ថាប័នឯកជនណាមួយក៏បាន ដូចជាវិធាននៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មជាដើម។

## ៦. អាសនៈនៃមជ្ឈត្តការ

អាសនៈនៃមជ្ឈត្តការ (seat or *locus arbitri*) ជាធាតុមួយដ៏សំខាន់នៃមជ្ឈត្តការ ព្រោះវាកំណត់ពីច្បាប់ស្តីពីមជ្ឈត្តការដែលអនុវត្តមកលើជម្លោះនៅចំពោះមុខ និងតុលាការដែលមានសមត្ថកិច្ចលើការប្រានចោលមជ្ឈត្តវិនិច្ឆ័យ ឬរឿងផ្សេងទៀតដែលច្បាប់មជ្ឈត្តការកំណត់(ដូចជាការជំទាស់មជ្ឈត្តករជាដើម)។ ឧទាហរណ៍ បើប្រទេសកម្ពុជាជាអាសនៈនៃមជ្ឈត្តការ នោះច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជានឹងអនុវត្តលើការដំណើរការមជ្ឈត្តការ និងអំណាចរបស់តុលាការកម្ពុជាក្នុងការប្រានចោលមជ្ឈត្តវិនិច្ឆ័យ។

ទោះជាយ៉ាងណាក៏ដោយ គេមិនត្រូវច្រឡំរវាងអាសនៈមជ្ឈត្តការ ជាមួយនឹងទីកន្លែងធ្វើមជ្ឈត្តការទេ (venue of arbitration) ។ ទីកន្លែងធ្វើមជ្ឈត្តការគ្មានអានុភាពគតិយុត្តលើមជ្ឈត្តវិនិច្ឆ័យឡើយ។ ទីកន្លែងនោះគ្រាន់ជាកន្លែងសម្រាប់សម្រួលដល់ នីតិវិធីមជ្ឈត្តការប៉ុណ្ណោះ ដូចជាការយកកន្លែងមួយនៅក្នុងប្រទេសដែលមិនមែនជាអាសនៈមជ្ឈត្តការ (មាត្រា ២៨ កថាខណ្ឌ ២)។

ប៉ុន្តែ មានពេលខ្លះភាគីនៃកិច្ចសន្យាមិនបានបញ្ជាក់ពីអាសនៈនៃមជ្ឈត្តការ ក្នុងករណីនេះវេទិកាមជ្ឈត្តការជាអ្នកសម្រេច ដោយពិចារណាទោះលើកាលៈទេសៈនៃជម្លោះ រួមទាំងភាពងាយស្រួលនៃភាគី (Convenience)។ យោងតាមសេចក្តីពន្យល់លើមាត្រា ២០ នៃ UNCITRAL Model Law on International Commercial Arbitration ការពិចារណាលើកាលៈទេសៈនេះសំដៅដល់ការដែលវេទិកាមជ្ឈត្តការធានាដល់ការប្រព្រឹត្តដោយ ស្មើភាពគ្នាចំពោះភាគី (equal treatment of the parties) និងធ្វើឲ្យមានសេចក្តីសម្រេចដោយ យុត្តិធម៌សមរម្យ (fair decision)។ ម្យ៉ាងទៀត ដែលហៅថា "ពិចារណាដល់កាលៈទេសៈនៃជម្លោះមានន័យថា វេទិកាត្រូវគិតដល់ការជាប់ទាក់ទង (១) របស់ភាគីជាមួយប្រទេសមួយ (២) ការទាក់ទងនៃជម្លោះនោះទៅនឹងប្រទេសមួយ (៣) ការជាប់ទាក់ទងនៃនីតិវិធីមជ្ឈត្តការជាមួយប្រទេសមួយ (៤) កន្លែងធ្វើសវនាការ (៥) ការជាប់ទាក់ទង នៃមជ្ឈត្តវិនិច្ឆ័យជាមួយប្រទេសមួយ។

ច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្មខ្មែរ មាត្រា ២.ជ.២កំណត់ថា ទីកន្លែងដែលកាតព្វកិច្ចមួយចំណែកធំនៃទំនាក់ទំនងពាណិជ្ជកម្មដែលត្រូវអនុវត្តគឺ ជាអាសនៈនៃមជ្ឈត្តការ ឬបើពុំនោះទេ អាសនៈគឺ ទីកន្លែង នៃប្រទេសមួយដែលមានចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងកម្មវត្ថុនៃជម្លោះនោះ។

## ៧. ភាសា

ភាគីអាចជ្រើសរើសភាសាណាមកប្រើក៏បាន ប៉ុន្តែបើភាគីមិនចែង ហើយមិនព្រមព្រៀងគ្នាពីភាសាដែលត្រូវប្រើប្រាស់ក្នុងនីតិវិធីមជ្ឈត្តការទេនោះ នោះវេទិកាមជ្ឈត្តការជាអ្នកសម្រេចពីភាសាដែលសមស្របជាមួយនឹងជម្លោះនោះ។

## ៨. ការតែងតាំងមជ្ឈត្តករ

ខមជ្ឈត្តការអាចចែងឲ្យរួចស្រេចពីរបៀបតែងតាំងមជ្ឈត្តករ ដើម្បីចៀសវាងទំនាស់លើការតែងតាំងនេះ នៅពេលជម្លោះមកដល់។ ភាគីមានសេរីភាពក្នុងការតែងតាំងមជ្ឈត្តករ ប៉ុន្តែចំនួនមជ្ឈត្តករត្រូវជាចំនួនសេស។ បើភាគីមិនបានបញ្ជាក់ពីចំនួនមជ្ឈត្តករនៅក្នុងខមជ្ឈត្តការទេនោះច្បាប់កំណត់ថាចំនួនមជ្ឈត្តករត្រូវមានបីរូប (មាត្រា១៨ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម)។

ភាគីអាចមានការស្នុំគ្រស្នាញ ដើម្បីរកចំណុចព្រមព្រៀងលើការតែងតាំងមជ្ឈត្តករជាពិសេស នៅក្នុងមជ្ឈត្តការដែលមានមជ្ឈត្តករមួយរូប។ ដូចនេះ ភាគីអាចព្រមព្រៀងគ្នាចែងពីនីតិវិធីសម្រាប់គ្រប់គ្រងការតែងតាំងមជ្ឈត្តករ។ បើគ្មានការព្រមព្រៀងនេះទេ ច្បាប់ជាអ្នកកំណត់ពីនីតិវិធីនៃការតែងតាំង។ នៅក្នុងមជ្ឈត្តការដែលមានមជ្ឈត្តករបីរូប ភាគីម្នាក់ៗត្រូវជ្រើសតាំងមជ្ឈត្តកររៀងខ្លួន។ បន្ទាប់មកមជ្ឈត្តករទាំងពីរតែងតាំងមជ្ឈត្តករទីបី។

តុលាការនឹងចូលអន្តរាគមក្នុងការតែងតាំងមជ្ឈត្តករកាលណា៖

១.ក្នុងករណីមជ្ឈត្តការដែលមានមជ្ឈត្តករមួយរូប ភាគីមិនព្រមព្រៀងគ្នា ហើយភាគីមួយសុំឲ្យតុលាការតែងតាំងជំនួស។

២.ក្នុងករណីមជ្ឈត្តការដែលមានមជ្ឈត្តករបីរូប មជ្ឈត្តករទាំងពីរដែលតែងតាំងដោយភាគី មិនព្រមព្រៀងគ្នាក្នុងការតែងតាំងមជ្ឈត្តករទីបីក្នុងរយៈពេល ៣០ ថ្ងៃ ហើយភាគីមួយសុំឲ្យតុលាការតែងតាំងជំនួស

៣. ក្នុងករណីមជ្ឈត្តការដែលមានមជ្ឈត្តករបីរូប ភាគីណាមួយមិនបានតែងតាំងមជ្ឈត្តកររបស់ខ្លួនក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីថ្ងៃទទួលសំណើឲ្យតែងតាំងពីភាគីមួយទៀត ភាគីមួយទៀតនោះសុំឲ្យតុលាការតែងតាំងជំនួស។

# ចំណុចវិវាទដែលអាចសម្រេចសេចក្ដីបានដោយវេទិកា មជ្ឈត្តការពាណិជ្ជកម្មកម្ពុជា

ដោយមេធាវី គឹម សាន*

## ១.សេចក្ដីផ្ដើម

ទោះបីជាច្បាប់ស្ដីពី មជ្ឈត្តការពាណិជ្ជកម្មរបស់កម្ពុជា មានសុពលភាពអនុវត្តជាង ១០ឆ្នាំហើយក៏ដោយ ក៏ពាណិជ្ជករ ឬអ្នកធ្វើពាណិជ្ជកម្មតិចតួចណាស់ដែលស្គាល់ពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មច្បាស់។ ជាឧទាហរណ៍ សាធារណជនទូទៅគិតថា វេទិកាមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្មងាយនឹងច្រឡំបំផុត ជាមួយក្រុមប្រឹក្សាអាជ្ញាកណ្ដាលដោះស្រាយវិវាទការងារ។ ដែលវេទិកាពីរនេះមានចារិកខុសគ្នាត្រង់ វេទិកាមជ្ឈត្តការពាណិជ្ជកម្មដោះស្រាយតែរឿងពាណិជ្ជកម្ម តែវេទិកាមជ្ឈត្តការការងារដោះស្រាយតែរឿងការងារ។ ទោះបីយ៉ាងណាក៏ដោយ រឿងដែលវេទិកាមជ្ឈត្តការផ្នែកពាណិជ្ជកម្មអាចសម្រេចបាន តាមច្បាប់កម្ពុជាមិនមានរាប់បញ្ចូលរឿងដទៃទៀត ក្រៅពីពាណិជ្ជកម្មឡើយ ហើយចំណុចវិវាទត្រូវតែជារឿងពាណិជ្ជកម្ម។ ដូច្នេះនៅក្នុងអត្ថបទនេះយើងនឹងពិភាក្សាស៊ីជម្រៅពីពាក្យ "ពាណិជ្ជកម្ម" ដែលមាត្រា២(ឈ) នៃច្បាប់ស្ដីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម កម្ពុជាបានចែង។

## ២. សញ្ញាណទូទៅ នៃពាក្យ "ពាណិជ្ជកម្ម"

ការសម្រេចលើ ចំណុចវិវាទដែលមិនអាចធ្វើមជ្ឈត្តការបាន នឹងធ្វើឲ្យមានការជំទាស់ពីសំណាក់តុលាការសាលាឧទ្ធរណ៍ និងតុលាការកំពូលនៅតំណាក់កាលអនុវត្ត។[90] ការកំណត់ថាតើចំណុចវិវាទណាមួយ អាចសម្រេចដោយវេទិកាមជ្ឈត្តកម្មបានឬទេ មានទំនាក់ទំនងផ្ទាល់នឹងពេលអនុវត្តសេចក្ដីសម្រេចនោះនៅយុត្តាធិការ ដែលភាគីឈ្នះស្នើសុំឲ្យអនុវត្តសេចក្ដីសម្រេច។ ដូច្នេះ ចំណុចវិវាទដែលជារឿង "ពាណិជ្ជកម្ម" គឺអាស្រ័យលើ ១) តើវិវាទនោះមាន

* លោកមេធាវី **គឹម សាន** បានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់សេដ្ឋកិច្ចអន្តរជាតិ ពីសកលវិទ្យាល័យ Victoria University of Wellington (VUW) ប្រទេសណូវ៉ែលហ្សេឡង់។ បច្ចុប្បន្នលោកក៏ជាបេក្ខជន មជ្ឈត្តករពាណិជ្ជកម្ម នៃមជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.) និងជាមន្ត្រីផ្ដល់យោបល់ផ្នែកច្បាប់លើកិច្ចការរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ លោកធ្លាប់ជាអ្នកផ្ដល់យោបល់ច្បាប់ ដល់គម្រោងច្បាប់ប្រឆាំងការជួញដូរកុមារ អ្នកផ្ដល់យោបល់ច្បាប់ផ្នែកបទបញ្ញត្តិពាណិជ្ជកម្មរបស់ក្រុមហ៊ុន Development Alternatives Inc. អ្នកផ្ដល់យោបល់ច្បាប់ពាណិជ្ជកម្មក្នុងក្រុមមេធាវី (ខេមលីហ្គល អាស៊ី Camlegal Asia)។។

[90] មាត្រា ៤៤.២.ខ នៃច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានអនុម័ត នៅថ្ងៃទី ៦ ខែមីនា ឆ្នាំ២០០៦

ចែងថាជាវិវាទពាណិជ្ជកម្ម អនុលោមតាមសន្ធិសញ្ញាអន្តរជាតិ ប្រើសម្រាប់អនុវត្តសេចក្តីសម្រេចមជ្ឈត្តការឬទេ? និង ២) តើវិវាទមានចែងនៅក្នុងច្បាប់ជាតិណាមួយថាមិនអាចធ្វើមជ្ឈត្តការបានឬទេ (មិនថាច្បាប់ជាតិនៅប្រទេសដែលវេទិកាមជ្ឈត្តកម្មប្រព្រឹត្តទៅ ឬនៅប្រទេស នៃកន្លែងអនុវត្តសេចក្តីសម្រេចទេ)?[91]

ប្រទេសកម្ពុជាជាហត្ថលេខី នៃសន្ធិសញ្ញាទីក្រុង ញូយ៉ក (New York) ស្តីពីការទទួលស្គាល់ និងការអនុវត្តសេចក្តីសម្រេចមជ្ឈត្តការបរទេស នាឆ្នាំ១៩៦០។[92] យើងសង្កេតឃើញថា មាត្រា១ កថាខណ្ឌ១ នៃសន្ធិសញ្ញានេះ តម្រូវឲ្យមានការបកស្រាយទំនាស់នោះយ៉ាងទូលំទូលាយ "ទំនាស់កើតចេញពី ការខ្វែងគំនិតគ្នារវាងបុគ្គលច្រើននាក់ មិនថាមានលក្ខណៈជារូបវន្ត ឬមានលក្ខណៈច្បាប់ឡើយ"។ មាត្រា ២ (ឈ) នៃច្បាប់មជ្ឈត្តការកម្ពុជា ឆ្នាំ២០០៦ មានចែងពីភាពទូលាយនៃចំណុចវិវាទដែរ ប៉ុន្តែដោយណែនាំពាក្យ"ពាណិជ្ជកម្ម" ដោយតម្រូវឲ្យមានការបកស្រាយពាក្យ "ពាណិជ្ជកម្ម" "ឲ្យបានទូលំទូលាយ ដើម្បីគ្របដណ្តប់ប្រភេទធុរកិច្ចដែលមានប្រភេទជា "ពាណិជ្ជកម្ម" ទោះបីជាមានកិច្ចសន្យា ឬគ្មានកិច្ចសន្យាក៏ដោយ"។ មាត្រា ១ កថាខណ្ឌ ៣ នៃសន្ធិសញ្ញានេះអនុញ្ញាតឲ្យប្រទេសសមាជិកហត្ថលេខីប្រើប្រាស់ ន័យ "ពាណិជ្ជកម្ម" ដែលជាពាក្យមួយសង្កត់ន័យដែលមានលក្ខណៈចង្អៀត និងច្បាស់លាស់ ជាងកថាខណ្ឌ១ខាងលើ ជាមួយប្រទេសណាមួយដែលខ្លួនព្រមព្រៀងជាមួយនៅពេលអនុវត្តសេចក្តីសម្រេចផ្អែកលើគោលការណ៍បំពេញឲ្យគ្នាទៅវិញទៅមក (Principle of Reciprocity) ។ ទោះបីមានការអនុញ្ញាតបែបនេះក៏ដោយ មានប្រទេសតិចតួច (ប្រហែល ៤៤) ប៉ុណ្ណោះដែលបានប្រើគោលការណ៍នេះ។[93] ប្រទេសកម្ពុជាមិនស្ថិតក្នុងចំណោមប្រទេសនៃការប្រើនិយមន័យបែបចង្អៀតនោះទេ ប៉ុន្តែបានប្រើការពន្យល់ពាក្យ "ពាណិជ្ជកម្ម" តាមការវាស់វែង ដែលមានចែងក្នុងច្បាប់គម្រូ ដូចមានលើកឡើងខាងលើ។

ដោយឡែក ច្បាប់ស្តីពីរមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ ដែលជាច្បាប់មួយយកគម្រូស្ទើរតែទាំងស្រុងពីច្បាប់គម្រូឆ្នាំ១៩៨៥របស់ UNCTRAL[94] ពន្យល់ថាវេទិកាមជ្ឈត្តការអាចសម្រេចបានតែរឿងដែលទាក់ទង នឹងពាណិជ្ជកម្មតែប៉ុណ្ណោះ។ មាត្រា ២(ឈ) នៃច្បាប់

---

[91] Dasteel, Jeffrey, International Commercial Arbitration for Law Students, Amazon, 2nd Edition, 2016, ទ ២៣១០

[92] http://www.newyorkconvention.org/countries

[93] http://www.newyorkconvention.org/countries

[94] ជាច្បាប់ដែលអង្គការសហប្រជាជាតិបានបង្កើតឡើងនៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ១៩៨៥ និងវិសោធនកម្មនៅថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៦ ដើម្បីប្រទេសនីមួយៗអាចយកជាគម្រូនៅក្នុងការដាក់បញ្ញត្តិចូលនៅក្នុងច្បាប់ជាតិរបស់ខ្លួន។

នេះបានឲ្យនិយមន័យ "ពាណិជ្ជកម្ម" ទៅតាមប្រភេទ នៃសកម្មភាពជួញដូរនីមួយៗ[95] ដូចគ្នាទាំងស្រុងនឹងមាត្រា ១ (១) នៃច្បាប់គម្រូនេះ។ ទោះបីច្បាប់នេះ មិនបានកំណត់ដែនកំណត់នៃប្រភេទនៃការជួញដូរក៏ដោយ ក៏បញ្ហាមួយចំនួនដូចជា ១) ទំនាក់ទំនងជាមួយបុគ្គល និងស្ថាប័នពាណិជ្ជកម្ម ២)ចំនួនទឹកប្រាក់ដែលវេទិកាទទួលដោះស្រាយវិវាទ ឬ ៣) លក្ខខណ្ឌ ឬលក្ខណៈវិនិច្ឆ័យដទៃទៀត ដែលវេទិកាមួយត្រូវបដិសេធមិនសម្រេចសេចក្តីនៅក្នុងនោះឡើយ។

ស្ថិតក្នុងល័ក្ខខ័ណ្ឌទម្រង់ធម្មតា វិវាទពាណិជ្ជកម្មដែលអាចដោះស្រាយបានតាមច្បាប់កម្ពុជាទាមទារឲ្យមានដូចខាងក្រោមៈ

១. មានការព្រមព្រៀងតាមកិច្ចសន្យាជាលាយលក្ខណ៍អក្សរ[96] ថានឹងប្រើវេទិកាមជ្ឈត្តកម្មផ្នែកពាណិជ្ជកម្ម[97]

២. ជារឿងពាណិជ្ជកម្ម[98]

មាត្រា ២(ឈ) នៃច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ទាមទារឲ្យមានការបកស្រាយទូលាយ ដើម្បីគ្របដណ្តប់លើគ្រប់ទំនាក់ទំនងទាំងអស់នៃប្រភេទពាណិជ្ជកម្ម មិនថាទំនាក់ទំនងនោះស្ថិតក្នុងកិច្ចសន្យា ឬក្រៅកិច្ចសន្យាក៏ដោយ។ ជាតួយ៉ាង ទំនាក់ទំនងរវាងភាគីអ្នកដឹកជញ្ជូន (ភាគីទី៣) ដែលមិនស្ថិតនៅក្នុងកិច្ចសន្យាពាណិជ្ជកម្មផ្គត់ផ្គង់របស់គូភាគីវិវាទ មិនអាចជារឿងសម្រាប់ធ្វើមជ្ឈត្តការបានទេ។ ប៉ុន្តែករណីកំហុសដែលកើតឡើងពីគូភាគី នៃកិច្ចសន្យាផ្គត់ផ្គង់ដែលកំហុសនោះមិនមានចែងក្នុងកិច្ចសន្យា (ឧទាហរណ៍ ករណីអំពើអនិត្យានុកូល) អាចត្រូវសម្រេចបានដោយមជ្ឈត្តការ ទោះបីជាបញ្ហានោះអាចត្រូវដោះស្រាយដោយយុត្តាធិការរបស់តុលាការជាតិក៏ដោយ។ មូលហេតុគឺថា គេអាចធ្វើការបកស្រាយបញ្ហាបន្ទាប់ខាងលើថាជាទំនាក់ទំនងក្រៅកិច្ចសន្យា ប៉ុន្តែមានលក្ខណៈពាណិជ្ជកម្ម ចំពោះគូភាគី។

[95] មាត្រា ២ (ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (LCA)

[96] មាត្រា ៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ច.ម.ព.)

[97] មាត្រា ២ (ឃ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

[98] មាត្រា ២ (ឈ) នៃច្បាប់ ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម កំណត់ថាធុរកិច្ចដែលមានប្រភេទជាពាណិជ្ជកម្មមានជាទី៖ កិច្ចការជំនួញដើម្បីផ្គត់ផ្គង់ ឬការផ្លាស់ប្តូរទំនិញ ឬសេវាផ្សេងៗ កិច្ចព្រមព្រៀងនៃការចែកចាយតំណាង ឬទីភ្នាក់ងារពាណិជ្ជកម្ម ការទិញ-លក់គណនីក្រុមហ៊ុន ការជួលទីតាំងឬសម្ភារៈវត្ថុ ការងារស្ថាបនា ការពិគ្រោះយោបល់វិស្វកម្ម ការចេញអាជ្ញាប័ណ្ណ ការវិនិយោគទុន ការផ្តល់ហិរញ្ញវត្ថុ ការធ្វើអាជីវកម្មធនាគារ ការធានារ៉ាប់រង កិច្ចព្រមព្រៀងធ្វើអាជីវកម្ម ឬសម្បទានក្រុមហ៊ុនចំរុះ និងប្រភេទផ្សេងៗទៀតនៃសហប្រតិបត្តិការឧស្សាហកម្ម ឬពាណិជ្ជកម្ម និងការដឹកជញ្ជូនទំនិញ ឬអ្នកដំណើរតាមផ្លូវអាកាស ផ្លូវទឹក ផ្លូវគោក។"

## ៣. សញ្ញាណមិនមែន "ពាណិជ្ជកម្ម"

ផ្ទុយពីតុលាការជាតិ ដែលអាចដោះស្រាយរឿងទូទៅ ដែលស្ថិតនៅក្នុងវិសាលភាពនៃទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដែលជាយុត្តាធិការដែនដី វេទិកាពាណិជ្ជកម្ម ត្រឹមតែមានយុត្តាធិការលើរឿងក្តីផ្នែកពាណិជ្ជកម្មប៉ុណ្ណោះ ហើយត្រូវឈរលើការបកស្រាយតាមច្បាប់តែមួយគត់របស់ច្បាប់ស្តីពីមជ្ឈការពាណិជ្ជកម្មនេះ។ សំនួរសួរថា តើច្បាប់ស្តីពី ការចុះបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម និងច្បាប់ដទៃទៀតអាចយកមកប្រើ ឬជាជំនួយក្នុងការយល់បន្ថែមពីពាក្យ "ពាណិជ្ជកម្ម" ក្នុងវិវាទពាណិជ្ជកម្ម របស់វេទិកាមជ្ឈត្តកម្ម ដែរឬទេ? ការពន្យល់បន្ថែមអំពីបញ្ហានេះទំនងជាអាចរកឃើញ ក្នុងការចង្អុលបង្ហាញរបស់មាត្រា៣៦(២) និងមាត្រា ៣៦(៤) នៃច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ មាត្រា ៣៦(២) នៃច្បាប់នេះ តម្រូវឲ្យវេទិកាមជ្ឈត្តកម្មប្រើប្រាស់ "ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីដែលភាគី វិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់ទេនោះ។" មាត្រា៣៦(៤) នៃច្បាប់ដដែលបានកំណត់ពីកាតព្វកិច្ចក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ដោយត្រូវយកចិត្តទុកដាក់ "ដល់ទម្លាប់ផ្នែកពាណិជ្ជកម្ម"។ នោះមានន័យថា ការស្វែងរកការពន្យល់បន្ថែមអាចទាក់ទងដល់ការបកស្រាយច្បាប់ផ្នែកពាណិជ្ជកម្មនានារបស់កម្ពុជាដើម្បីជួយកំណត់ពីអត្ថិភាពនៃសញ្ញាណ "ពាណិជ្ជកម្ម"។

មាត្រា ១ នៃ ច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម បានកំណត់ "ពាណិជ្ជករ" ថាជា "រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងឡាយណាដែលធ្វើពាណិជ្ជកិច្ច ហើយដែលយកពាណិជ្ជកិច្ចនេះជាមុខរបរខ្លួនជាប្រចាំ"។ ចំណែក "ពាណិជ្ជកិច្ច" គឺជា "សកម្មភាពទិញលក់ទំនិញ ឬសេវាដែលត្រូវបានអនុវត្តជាប្រចាំ ក្នុងគោលដៅធ្វើការដោះដូរ និងស្វែងរកចំណេញ" ។[99] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនបានកំណត់ពីអញ្ញត្តកម្ម សកម្មភាពដែលចាត់ទុកថាជា មិនមែនពាណិជ្ជកម្មឡើយ និងមិនកំណត់ថាតើទំនាក់ទំនងរវាងស្ថាប័នពាណិជ្ជកម្ម និងបុគ្គលអាចយកមកសម្រេចសេចក្តីបានដែរ ឬទេ។ មាត្រា ២(ឈ) នៃច្បាប់មជ្ឈត្តការសំដៅលើសកម្មភាពដែលចាត់ថាជាទំនាក់ទំនងពាណិជ្ជកម្ម ជាជាងភាពទទួលស្របច្បាប់ថាជាពាណិជ្ជករដែលជាបុគ្គលដែលធ្វើពាណិជ្ជកម្ម។ ឈរលើការបកស្រាយកាន់តែទូលាយទៀតនោះ និងផ្ទុយពីច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មមិនមានកំណត់ដែនកំណត់ "ពាណិជ្ជកម្ម" នៅត្រឹម "ការដោះដូរ" ឬ "ការស្វែងរកចំណេញ" ដែលជាទិសដៅជាទូទៅរបស់សហគ្រាសពាណិជ្ជកម្មទេ។ ដូច្នេះនៅពេលដែលច្បាប់មជ្ឈត្តការអនុញ្ញាតឲ្យមានការបកស្រាយទូលំទូលាយ និងខ្វះខាតការស្វែងយល់ពាក្យ "ពាណិជ្ជកម្ម"

[99] ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ១៩៩៥

គ្រប់គ្រាន់នៅក្នុងច្បាប់នេះ ច្បាប់ដទៃទៀតដែលមានរាយខាងលើអាចផ្តល់ជាការណែនាំសម្រាប់វេទិកាមជ្ឈត្តការពាណិជ្ជកម្មសម្រេចពីដែនកំណត់នៃទំនាក់ទំនងរបស់គូភាគី។

ដោយឡែកច្បាប់នេះ មិនតម្រូវឲ្យមានការចុះបញ្ជី សម្រាប់បំពេញល័ក្ខខ័ណ្ឌលើទំនាស់ដែលអាចវេទិកាអាចសម្រេចបាននោះឡើយ ប៉ុន្តែសំដៅលើប្រភេទសកម្មភាពអាជីវកម្ម។ ដូច្នេះប្រសិនបើគេរកឃើញថា មានទំនាក់ទំនងរវាងស្ថាប័នពាណិជ្ជកម្ម ដែលមិនបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ពាណិជ្ជកម្មជាមួយស្ថាប័នមួយទៀត មិនបានចុះបញ្ជីដែរ ឬជាមួយបុគ្គលសុទ្ធសាទ (រួមទាំងជាអ្នកប្រើប្រាស់ផង) ហេតុផលនេះមិនអាចធ្វើឲ្យ*កិច្ចព្រមព្រៀងមជ្ឈត្តកម្ម*[100] គ្មានប្រសិទ្ធិភាពឡើយ។

លើសពីនេះ ច្បាប់មជ្ឈត្តការពាណិជ្ជកម្ម នៃប្រទេសកម្ពុជា មិនមានចែងពីអញ្ញត្រកម្មកម្ម (ភាពលើកលែង) លើចំណុចដែលមិនអាចដោះស្រាយបានឡើយ។ ទោះជាយ៉ាងណាក៏មាត្រា ១ កថាខណ្ឌ២ នៃច្បាប់នេះ មានកំណត់ពីដែនសមត្ថកិច្ចក្នុងការសម្រេចរបស់ខ្លួន មិនឲ្យជ្រៀតជ្រែកចូល បញ្ហាដែលដោះស្រាយដោយតុលាការ តាមអណត្តិច្បាប់ដទៃទៀត។ នេះជាចំណុចសំខាន់មួយដើម្បីពិចារណា ពេលវេទិកាពាណិជ្ជកម្មសម្រេចថា ខ្លួនមានយុត្តាធិការឬទេ។ ប៉ុន្តែ ទាមទារឲ្យពិនិត្យមើលតើច្បាប់ដទៃទៀតបាន ចាត់ទុកបញ្ហាណាខ្លះជាបញ្ហាដែលខ្លួនមានសមត្ថកិច្ច និងដោយពិចារណាយ៉ាងម៉ត់ចត់ថា ខ្លួនពិតជាមានសមត្ថកិច្ចលើបញ្ហាដទៃនោះមែន។[101]

## ៤. ការឆ្លុះបញ្ចាំងបទពិសោធន៍កម្ពុជា ជាមួយ ប្រទេសសឹង្ហបូរី (Singapore) និង អាហ្សង់ទីន (Argentina)

ទាក់ទងនឹងការកំណត់សញ្ញាណមិនមែនពាណិជ្ជកម្ម តុលាការសាលាឧទ្ធរណ៍នៅប្រទេសសឹង្ហបុរី[102] (Singapore) បានចេញសេចក្តីសម្រេចមួយនៅក្នុងឆ្នាំ២០១១ អំពីអ្វី

[100] ពាក្យ "*កិច្ចព្រមព្រៀងមជ្ឈត្តកម្ម*" ត្រូវបានប្រើនៅក្នុងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ថាជា"កិច្ចព្រមព្រៀងផ្សះផ្សារ"។

[101] មាត្រា ១ កថាខ័ណ្ឌ២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ចែងថា "ច្បាប់នេះ មិនប៉ះពាល់ដល់អានុភាពគតិយុត្តិនៃច្បាប់នានា ឯទៀត របស់ព្រះរាជាណាចក្រកម្ពុជាដែលនៅក្នុងនោះ ករណីវិវាទខ្លះផ្សះផ្សាបាន ឬដោះស្រាយបានតាមនីតិវិធីផ្សេងៗទៀត និងវិវាទខ្លះទៀតផ្សះផ្សាមិនបាន។"

[102] ប្រទេសស៊ីងហ្គាពួរ តំណាងឲ្យប្រទេសខាំមិនឡ និងស្ថិតក្នុងចំណោមប្រទេសទាំង៥ ដែលគេចូលចិត្តប្រើជាកន្លែងធ្វើមជ្ឈត្តការផ្នែកពាណិជ្ជកម្មបំផុត ផ្អែកតាមការស្រាវជ្រាវផ្នែកមជ្ឈត្តការអន្តរជាតិមួយ របស់សកលវិទ្យាល័យ Queen Mary University of London ឆ្នាំ ២០១៥ ,Queen Mary University of London - White & Case, 2015 International Arbitration Survey: Improvements and Innovations in International Arbitration (www.singaporelaw.sg)

ដែលគេចាត់ទុកថា វេទិកាមជ្ឈត្តការមិនអាចសម្រេចបាន ដោយមូលហេតុប៉ះពាល់ដល់ប្រយោជន៍សាធារណៈនៅពេលដែលច្បាប់ដែលមានស្រាប់មិនបានឲ្យនិយមន័យច្បាស់លាស់សព្វគ្រប់អំពីអ្វីដែលវេទិកាមជ្ឈត្តការអាចសម្រេចបាន ដែលរួមមាន[103]៖

- បញ្ហាទាក់ទងនឹងពលរដ្ឋ ឬភាពស្របច្បាប់នៃអាពាហ៍ពិពាហ៍ (Matters relating to citizenship or legitimacy of marriage.)
- ការផ្តល់ជូន អាជ្ញាប័ណ្ណនានា តាមផ្លូវច្បាប់ (Grants of statutory licences).
- សុពលភាពនៃការចុះ ពាណិជ្ជនាម ឬប៉ាតង់ (Validity of registration of trade marks or patents).
- សិទ្ធិថតចម្លង (Copyrights)
- ការជម្រះបញ្ជីក្រុមហ៊ុន (Winding-up of companies)
- ក្ស័យធនរបស់កូនបំណុល (Bankruptcies of debtors)
- ការគ្រប់គ្រងលើទ្រព្យសម្បត្តិ (Administration of estates.)

ដោយឡែកតាមច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មកម្ពុជា ទំនាស់ពាណិជ្ជកម្មរវាងរដ្ឋ និងឯកជនក៏អាចចាត់ចូលក្នុងទំនាស់ដែលអាចដោះស្រាយ ក្នុងវេទិកាមជ្ឈត្តការបានដែរ ដោយផ្អែកលើសារធាតុពាណិជ្ជកម្មនេះ។ ទោះបីជាយ៉ាងណាក៏ដោយ មាត្រា ២ (ឈ) នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានកំណត់ ទំនាក់ទំនងពាណិជ្ជកម្មថារួមទាំង "ការចេញអាជ្ញាប័ណ្ណ"។ ដោយឡែកប្រសិនបើមានក្រុមហ៊ុនរដ្ឋមួយដែលមានភាគហ៊ុនរដ្ឋ និងឯកជនដែលភាគីស្ថាប័នក្រសួងដែលគ្រប់គ្រងលើភាគហ៊ុនរបស់រដ្ឋ នោះត្រូវអនុវត្តកាតព្វកិច្ចផ្តល់អាជ្ញាប័ណ្ណរុករករ៉ែដល់ភាគីខាងឯកជន។ តើរឿងនេះអាចទៅរួចដែរ ឬទេ? តើវេទិកាមជ្ឈត្តកម្មអាចបញ្ជាឲ្យស្ថាប័នរដ្ឋនោះចេញ អាជ្ញាប័ណ្ណឲ្យភាគីអ្នកឈ្នះដែរ ឬទេ?

ដូច្នេះ "ការចេញអាជ្ញាប័ណ្ណ" ស្ថិតក្នុងន័យអាជីវកម្ម អាចមានភាពមិនច្បាស់លាស់មួយចំនួន ដោយសារគ្មានភាគីឯកជនណា (ជាតួយ៉ាង វេទិកាមជ្ឈត្តការពាណិជ្ជកម្ម) មានសិទ្ធិបញ្ជាឲ្យស្ថាប័នរដ្ឋចេញអាជ្ញាប័ណ្ណទេ។ អាចនិយាយម៉្យាងទៀតថា ការសម្រេចឲ្យអាជ្ញាធរជាតិចេញអាជ្ញាប័ណ្ណដែលជាតតិយជន ក៏មិនអាចទៅរួចដែរ។ ការសម្រេចឲ្យផ្តល់អាជ្ញាប័ណ្ណ ក៏ជាការរំលោភដល់គោលការណ៍គោលនយោបាយសាធារណៈដែលមានចែងក្នុងមាត្រា៤៤(ខ)២

[103] the Court of Appeal in *Larsen Oil and Gas Pte Ltd v Petropord Ltd (2011) SGCA 21* www.singaporelaw.sg

នៃច្បាប់នេះ[104]ដែលធ្វើឲ្យការទទួលស្គាល់ និងការអនុវត្តមិនអាចធ្វើទៅបាន។ ដោយហេតុថា ទោះបីជា ច្បាប់មជ្ឈត្តការរបស់កម្ពុជាមិនមានកំណត់និយមន័យពាក្យ "គោលនយោបាយសាធារណៈ" ការអនុវត្តសិទ្ធិជំនួស និងសិទ្ធិចាប់បង្ខំស្ថាប័នរដ្ឋបែបនេះនឹងធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ប្រសិនណាបើ ស្ថាប័នជំនាញរបស់រដ្ឋយល់ថា ការផ្តល់នោះជាអំពើបំពានលើផលវិបាកបច្ចេកទេស។

ក្រមរដ្ឋប្បវេណី និងពាណិជ្ជកម្ម ខែសីហា ឆ្នាំ២០១៥ នៃ ប្រទេសអាហ្សង់ទីនដែលជាប្រទេសប្រកាន់ប្រព័ន្ធស៊ីវិលលរ (ផ្អែកលើការចែងរបស់ច្បាប់)ដូចប្រទេសកម្ពុជាដែរបានកំណត់ពីបញ្ហាមួយចំនួន ដែល វេទិកាមិនអាចសម្រេចបាន ដែលមានដូចជា[105]៖

- ឋានៈស៊ីវិល ឬសមត្ថភាពរបស់បុគ្គល (the civil status or capacity of persons;)
- បញ្ហាគ្រួសារ (family matters;)
- អ្នកប្រើប្រាស់ និងអតិថិជន (users and consumers;)
- កិច្ចសន្យាតាមទម្រង់គម្រូ (standard form contracts;)
- ច្បាប់ការងារ (labor law) និង
- ភាគីដែលជារដ្ឋសហព័ន្ធ ឬរដ្ឋក្នុងស្រុកទាំងឡាយ (Federal State or local states parties)

ប្រទេសកម្ពុជាមិនទាន់មាន ច្បាប់ការពារអ្នកប្រើប្រាស់ ដែលការពារអ្នកប្រើប្រាស់ទេ។ ដូច្នេះ និយមន័យ ឬលក្ខណៈសម្គាល់អ្នកប្រើប្រាស់មិនមានការកំណត់ជាផ្លូវការទេ។ ហេតុផលនេះ កិច្ចសន្យាដែលបង្កើតទំនាក់ទំនងរវាងក្រុមហ៊ុនមួយ និងអ្នកប្រើប្រាស់ម្នាក់ ឬមួយក្រុម នៅមានភាពមិនច្បាស់លាស់ ថាជាភាគីក្នុងទំនាក់ទំនងពាណិជ្ជកម្ម ឬទេ? ឧទាហរណ៍ កិច្ចសន្យាប្រើប្រាស់សេវាទូរស័ព្ទ អាចថាធ្វើឡើងរវាងក្រុមហ៊ុន និងអ្នកប្រើសេវា ដែលអ្នកប្រើប្រាស់អាចប្រើអស់ប្រាក់២០ដុល្លាជាកម្មវត្ថុដែលមិនមានហេតុផលផ្អែកលទ្ធភាព ក្នុងការសម្រេចដោយវេទិកាមជ្ឈត្តការទេ។ ប៉ុន្តែកិច្ចសន្យាមួយដែលអ្នកប្រើប្រាស់ជារោងចក្រហើយប្រើអគ្គិសនីមួយខែអស់ ២០ម៉ឺនដុល្លា ហើយអ្នកប្រើប្រាស់បានជំពាក់បំណុលនេះរយៈពេល៣ខែហើយ។ កិច្ចសន្យានេះ

[104] មាត្រា ៤៤ (ខ) ២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មចែងថា "ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទ្រង់ទ្រាយជាបណ្តឹងបដិសេធ និងតាមបែបបទដូចខាងក្រោមៈ មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា"។

[105] www.lexology.com, First-instance Court in Civil Proceedings 104; Court of Appeals in Civil Proceedings, Chamber F, *Blanco Rodriguez, María de las Mercedes v Madero Urbana SA s/ Cumplimiento de contrato* (Case 71416/2014)

ទំនងជាបង្កប់ការយល់ឃើញរបស់វេទិកាថា មានលទ្ធភាពក្នុងការដើរនីតិវិធីមជ្ឈត្តការខ្លាំងជាងកិច្ចសន្យាមុន។ គគួរកត់សំគាល់ថា ពាក្យ "អ្នកប្រើប្រាស់" មានវិសាលភាពប៉ុណ្ណាដែរ។

លើសពីនេះទៅទៀត វេទិកាមជ្ឈត្តកម្មពាណិជ្ជកម្ម កម្ពុជាអាចបដិសេធ មិនសម្រេចលើកិច្ចសន្យារវាងក្រុមហ៊ុន និងអ្នកប្រើប្រាស់ ប្រសិនបើខ្លួនយល់ថាទំនាក់ទំនងនោះមិនមែនជាទំនាក់ទំនងពាណិជ្ជកម្ម។ ប៉ុន្តែ មូលដ្ឋានផ្លូវច្បាប់ដែលកំនត់ពីភាពដែលអាចសម្រេចបាន ក៏អាចត្រូវគេបកស្រាយដូចគ្នានេះដែរ ប្រសិនណាបើគេយល់ថាមិនអាចសម្រេចបាន។ នៅយុត្តាធិការនៃប្រទេសដទៃទៀត អាចសម្រេចផ្សេងពីនេះដែរ អាស្រ័យលើលក្ខខណ្ឌច្បាប់នីមួយៗ (ប្រទេសស៊ីវិលឡូ) និងសេចក្តីសម្រេចរបស់ចៅក្រម (ប្រទេសកុំមិនឡូ)៕

យ៉ាងណាមិញ ទោះបីជាវិវាទការងារមានភាពច្បាស់លាស់ថាមិនត្រូវចាត់ចូល នៅក្នុងវិវាទពាណិជ្ជកម្មក៏ដោយ ក៏ទំនាក់ទំនងការងារដែលនិយោជិកទទួលពីនិយោជកខ្លះ មានភាពជឿនលឿន និងប្រព្រឹត្តទៅលើសពីច្បាប់ការងារបច្ចុប្បន្នរបស់កម្ពុជា[106]។ ជាតួយ៉ាង តើគេអាចបកស្រាយថា បុគ្គលិកលក់ដែលទទួលប្រាក់ខែ ១០០ដុល្លាក្នុង១ខែ (ប្រាក់ខែថេរ) ហើយទទួលបានប្រាក់កម្រៃជើងសារគិតជាភាគរយ ជាមធ្យម ១០.០០០ដុល្លាក្នុង១ខែថា ជាទំនាក់ទំនងនៃកិច្ចសន្យាមិនមែនពាណិជ្ជកម្មសុទ្ធសាធឬទេ នៅពេលដែលភ្នាក់ងារលក់នោះមានភាពម្ចាស់ការច្រើន (Autonomy) តាមរយៈចំណូលឯករាជ្យមួយចំនួនធំ (ប្រាក់កម្រៃជើងសារគិតជាភាគរយជាមធ្យម ១០.០០០ដុល្លា) ។ តើគេអាច យកចំណុចវិវាទ លើមូលដ្ឋានទឹកប្រាក់ ២ម៉ឺនដុល្លាក្នុង១ខែនោះ នោះថាអាចដោះស្រាយដោយមជ្ឈត្តការពាណិជ្ជកម្មកម្ពុជាដែរ ឬទេ?

## ៥. សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជា ប្រកាន់គោលការណ៍បកស្រាយ និងអនុវត្តតាមខ្លឹមសារនៃច្បាប់ទាក់ទងនឹងពាក្យ "ពាណិជ្ជកម្ម" ដែលមានចែង ដែលខុសពីប្រទេសកុំមិនឡូ (Common Law) ដែលមានការបត់បែនតាមបណ្តុំនៃគំនិតរបស់ស្ថាប័នតុលាការ នៅពេលដែលច្បាប់មានការខ្វះចន្លោះ ឬបំពេញន័យឲ្យច្បាប់។ មាត្រា ២ (ឈ) ដែលកំណត់ពីសញ្ញាណពាណិជ្ជកម្មប្រកបដោយភាពទូលំទូលាយផ្តល់ភាពងាយស្រួលក្នុងចំណាត់ថ្នាក់ចំណុចវិវាទឲ្យចូលក្នុងសមត្ថកិច្ចដោះស្រាយរបស់វេទិកាមជ្ឈត្តកម្ម។ ប៉ុន្តែ ក៏ផ្តល់ភាពលំបាកដែរចំពោះទំនាស់តូចតាច ឬទំនាស់ដែលភាគីតូចតាច មិនមានអាចគ្រប់គ្រងពីជោគវាសនានៃទំនាស់របស់ខ្លួនបាន (ឧទាហរណ៍៖ អ្នកប្រើប្រាស់សេវាទូរស័ព្ទមួយរូប និងក្រុមហ៊ុនទូរគមនាគមន៍)។

[106] ច្បាប់ការងារ នៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលមានអាយុជាង១០ឆ្នាំ ចាប់តាំងពីរដ្ឋសភាពបានអនុម័ត និងដាក់ឲ្យប្រើប្រាស់។

នៅពេលដែលច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្មសព្វថ្ងៃមិនមានចែងពីអញ្ញត្រកម្ម លើទំនាស់ដែលមិនអាចដោះស្រាយបាន កាតព្វកិច្ចរបស់វេទិកាមជ្ឈត្តកម្មនឹងត្រូវសម្រេចដោយខ្លួនឯង លើយុត្តិការផ្នែកចំណុចវិវាទដោយខ្លួនឯង និងអាចផ្អែកលើការណែនាំរបស់ច្បាប់ក្នុងស្រុកមួយចំនួនដើម្បីពន្យល់បន្ថែមពីសញ្ញាណពាណិជ្ជកម្ម ដើម្បីសម្រេចបាននូវយុត្តិធម៌ (natural justice) សម្រាប់គូភាគី។ ចំពោះការចូលរួមរបស់មជ្ឈត្តករពាណិជ្ជកម្មបរទេស នៅក្នុងវេទិកាមជ្ឈត្តកម្មពាណិជ្ជកម្មណាមួយ វាមានភាពជៀសមិនផុតទេ ក្នុងការប្រើការពិចារណាលើរឿងក្តីរបស់ប្រទេសក្រៅក្នុងការពិភាក្សា និងការរិះរកហេតុផលចុងក្រោយ និងដើម្បីបំពេញយុត្តិធម៌ឲ្យគ្រប់ភាគី។ ការស្វែងរកយោបល់បន្ថែមពីការសម្រេច ក្នុងរឿងក្តីក្រៅប្រទេសគឺ អាចបូករួមទាំងមូលហេតុដែលប្រទេសកម្ពុជាទើបតែមានវេទិកាមជ្ឈត្តកម្ម ដែលមានបទពិសោធន៍ជម្រះរឿងក្តីតិចតួចបំផុតក្នុងរយៈពេលជាង១០ឆ្នាំ បន្ទាប់ពីច្បាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ខ្លួនចូលជាធរមានមក។

ម៉្យាងវិញទៀត ដោយសារសញ្ញាណនៃពាក្យ "ពាណិជ្ជកម្ម" នេះមានទំនាក់ទំនងផ្ទាល់ជាមួយច្បាប់ជាតិរបស់ប្រទេសដែលវេទិកាមជ្ឈត្តកម្មតាំងនៅ និងប្រទេស នៃកន្លែងអនុវត្តសេចក្តីសម្រេចតាំងនៅ ការសម្រេចចិត្តទទួលយកវិវាទមួយមកសម្រេច ត្រូវព្យាយាមធានាឲ្យបានថាភាគីណាមួយនឹងមិនព្យាយាមជំទាស់ការអនុវត្ត ផ្អែកលើលក្ខខ័ណ្ឌ មិនមែនពាណិជ្ជកម្មនៅពេលក្រោយទេ។

# សិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

# យន្តការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ

លោកមេធាវី វង់ គុន*

## ១. សេចក្តីផ្តើម

ក្រោយសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) មានសន្និសីទអន្តរជាតិមួយត្រូវបានរៀបចំឡើងចាប់ពីខែមេសា-មិថុនា ១៩៤៥ នៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិច ដើម្បីពិភាក្សាលើអត្ថបទច្បាប់មួយដែលក្រោយមកត្រូវបានស្គាល់ជាទូទៅថា ធម្មនុញ្ញសហប្រជា-ជាតិ។ ក្នុងឱកាសបិទសម័យប្រជុំនៃអង្គសន្និសិទ្ទនេះនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៤៥ ធម្មនុញ្ញសហប្រជាជាតិត្រូវបានបើកឱ្យចុះហត្ថលេខា ហើយធម្មនុញ្ញនេះបានចូលជាធរមាននៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៤៥ គឺជាថ្ងៃដែលអង្គការសហប្រជាជាតិត្រូវបានបដិសន្ធិឡើង។ សព្វថ្ងៃនេះអង្គការសហប្រជាជាតិមានសមាជិកចំនួន១៩៨រដ្ឋ។ សសរស្តម្ភនៃធម្មនុញ្ញសហប្រជាជាតិមានបីគឺ៖

- ➢ សន្តិភាព និងសន្តិសុខពិភពលោក
- ➢ សិទ្ធិមនុស្ស និងនីតិរដ្ឋ
- ➢ ការអភិវឌ្ឍន៍

សសរស្តម្ភទាំងបីនេះប្រៀបបាននឹងមុំចង្ក្រានដែលត្រូវពឹងអាស្រ័យគ្នាទៅវិញទៅមក។ ធម្មនុញ្ញនេះ បានបង្កើតស្ថាប័នសហប្រជាជាតិធំៗចំនួន៦ គឺមហាសន្និបាតអង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម តុលាការយុត្តិធម៌អន្តរជាតិ ក្រុមប្រឹក្សាអាណាព្យាបាល និងលេខាធិការដ្ឋានអង្គការសហប្រជាជាតិ។ លេខាធិការដ្ឋានគឺជាសេនាធិការប្រតិបត្តិរបស់សហប្រជាជាតិ។ លេខាធិការដ្ឋានដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់របៀបវារៈពីការប្រជុំពិភាក្សា និងការប្រជុំធ្វើសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ក្រុមប្រឹក្សាសន្តិសុខនិងក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម និងការអនុវត្តសេចក្តីសម្រេចរបស់ស្ថាប័នទាំងនេះ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវបោះឆ្នោតជ្រើសតាំងដោយមហាសន្និបាតអង្គការសហប្រជាជាតិ គឺជាប្រធានលេខាធិការដ្ឋាននេះ។

លេខាធិការដ្ឋានសហប្រជាជាតិ ត្រូវបានបែងចែកជា១០ការិយាល័យ៖

១. ការិយាល័យប្រតិបត្តិរបស់អគ្គលេខាធិការ

---

* លោក វង់ គុន មេធាវីនៅការិយាល័យ Legal Town Law Firm

២. ការិយាល័យត្រួតពិនិត្យសេវាផ្ទៃក្នុង
៣. ការិយាល័យកិច្ចការនីតិកម្ម (ជាការិយាល័យមួយធ្វើការជាមួយសាលាក្តីខ្មែរក្រហម)
៤. ការិយាល័យកិច្ចការរំសាយអាវុធ
៥. ការិយាល័យសម្របសម្រួលកិច្ចការមនុស្សធម៌
៦. ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស (មានការិយាល័យនៅភ្នំពេញ)
៧. ការិយាល័យឧត្តមស្នងការជនភៀសខ្លួន (មានការិយាល័យនៅភ្នំពេញ)
៨.ការិយាល័យគ្រឿងញៀន និងឧក្រិដ្ឋកម្ម (មានការិយាល័យនៅភ្នំពេញ)
៩.ការិយាល័យតំណាងជាន់ខ្ពស់សម្រាប់ប្រទេសតតិយលោក ប្រទេសមិនសូវអភិវឌ្ឍន៍ និងប្រទេសជាកោះ តូចៗកំពុងអភិវឌ្ឍន៍
១០. ការិយាល័យកិច្ចការអវកាស

ក្រៅពីទីស្នាក់ការធំនៅបូរីញូយក សហប្រជាជាតិក៏មានទីស្នាក់ការនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ទីស្នាក់ការនៅទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា និងទីស្នាក់ការនៅទីក្រុងវៀន ប្រទេសអូទ្រីស។ ក្រៅពីទីស្នាក់ការខាងលើនេះ សហប្រជាជាតិក៏នៅមានស្នាក់ការក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៅតាមតំបន់មួយចំនួន ដូចជានៅបាងកកជាដើម។

ខាងលើនេះ គ្រាន់តែចង់រំលេចពីទីតាំងនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សដែលមានទីស្នាក់ការនៅទីក្រុងហ្សឺណែវ ដោយសារតែការិយាល័យឧត្តមស្នងការគឺជាលេខាធិការដ្ឋាននៃយន្តការ ឬស្ថាប័នសិទ្ធិមនុស្សសហប្រជាជាតិទាំងអស់។

យន្តការសិទ្ធិមនុស្សសហប្រជាជាតិ ត្រូវបានបង្កើតឡើង ដោយឈរលើមូលដ្ឋានពីរ៖

- ស្ថាប័នដែលបង្កើតឡើងដោយឈរលើមូលដ្ឋានធម្មនុញ្ញ គឺមានក្រុមប្រឹក្សាសិទ្ធិមនុស្ស
- ស្ថាប័នដែលបង្កើតឡើងដោយឈរលើមូលដ្ឋានសន្ធិសញ្ញា គឺស្ថាប័នសន្ធិសញ្ញា

## ២. ក្រុមប្រឹក្សាសិទ្ធិមនុស្ស

គឺជាស្ថាប័នអន្តររដ្ឋាភិបាល នៅក្នុងប្រព័ន្ធសហប្រជាជាតិទទួលខុសត្រូវពង្រឹងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស នៅជុំវិញពិភពលោក និងដោះស្រាយស្ថានភាពនៃការរំលោភបំពានសិទ្ធិ និងផ្តល់អនុសាសន៍ពីដំណោះស្រាយនោះ។ ក្រុមប្រឹក្សានេះមានសមត្ថភាពពិភាក្សាគ្រប់បញ្ហា និងស្ថានភាពសិទ្ធិមនុស្ស។

គួរកត់សំគាល់ថា កាលពីមិនទាន់មានក្រុមប្រឹក្សាសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ មានគណៈកម្មការសិទ្ធិមនុស្ស (កុំច្រឡំជាមួយគណៈកម្មាធិការសិទ្ធិមនុស្សដែលជាស្ថាប័នសន្ធិសញ្ញាមួយបង្កើតឡើងដោយកតិកាសញ្ញា ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ)។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៤៦ គឺមួយឆ្នាំក្រោយពីការបង្កើតអង្គការសហប្រជាជាតិ។ គណៈកម្មការនេះត្រូវបានបង្កើតដើម្បីការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្សគ្រប់រូប។ គណៈកម្មការនេះ មានសមាជិកចំនួន៥៣រដ្ឋសមាជិក បោះឆ្នោតជ្រើសតាំងដោយក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម។ ក្នុងចំណោមសមាជិកទាំងអស់ គ្មានសមាជិកណាមួយជាសមាជិកអចិន្ត្រៃយ៍នោះទេ។ ការបោះឆ្នោតត្រូវធ្វើរៀងរាល់ខែឧសភា ដោយបោះឆ្នោតជ្រើសយក១/៣ នៃសមាជិកគណៈកម្មការដើម្បីជំនួសសមាជិកដែលត្រូវដល់វេនចាកចេញ។ សមាជិក ម្នាក់ៗមានអាណត្តិរយៈពេល៣ឆ្នាំ ហើយអាចឈរឈ្មោះឱ្យគេបោះឆ្នោតជាថ្មីបាន។ ចំនួនសមាជិកទាំង៥៣រដ្ឋនេះត្រូវបានបែងចែកទៅតាមតំបន់ភូមិសាស្ត្រដូចខាងក្រោម៖

រដ្ឋនៅអាហ្វ្រិចៈ ១៥រដ្ឋ

រដ្ឋនៅអាស៊ីៈ ១២រដ្ឋ

រដ្ឋនៅអឺរ៉ុបខាងកើតៈ ៥រដ្ឋ

រដ្ឋនៅអាមេរិចឡាទីន និងតំបន់ការ៉ាប៊ីនៈ ១១រដ្ឋ

រដ្ឋនៅអឺរ៉ុបខាងលិច និងរដ្ឋដទៃទៀតៈ ១០រដ្ឋ (បច្ចឹមលោក)

ក្នុងអំឡុងសម័យប្រជុំប្រចាំឆ្នាំរបស់ខ្លួន មានប្រតិភូមិនតិចជាង៣០០០នាក់ បានមកចូលរួមជាទៀងទាត់ ភាគច្រើនមកពីរដ្ឋសមាជិក រដ្ឋសង្កេតការណ៍ និងតំណាងអង្គការក្រៅរដ្ឋាភិបាល។ ជារៀងរាល់ឆ្នាំ គណៈកម្មការនេះបានអនុម័តសេចក្តីសម្រេចមិនតិចជាង១០០ សេចក្តីសម្រេចនោះទេ អំពីបញ្ហានានាពាក់ព័ន្ធនឹងបុគ្គលនៅក្នុងគ្រប់តំបន់និងគ្រប់កាលៈទេសៈ។ រាល់សម័យប្រជុំ មានការជួយជ្រោមជ្រែងពីអនុគណៈកម្មការស្តីពីការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ក្រុមការងារមួយចំនួនធំ និងបណ្តាញនៃអ្នករាយការណ៍ អ្នកតំណាង អ្នកជំនាញជាឯកត្តបុគ្គល ដែលមានអាណត្តិត្រូវរាយការណ៍មកគណៈកម្មការពីបញ្ហាជាក់លាក់នានា។ គណៈកម្មការក៏ធ្វើជាវេទិកាមួយដែលប្រទេសនានាទាំងតូចទាំងធំ ក្រុមអង្គការមិនមែនរដ្ឋាភិបាល និងអ្នកការពារសិទ្ធិមនុស្សមកពីគ្រប់ទិសទី សំដែងពីការព្រួយបារម្ភរបស់ពួកគេ។ នាសម័យប្រជុំម្តងៗ មានតែស្ថានភាពសិទ្ធិមនុស្សរបស់រដ្ឋមួយចំនួនប៉ុណ្ណោះ ត្រូវបានយកមកពិនិត្យ។

ពេលដែលក្រុមប្រឹក្សាសិទ្ធិមនុស្សត្រូវបានបង្កើតឡើង គណៈកម្មការនេះ លែងមានអត្ថិភាពតទៅទៀតហើយ។

ក្រុមប្រឹក្សាសិទ្ធិមនុស្សត្រូវបានបង្កើតឡើងដោយ មហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃ១៥ មីនា ២០០៦ តាមរយៈសេចក្ដីសម្រេចរបស់ខ្លួនលេខ៦០/២៥១ ដែលទន្ទឹមគ្នានោះ ក៏បង្កើតយន្តការនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់។ សម័យប្រជុំលើកទី១របស់ក្រុមប្រឹក្សានេះ ប្រព្រឹត្តទៅពីថ្ងៃ១៩ ដល់៣០ ខែមិថុនា ឆ្នាំ២០០៦។

ក្រុមប្រឹក្សាសិទ្ធិមនុស្ស មានសមាជិកចំនួន៤៧រដ្ឋសមាជិកសហប្រជាជាតិ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ និងសម្ងាត់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ។ មហាសន្និបាត តែងតែគិតគូរដល់រដ្ឋបេក្ខភាព ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងរដ្ឋបេក្ខភាពណាដែលមានការតាំងចិត្ត និងការប្ដេជ្ញាចិត្តដោយស្ម័គ្រចិត្តដល់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។

ទោះជាយ៉ាងណាក៏ដោយ សមាជិកក្រុមប្រឹក្សាត្រូវបានបោះឆ្នោតជ្រើសរើសតាមចំនួនកូតានៃតំបន់ភូមិសាស្ត្រដូចខាងក្រោម៖

រដ្ឋនៅអាហ្វ្រិច៖ ១៣រដ្ឋ

រដ្ឋនៅអាស៊ីប៉ាស៊ីហ្វិច៖ ១៣រដ្ឋ

រដ្ឋនៅអាមេរិចឡាទីន និងតំបន់ការ៉ាប៊ីន៖ ៨រដ្ឋ

រដ្ឋនៅអឺរ៉ុបខាងលិច និងរដ្ឋដទៃទៀត៖ ៧រដ្ឋ

រដ្ឋនៅអឺរ៉ុបខាងកើត៖ ៦រដ្ឋ

សមាជិកទាំងអស់មានអាណត្តិរយៈពេល៣ឆ្នាំ ហើយមិនអាចឈរឈ្មោះឱ្យគេបោះឆ្នោតបានភ្លាមទេ ក្រោយពីបានកាន់២អាណត្តិជាប់ៗគ្នាហើយនោះ។

គួរកត់សំគាល់ថា សមាជិកទាំង៤៧រូបនេះ គឺជាឯកអគ្គរាជទូត/រដ្ឋទូតតំណាងឱ្យរដ្ឋសមាជិកទាំងនេះ។ ដោយឡែក ប្រធានក្រុមប្រឹក្សាសិទ្ធិមនុស្សគឺ ជាប្រធានដូរវេនរៀងរាល់ឆ្នាំ និងមានអនុប្រធាន៥រូបតំណាងឱ្យតំបន់ទាំង៥ខាងលើ។

រហូតដល់១ឆ្នាំក្រោយមក គឺនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ ទើបក្រុមប្រឹក្សានេះ បានអនុម័តសេចក្ដីសម្រេចលេខ៥/១ ដើម្បីបង្កើតនីតិវិធីនិងយន្តការធ្វើការរបស់ខ្លួន រួមទាំងនីតិវិធីបណ្ដឹង និងគណៈកម្មាធិការប្រឹក្សាយោបល់។ លើសពីនេះ ក្រុមប្រឹក្សានេះក៏បានអនុម័តបន្តយកនីតិវិធីពិសេសរបស់អតីតគណៈកម្មការសិទ្ធិមនុស្សផងដែរ។

**ក. គណៈកម្មាធិការប្រឹក្សាយោបល់៖** មានអ្នកជំនាញ១៨រូប បង្កើតឡើងដើម្បីបំពេញភារកិច្ចជា "ក្រុមផ្ដល់គំនិត"ដល់ក្រុមប្រឹក្សានិងធ្វើការក្រោមការណែនាំពីក្រុមប្រឹក្សា។ គួរកត់សំគាល់ជាថ្មីម្ដងទៀតថា សមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្សមិនមែនសុទ្ធតែជាអ្នកជំនាញខាងសិទ្ធិមនុស្សនោះទេ ពួកគាត់គឺជាឯកអគ្គរាជទូត/រដ្ឋទូតនៃប្រទេសដែលត្រូវបោះឆ្នោតជ្រើសរើសជាសមាជិក

ក្រុមប្រឹក្សានេះតែប៉ុណ្ណោះ។ ដូច្នេះ គណៈកម្មាធិការប្រឹក្សាយោបល់នេះ ដើរតួនាទីមួយយ៉ាងសំខាន់ ជួយដល់សមាជិកក្រុមប្រឹក្សា លើគ្រប់ទិដ្ឋភាពសិទ្ធិមនុស្ស និងក្នុងគ្រប់កាលៈទេសៈ។ គណៈកម្មាធិការនេះបង្កើតឡើងដើម្បីជំនួសអនុគណៈកម្មការស្តីពីការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស របស់អតីតគណៈកម្មការសិទ្ធិមនុស្ស។

**ខ. នីតិវិធីបណ្តឹង៖** ត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយករណីរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬជាប្រព័ន្ធដែលកើតមានឡើងនៅផ្នែកណាមួយក្នុងពិភពលោកនេះ ឬក្នុងកាលៈទេសៈណាមួយ។ នីតិវិធីបណ្តឹង បើកឱ្យមានការប្តឹងផ្ទាល់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សដោយបុគ្គលក្រុមបុគ្គល ឬអង្គការមិនមែនរដ្ឋាភិបាលដែលអះអាងថាខ្លួនជាជនរងគ្រោះ នៃការរំលោភបំពានសិទ្ធិមនុស្ស ឬក៏ដឹងដោយផ្ទាល់ ជឿជាក់ពីការរំលោភបំពានបែបនេះ។ ដូចនីតិវិធីលេខ១៥០៣របស់អតីតគណៈកម្មការសិទ្ធិមនុស្សដែរ គឺជានីតិវិធីមួយសំងាត់ ដើម្បីលើកកំពស់កិច្ចសហការជាមួយរដ្ឋសមាជិកពាក់ព័ន្ធ។ នីតិវិធីបណ្តឹងថ្មីនេះ ត្រូវបានកែសម្រួលឡើងវិញតាមការចាំបាច់ដើម្បីធានាថា នីតិវិធីនេះមិនលំអៀង សត្យានុម័ត មានប្រសិទ្ធភាព ដោយគិតគូរដល់ជនរងគ្រោះ និងអនុវត្តបានឆាប់រហ័ស។ ចំពោះការអនុវត្តនីតិវិធីបណ្តឹងនេះ អ្នកដាក់ពាក្យប្តឹងត្រូវគោរពតាមលក្ខខណ្ឌតម្រូវនៃការដាក់ពាក្យបណ្តឹង ដើម្បីឱ្យបណ្តឹងអាចទទួលយកបានដោយក្រុមប្រឹក្សា។ លក្ខខណ្ឌតម្រូវទាំងនេះរួមមាន៖

- មិនត្រូវបានបង្ហាញថាបណ្តឹងនេះមានចេតនាកេងចំណេញនយោបាយ ហើយកម្មវត្ថុនៃបណ្តឹងត្រូវស្របនឹងធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍ដទៃទៀតដែលនៅជាធរមានក្នុង វិស័យច្បាប់សិទ្ធិមនុស្ស
- ត្រូវផ្តល់ការអធិប្បាយពីអង្គហេតុនៃការចោទប្រកាន់ពីការរំលោភបំពានរួមទាំង សិទ្ធិទាំងឡាយដែលត្រូវបានអះអាងថាត្រូវបានរំលោភបំពាន
- ពាក្យបណ្តឹង មិនត្រូវសរសេរដោយវាយប្រហារ។ ទោះជាយ៉ាងណា ពាក្យពេជ្រវាយប្រហារទាំងនេះ នឹងមិនទុកជាលក្ខខណ្ឌទាត់ចោលបណ្តឹងទេ បើសិនជាពេលដែលលុបចេញទៅ ពាក្យបណ្តឹងនៅតែបំពេញបានតាមលក្ខ ខណ្ឌតម្រូវនៃការដាក់ពាក្យបណ្តឹង
- ពាក្យបណ្តឹងនេះ អាចដាក់ជាឯកត្តបុគ្គល ឬជាក្រុមនៃបុគ្គលដែលអះអាងថា ជាជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមុនស្ស និងសេរីភាពជាមូលដ្ឋាន ឬបណ្តឹងនេះអាចដាក់ដោយបុគ្គលណាម្នាក់ ឬក្រុមបុគ្គលណាមួយ ឬអង្គការមិនមែនរដ្ឋាភិបាល ធ្វើឡើងដោយសុទ្ធចិត្តស្របតាមគោលការណ៍សិទ្ធិមនុស្ស

- មិនត្រូវពឹងអាស្រ័យទាំងស្រុងលើព័ត៌មាន ឬរបាយការណ៍ដែលមាននៅតាមប្រព័ន្ធផ្សព្វផ្សាយ គឺត្រូវតែមាន ភស្តុតាងច្បាស់លាស់

- មិនមែនសំដៅដល់តែមួយករណីដែលបានដោះស្រាយ ឬកំពុងដោះស្រាយដោយនីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញា ឬស្ថាប័នសិទ្ធិមនុស្សដទៃទៀតទាំងនៅសហប្រជាជាតិ ទាំងនៅថ្នាក់តំបន់

- ជាករណីដែលបានប្រើប្រាស់អស់ដំណោះស្រាយក្នុងស្រុក វាលែងតែករណីនេះ ស្តែងមកថានឹងមិនមានប្រសិទ្ធភាព ឬមានការពន្យារពេលយូរហួសហេតុពេកនៅក្នុងយន្តការក្នុងស្រុក។

បើពាក្យបណ្តឹង បំពេញបានតាមលក្ខខណ្ឌតម្រូវនេះហើយ អ្នកដាក់ពាក្យបណ្តឹងអាចផ្ញើរសារអេឡិចត្រូនិចទៅកាន់៖ E-mail: CP@ohchr.org ឬទូរសារ Fax: (41 22) 917 90 11 ឬដាក់ពាក្យទៅកាន់អាស័យដ្ឋាន៖

Complaint Procedure Unit

Human Rights Council Branch

Office of the High Commissioner for Human Rights

CH-1211 Geneva 10, Switzerland

ចំពោះរូបមន្តនៃពាក្យបណ្តឹងអាចទាញយកបានតាមរយៈគេហទំព័រ៖ http://www.ohchr.org/EN/HRBodies/HRC/ComplaintProcedure/Pages/HRCComplaintProcedureIndex.aspx

## គ. យន្តការត្រួតពិនិត្យជាសកលតាមកាលកំណត់ (UPR)

យន្តការពិនិត្យជាសកលតាមកាលកំណត់ (UPR) គឺជាដំណើរការតែមួយគត់អំពីកំណត់ត្រាសិទ្ធិមនុស្សរបស់រដ្ឋសមាជិកនីមួយៗ ទាំង១៩៣ប្រទេសនៃអង្គការសហប្រជាជាតិ។ ដោយមានគោលដៅខ្ពស់បំផុត ក្នុងការធ្វើឲ្យកាន់តែប្រសើរដល់ស្ថានភាពសិទ្ធិមនុស្សនៅគ្រប់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ UPR ត្រូវបានបង្កើតឡើង ដើម្បីបង្កើន គាំទ្រ និងពង្រីកការលើកស្ទួយ និងការការពារសិទ្ធិមនុស្សនៅតាមប្រទេសនីមួយៗ។ UPR គឺជាដំណើរការខិតខំប្រឹងប្រែងរបស់រដ្ឋ ដែលផ្តល់ឱកាសដល់រដ្ឋនីមួយៗ ប្រកាសពីការចាត់វិធានការនានា ដើម្បីធ្វើឲ្យប្រសើរដល់ស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេស និងបំពេញកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួននៅចំពោះមុខរដ្ឋដទៃទៀត និងចំពោះមុខសាធារណៈជនទូទៅ។ UPR បង្កើតឱកាសផ្តល់

ជំនួយបច្ចេកទេសដល់រដ្ឋនានា និងលើកកំពស់សមត្ថភាព របស់ពួកគេក្នុងការដោះស្រាយបញ្ហាប្រឈមសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាព និងចែករំលែកការអនុវត្តន៍ល្អៗនៅក្នុងវិស័យសិទ្ធិមនុស្ស រវាងរដ្ឋនានានិងដៃគូដទៃទៀត។ ជាទិដ្ឋភាពចំបងមួយរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស UPRត្រូវបានបង្កើតឡើង ដើម្បីធានាឲ្យមានការពិនិត្យដោយស្មើភាពគ្នាដល់រដ្ឋទាំងអស់ នៅពេលស្ថានភាពសិទ្ធិមនុស្សរបស់ពួកគេត្រូវបានយកមកវាយតម្លៃម្តងៗ។ គ្រប់រដ្ឋត្រូវស្ថិតនៅក្រោមដំណើរការដូចគ្នា និងការពិនិត្យដូចគ្នាដោយមិនគិតពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សនោះទេ។ សព្វថ្ងៃនេះ មិនមានយន្តការសកលដទៃណារបៀបនេះនោះទេ។

ទិដ្ឋភាពតែមួយគត់នៃដំណើរការ UPR គឺថាវាឆ្លុះបញ្ចាំងនូវការប្រមូលផ្តុំនៃទស្សនៈអន្តរជាតិអំពីស្ថានភាពសិទ្ធិមនុស្សនៅតាមប្រទេសនីមួយៗដែលស្ថិតក្រោមការពិនិត្យ ហើយអនុសាសន៍ដែលជាលទ្ធផលពីការពិនិត្យនេះ ត្រូវបានទទួលយកដោយស្ម័គ្រចិត្ត និងជាសាធារណៈដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យ។

សម័យប្រជុំរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ត្រូវធ្វើទៀងទាត់ ៣ដង ក្នុងមួយឆ្នាំ ជាទូទៅក្នុងខែមីនាមានរយៈពេល៤សប្តាហ៍ ក្នុងខែមិថុនា មានរយៈពេល៣សប្តាហ៍ និង ក្នុងខែកញ្ញា មានរយៈពេល៣សប្តាហ៍។ ក្នុងករណីមានការស្នើសុំពីរដ្ឋសមាជិកយ៉ាងតិច១/៣ ក្រុមប្រឹក្សាសិទ្ធិមនុស្សអាចសម្រេចកោះប្រជុំពិសេសនៅពេលណាមួយក៏បាន ដើម្បីដោះស្រាយពីភាពអាសន្ន និងការរំលោភបំពានសិទ្ធិមនុស្ស។

## ដំណើរការUPR

ការពិនិត្យត្រូវធ្វើឡើងរៀងរាល់៤.៥ឆ្នាំម្តង ដោយក្រុមការងារ UPR ដែលមានសមាជិកចំនួន៤៧រដ្ឋនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស ទោះជាយ៉ាងនេះក៏ដោយ រដ្ឋសមាជិកដទៃទៀតរបស់អង្គការសហប្រជាជាតិ ក៏អាចចូលរួមក្នុងកិច្ចពិភាក្សា/សន្ទនាជាមួយរដ្ឋដែលស្ថិតនៅក្រោមការពិនិត្យផងដែរ។ រដ្ឋនីមួយៗដែលស្ថិតក្រោមការពិនិត្យ ត្រូវបានជួយដោយក្រុមនៃរដ្ឋបីដែលដឹងថាជា"troikas"ធ្វើជាអ្នករាយការណ៍។ ការជ្រើសរើស troikas សម្រាប់រដ្ឋនីមួយៗ ត្រូវធ្វើតាមរយៈការចាប់ឆ្នោត បន្ទាប់ពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្សនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ។

ការត្រួតពិនិត្យនេះ ផ្អែកលើឯកសារចំនួនបី៖

១. ព័ត៌មានដែលផ្តល់ឲ្យដោយរដ្ឋដែលស្ថិតក្រោមការពិនិត្យដែលអាចធ្វើតាមទម្រង់ជា "របាយការណ៍ជាតិ"

២. ព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់អ្នកជំនាញការ និងក្រុមឯករាជ្យខាងសិទ្ធិមនុស្ស រួមមាននីតិវិធីពិសេស ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងស្ថាប័នសហប្រជាជាតិដទៃទៀត។

៣. ព័ត៌មានពីដៃគូដទៃទៀត រួមទាំងស្ថាប័នសិទ្ធិមនុស្សជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។

UPR វាយតម្លៃពីវិសាលភាពដែលរដ្ឋគោរពកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួនដូចមានចែងក្នុង៖

(១). ធម្មនុញ្ញសហប្រជាជាតិ

(២). សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

(៣). លិខិតុបករណ៍សិទ្ធិមនុស្ស/សន្ធិសញ្ញាសិទ្ធិមនុស្សដែលរដ្ឋនោះជាភាគី/បានផ្តល់សច្ចាប័ន

(៤). ការសន្យា និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តធ្វើដោយរដ្ឋនោះ និង

(៥). ច្បាប់មនុស្សធម៌អន្តរជាតិដែលនៅជាធរមាន។

ការពិនិត្យប្រព្រឹត្តទៅតាមរយៈកិច្ចសន្ទនាគ្នាជាអន្តរកម្ម រវាងរដ្ឋស្ថិតនៅក្រោមការពិនិត្យ និងសមាជិកដទៃទៀតរបស់សហប្រជាជាតិ។ កិច្ចពិភាក្សានេះប្រព្រឹត្តទៅក្នុងអំឡុងពេលកិច្ចប្រជុំរបស់ក្រុមការងារ UPR ដែលសមា ជិកណាក៏ដោយរបស់អង្គការសហប្រជាជាតិអាចតាំងសំណួរ យោបល់ និង/ឬធ្វើអនុសាសន៍ដល់រដ្ឋដែលស្ថិតនៅក្រោមការពិនិត្យ។ រយៈពេលនៃការត្រួតពិនិត្យ គឺ៣ម៉ោង និង៣០នាទី។

បន្ទាប់ពីការពិនិត្យដោយក្រុមការងារ troikaនឹងរៀបចំរបាយការណ៍មួយ ដោយមានការចូលរួមពីរដ្ឋដែលស្ថិតក្រោមការពិនិត្យ និងជំនួយពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។ របាយការណ៍នេះដែលត្រូវទុកជា "របាយការណ៍លទ្ធផល" រៀបរាប់យ៉ាងសង្ខេបពីកិច្ចសន្ទនាគ្នានោះ។ ដូច្នេះរបាយការណ៍នេះ មានសំណួរ យោបល់ និងអនុសាសន៍ដែលដាក់ដោយរដ្ឋនានាដល់រដ្ឋដែលស្ថិតក្រោមការពិនិត្យ ព្រមទាំងការឆ្លើយតបរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យ។

ពេលវេលាត្រូវបានផ្តល់ឲ្យក្រុមការងារដើម្បីអនុម័ត "របាយការណ៍លទ្ធផល" នីមួយៗរបស់រដ្ឋដែលស្ថិតក្រោមការពិនិត្យក្នុងអំឡុងសម័យប្រជុំនោះ។ រដ្ឋដែលស្ថិតក្រោមការពិនិត្យ

មានឱកាសផ្តល់យោបល់បឋមទៅលើអនុសាសន៍នានា ជ្រើសរើសថាព្រមទទួលយកឬគ្រាន់តែធ្វើការកត់សំគាល់លើអនុសាសន៍ទាំងនោះ។ ទាំងអនុសាសន៍ដែលបានទទួលយក និងអនុ-សាសន៍ដែលគ្រាន់តែធ្វើការកត់សំគាល់ ត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍នេះ។

បន្ទាប់មក របាយការណ៍នេះ ត្រូវដាក់ជូនសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សដើម្បីទទួលការអនុម័ត។ នៅពេលនោះ រដ្ឋដែលស្ថិតក្រោមការពិនិត្យអាចឆ្លើយតបទៅនឹងសំណួរ និងបញ្ហានានាដែលមិនទាន់បានឆ្លើយគ្រប់គ្រាន់នៅអំឡុងពេលក្រុមការងារ និងឆ្លើយតបចំពោះអនុសាសន៍ ដែលត្រូវបានលើកឡើងដោយ រដ្ឋនានាក្នុងអំឡុងពេលនៃការត្រួតពិនិត្យ។ ពេលវេលាក៏មានផ្តល់ជូនរដ្ឋសមាជិក និងរដ្ឋសង្កេតការណ៍ដែរដែលចង់សំដែងមតិរបស់ខ្លួនអំពីលទ្ធផលនៃការត្រួតពិនិត្យនេះ និងក៏មានផ្តល់ជូនស្ថាប័នសិទ្ធិមនុស្សជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីផ្តល់យោបល់ជាទូទៅដែរ។

រដ្ឋដែលស្ថិតក្រោមការពិនិត្យ តែងតែមានការទទួលខុសត្រូវបឋម ដើម្បីអនុវត្តអនុសាសន៍នានាដែលមាននៅក្នុងរបាយការណ៍លទ្ធផលចុងក្រោយ។ UPR ធានាថាគ្រប់ប្រទេសត្រូវទទួលខុសត្រូវចំពោះការរីកចម្រើន ឬការខកខានក្នុងការអនុវត្តអនុសាសន៍ទាំងនេះ។ ក្នុងអំឡុងការត្រួតពិនិត្យលើកក្រោយ រដ្ឋត្រូវបានរំពឹងថា នឹងផ្តល់ព័ត៌មានអំពីវិធានការនានាដែលខ្លួនបានចាត់ឡើង ដើម្បីអនុវត្តអនុសាសន៍នានាដែលបានផ្តល់ឲ្យកាលពីលើកមុន ព្រមទាំងអំពីការវិវត្តន៍ណាមួយ នៅក្នុងវិស័យសិទ្ធិមនុស្ស។ សហគមន៍អន្តរជាតិមានតួនាទីជួយអនុវត្តអនុសាសន៍ទាំងនេះ តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងការកសាងសមត្ថភាព ដោយពិគ្រោះយោបល់ជាមួយរដ្ឋសាមី។

កម្ពុជាត្រូវបានពិនិត្យដំបូងក្រោមដំណើរការ UPR កាលពីខែធ្នូ ឆ្នាំ២០០៩។ នៅចុងបញ្ចប់នៃការពិនិត្យលើកដំបូងរបស់ខ្លួន កម្ពុជាបានទទួលយកទាំង៩១អនុសាសន៍ ដែលធ្វើឡើងដោយរដ្ឋនានា។[107] ជុំដំបូងនៃដំណើរការ UPR បានចប់សព្វគ្រប់កាលពីខែតុលា ឆ្នាំ២០១១ នៅពេលដែលរដ្ឋសមាជិកទាំងអស់១៩៣របស់អង្គការសហប្រជាជាតិត្រូវបានពិនិត្យ។ បន្ទាប់មកជុំទីពីរ បានចាប់ផ្តើម ហើយកម្ពុជាត្រូវបានពិនិត្យជាលើកទីពីរ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១៤។ គ្រប់ទិន្នន័យព័ត៌មាន ត្រូវបានដាក់ចូលសម្រាប់ការត្រួតពិនិត្យលើកទី២នេះ រួមមានរបាយការណ៍ជាតិរបស់រាជរដ្ឋាភិបាល និងកម្រងព័ត៌មានពីយន្តការសិទ្ធិមនុស្សសហប្រជាជាតិ

[107] អនុសាសន៍ទាំងនេះ អាចរកបាននៅគេហទំព័រៈ http://www.ohchr.org/EN/HRBodies/UPR/Pages/KHSession6.aspx

និងអង្គការមិនមែនរដ្ឋាភិបាល ហើយព័ត៌មានទាំងនេះ សុទ្ធតែអាចរកបាននៅក្នុងគេហទំព័ររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។[108] កិច្ចសន្ទនានៃការពិនិត្យនេះ ក៏អាចរកមើលផងដែរនៅក្នុងគេហទំព័រនេះ។[109]

## ឃ. នីតិវិធីពិសេស

នីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្សគឺជាអ្នកជំនាញការសិទ្ធិមនុស្សឯករាជ្យ ឬក្រុមនៃអ្នកជំនាញបែបនេះដែលរាយការណ៍ និងប្រឹក្សាយោបល់អំពីសិទ្ធិមនុស្សតាមទស្សនៈវិស័យប្រធានបទ ឬទស្សនៈវិស័យតាមប្រទេសជាក់លាក់។ អ្នកជំនាញការទាំងនេះរួមមាន អ្នករាយ-ការណ៍ពិសេស តំណាងពិសេស ក្រុមការងារ និងអ្នកជំនាញឯករាជ្យ។ គិតត្រឹមខែសីហា ឆ្នាំ២០១៧ ក្រុមប្រឹក្សាសិទ្ធិមនុស្ស មើលខុសត្រូវលើអាណត្តិអ្នករាយការណ៍ពិសេសតាមប្រធានបទចំនួន ៤៤ គ្របដណ្តប់លើសិទ្ធិមនុស្សទាំងអស់ ពោលគឺសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ និងអ្នករាយការណ៍ពិសេសតាមប្រទេស ចំនួន១២។

កន្លងមកមានអ្នករាយការណ៍ពិសេស តាមប្រធានបទមួយចំនួនបានមកបំពេញទស្សនកិច្ចនៅកម្ពុជាក្រៅផ្លូវការ ឬធ្លាប់ពាក់ព័ន្ធនឹងកម្ពុជា រួមមានក្រុមការងារស្តីពី ការឃុំខ្លួនតាមទំនើងចិត្ត អ្នករាយការណ៍ពិសេសស្តីពី ការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពនៃគំនិតនិងការសំដែងមតិ អ្នករាយការណ៍ពិសេសស្តីពី ស្ថានភាពអ្នកការពារសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេសស្តីពី សិទ្ធិសេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសមាគម អ្នករាយការណ៍ពិសេសស្តីពីលំនៅដ្ឋានសមរម្យ និងអ្នករាយការណ៍ពិសេសស្តីពី ការបង្ការទារុណកម្ម។

អ្នកកាន់អាណត្តិនីតិវិធីពិសេសបំរើការងារក្នុងសមត្ថភាពផ្ទាល់របស់ខ្លួន មានន័យថាពួកគេមិនមែនជាបុគ្គលិកសហប្រជាជាតិ មិនទទួលប្រាក់បៀវត្សសម្រាប់ការងារ ហើយមិនតំណាងឱ្យប្រទេសរបស់ពួកគេឬផលប្រយោជន៍ ពិសេសសម្រាប់ក្រុមណាមួយ។ អ្នកកាន់អាណត្តិនីមួយៗ អាចបំរើការងារយ៉ាងយូរ៦ឆ្នាំ។ ឋានៈឯករាជ្យនេះ មានបំណងអនុញ្ញាតឱ្យអ្នកជំនាញទាំងនេះ អនុវត្តមុខងាររបស់ខ្លួនដោយមិនលំអៀង។ ក្នុងការបំពេញការងាររបស់ខ្លួន អ្នកកាន់អាណត្តិ ទទួលបានការគាំទ្រពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួល

[108] ឯកសារទាំងនេះអាចរកបាននៅគេហទំព័រ http://www.ohchr.org/EN/HRBodies/UPR/Pages/KHSession18.aspx. ដើម្បីរកមើលការដាក់ឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារសហប្រជាជាតិនីមួយៗ សូមចុចលើរឹមទំព័រនៃគេហទំព័រនោះ។

[109] សូមមើលគេហទំព័រ៖ http://webtv.un.org/watch/cambodia-review-18th-session-of-universal-periodic-view/3119784522001/

បន្ទុកសិទ្ធិមនុស្ស(OHCHR)។ ភារកិច្ចរបស់អ្នកកាន់អាណត្តិ ត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចបង្កើត ឬបន្តអាណត្តិនីមួយៗរបស់ពួកគេ។ អ្នកកាន់អាណត្តិតាមនីតិវិធីពិសេសត្រូវរាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ ភាគច្រើននៃអ្នកកាន់អាណត្តិនេះ ក៏ត្រូវរាយការណ៍ជូនមហាសន្និបាតអង្គការសហប្រជាជាតិដែរ។

- ឃ្លាំមើលសិទ្ធិមនុស្សនៅក្នុងប្រទេសតាមអាណត្តិរៀងៗខ្លួន ឬតាមប្រធានបទជាក់លាក់
- ស្រាវជ្រាវបញ្ហាដែលជាកង្វល់ និងកោះប្រជុំពិគ្រោះយោបល់អ្នកជំនាញ
- ទស្សនកិច្ចតាមប្រទេស។ ជាទូទៅ ទស្សនកិច្ចនីមួយៗ ត្រូវតែទទួលបានការអនុញ្ញាតពីប្រទេសនោះ បើមិនមានការអនុញ្ញាតទេ អ្នកកាន់អាណត្តិមិនអាចទៅទស្សនកិច្ចជាផ្លូវការទេ តែជាទស្សនកិច្ចក្រៅផ្លូវការ។
- ទទួល និងពិចារណាបណ្តឹងដោយផ្ទាល់ ពាក់ព័ន្ធនឹងការចោទប្រកាន់ថាមានការរំលោភបំពានសិទ្ធិមុនស្សដែលស្ថិតក្នុងដែនអាណត្តិរបស់ខ្លួន
- អំពាវនាវដល់រដ្ឋាភិបាលនានា
- ឆ្លើយតបចំពោះស្ថានភាពបន្ទាន់
- ចូលរួមវិភាគទានដល់ការអភិវឌ្ឍន៍សិទ្ធិមនុស្ស
- ចូលរួមដល់ការតស៊ូមតិ លើកកំពស់ការយល់ដឹងជាសាធារណៈ និងផ្តល់ប្រឹក្សាយោបល់អំពីកិច្ចសហការបច្ចេកទេស

ក្នុងចំណោមតួនាទីទាំងអស់ខាងលើនេះ ខ្ញុំសូមលើកយកតួនាទីមួយមកអធិប្បាយ គឺយន្តការបណ្តឹង។

បណ្តឹងតាមយន្តការនីតិវិធីពិសេស អាចអន្តរាគមន៍ដោយផ្ទាល់ជាមួយរដ្ឋាភិបាល នៃរដ្ឋភាគីអំពីការចោទប្រកាន់ពីការរំលោភបំពានសិទ្ធិមនុស្ស ដែលស្ថិតនៅក្រោមអាណត្តិការងាររបស់ខ្លួនតាមមធ្យោបាយដាក់លិខិតជូនរដ្ឋភាគី ដែលរួមមានការអំពាវនាវបន្ទាន់ និងបណ្តឹងដទៃទៀត។ កិច្ចអន្តរាគមន៍អាចទាក់ទងនឹងការរំលោភបំពានសិទ្ធិមនុស្សដែលបានកើតឡើងហើយ ឬកំពុងតែកើតឡើង ឬដែលមានហានិភ័យខ្ពស់នៃការកើតឡើង។ ដំណើរការនេះ រួមមានការផ្ញើលិខិតទៅរដ្ឋភាគីសាមី ការកំណត់ពីអង្គហេតុនៃការចោទប្រកាន់ វិធាន និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលនៅជាធរមាន កង្វល់និងបញ្ហានានារបស់អ្នកកាន់អាណត្តិ និងសំណើសុំឱ្យមានការចាត់វិធានការតាមឃ្លាំមើល។ បណ្តឹងអាចដោះស្រាយតាមករណីជាឯកត្តបុគ្គលជាការរំលោភបំពានសិទ្ធិមនុស្សជាប្រព័ន្ធ ឬជាករណីដែលប៉ះពាល់ដល់ក្រុមណាមួយ ឬសហ-គមន៍ដោយឡែកណាមួយ ឬក៏ជាបណ្តឹងទាក់ទងនឹងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬច្បាប់

ដែលចូលជាធរមាន គោលនយោបាយ ឬការអនុវត្តណាមួយដែលត្រូវចាត់ទុកថា មិនស្រប ទាំងស្រុងតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

ការសម្រេចថាត្រូវអន្តរាគមន៍ គឺអាស្រ័យតាមឆន្ទានុសិទ្ធិរបស់អ្នកកាន់អាណត្តិ និងត្រូវអាស្រ័យលើគុណវុឌ្ឍន៍នានាដែលបង្កើតឡើងតាមអាណត្តិរបស់គេរៀងៗខ្លួន ព្រមទាំងគុណវុឌ្ឍន៍ដែលមានចែងនៅក្នុងក្រមប្រតិបត្តិ។ ជាទូទៅ គុណវុឌ្ឍន៍ត្រូវទាក់ទងនឹងភាពដែលអាចទុកចិត្តបាននៃប្រភព និងភាពជឿជាក់បាននៃព័ត៌មានដែលបានទទួល ភាពពិស្តារនៃព័ត៌មាន និងដែនសមត្ថកិច្ចនៃអាណត្តិរបស់ខ្លួន។

ដើម្បីឱ្យបណ្តឹងអាចយកមកវាយតម្លៃបាន ពាក្យបណ្តឹងត្រូវមាន៖

- អត្តសញ្ញាណជនរងគ្រោះ
- អត្តសញ្ញាណជនជាប់ចោទ ដែលត្រូវចោទប្រកាន់ពីការរំលោភបំពាននោះ (ប្រសិនជាស្គាល់) រួមទាំងព័ត៌មានសំខាន់ៗអំពីតួអង្គពាក់ព័ន្ធទាំងអស់ រាប់ទាំងតួអង្គមិនមែនជារដ្ឋ ប្រសិនបើមាន។
- អត្តសញ្ញាណជន ឬអង្គការដែលដាក់ពាក្យបណ្តឹង ប្រសិនបើផ្សេងពីជនរងគ្រោះ (ព័ត៌មាននេះ នឹងត្រូវរក្សាជាការសម្ងាត់)
- កាលបរិច្ឆេទ ទីកន្លែង និងការអធិប្បាយពិស្តារពីកាលៈទេសៈនៃរឿងហេតុ ឬការរំលោភបំពាន
- ត្រូវចងចាំថា នៅក្នុងពាក្យបណ្តឹង ជនរងគ្រោះ គ្រួសារជនរងគ្រោះ ឬតំណាង គួសបង្ហាញឱ្យបានច្បាស់ថា ខ្លួនបានយល់ព្រម ឬមិនយល់ព្រម
    - ឱ្យបង្ហាញអត្តសញ្ញាណជនរងគ្រោះដល់រដ្ឋាភិបាល នៅក្នុងសំណៅឆ្លើយឆ្លងរវាងនីតិវិធីពិសេស និងរដ្ឋភាគី
    - អត្តសញ្ញាណរបស់ជនរងគ្រោះមានដាក់នៅក្នុង របាយការណ៍ជាសាធារណៈដាក់ទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស។
- ព័ត៌មានពិស្តារដទៃទៀតអាចនឹងតម្រូវឱ្យបំពេញបន្ថែម ទៅតាមប្រភេទជាក់លាក់នៃការរំលោភបំពាន អាស្រ័យទៅតាមការទាមទាររបស់អាណត្តិនីមួយៗ

- បណ្ដឹងទាំងឡាយណាដែលប្រើប្រាស់ពាក្យពេជន៍វាយប្រហារ ឬមានហេតុផលនយោបាយយ៉ាងជាក់ច្បាស់មិនត្រូវយកមកពិចារណាទេ។ ពាក្យបណ្ដឹងមិនត្រូវពឹងផ្អែកទាំងស្រុងតែលើព័ត៌មានដែលមាននៅតាមសារព័ត៌មាននោះទេ។

ទម្រង់នៃពាក្យបណ្ដឹង អាចរកបានតាមគេហទំព័រដូចមានភ្ជាប់មកនេះ ហើយដើម្បីជួយសម្រួលដល់ការដាក់ពាក្យបណ្ដឹង ពេលបំពេញតាមការទាមទារនៃទម្រង់នេះហើយ គ្រាន់តែចុចត្រង់ដាក់ពាក្យបណ្ដឹងជាការស្រេច៖

https://spsubmission.ohchr.org/

ពាក្យបណ្ដឹងក៏អាចទទួលបានដែរ ទោះបីមិនបានធ្វើតាមទម្រង់ដែលផ្ដល់ឱ្យនេះក៏ដោយ តែត្រូវធ្វើតាមសារអេឡិចត្រូនិចទៅកាន់៖urgent-action@ohchr.org ឬផ្ញើតាមប្រៃសណីយ៍ទៅ៖

OHCHR-UNOG
8-14 Avenue de la Paix
1211 Geneva 10
Switzerland

ដោយឡែកអាណត្តិរបស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក៏ដូចអ្នកកាន់អាណត្តិ ពិសេសដទៃទៀតដែរ គឺត្រូវបានបោះឆ្នោតជ្រើសតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស គ្រាន់តែអាណត្តិសម្រាប់កម្ពុជាគឺត្រូវបានបង្កើតឡើងដោយផ្អែកលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដែលបានចុះហត្ថលេខាកាលពីឆ្នាំ១៩៩១។ តួនាទីរបស់អ្នករាយការណ៍ពិសេស គឺវាយតម្លៃអំពីស្ថានភាពសិទ្ធិមនុស្ស រាយការណ៍ជាសាធារណៈពីស្ថានភាពនេះ និងធ្វើការជាមួយរដ្ឋាភិបាល សង្គមស៊ីវិលនិងអ្នកដទៃទៀត ដើម្បីជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិនៅក្នុងវិស័យនេះ។ អ្នករាយការណ៍ពិសេសធ្វើទស្សនកិច្ច ឬបំពេញបេសកកម្មទៀងទាត់មកកាន់កម្ពុជា និងរាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស។ អ្នករាយការណ៍ពិសេសសព្វថ្ងៃគឺ លោកស្រីសាស្ត្រាចារ្យ រ៉ូណា ស្មីត (ជនជាតិអង់គ្លេស) លោកស្រីត្រូវបានតែងតាំងជាអ្នករាយការណ៍ពិសេស កាលពីខែមីនា ឆ្នាំ២០១៥។ មុនអាណត្តិរបស់លោកស្រី គឺលោកសូរិយាប្រាសាទ ស៊ូប៉ៃឌី (ជនជាតិនេប៉ាល់) លោកជាសាស្ត្រាចារ្យសកលវិទ្យាល័យ លីដ ចក្រភពអង់គ្លេស។ លោកកាន់អាណត្តិនេះពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥។

មុនអ្នករាយការណ៍ពិសេសទាំងពីររូបនេះ អ្នកកាន់អាណត្តិនេះសម្រាប់កម្ពុជា ត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ហេតុដូច្នេះមានឈ្មោះហៅផ្លូវការ

ថា តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលមានអាណត្តិជាបន្តបន្ទាប់ដូចខាងក្រោម៖

១- លោកចៅក្រម មៃឃើល ឃឺប៊ី (ជនជាតិអូស្ត្រាលី)៖ ១៩៩៣-១៩៩៦

២- លោក តូម៉ាស់ ហាំម៉ាប៊ឺហ្គ (ជនជាតិស៊ុយអ៊ែត)៖ ១៩៩៦-២០០០

៣- លោកសាស្ត្រាចារ្យ ភីតធី ព្ទយព្រេច (ជនជាតិអូទ្រីស)៖ ២០០០-២០០៥ លោកក៏ជាព្រឹទ្ធបុរសនៃសកលវិទ្យាល័យច្បាប់នៅ កាណាដា

៤- លោកសាស្ត្រាចារ្យ យ៉ាស់ ហ្គាយ (ជនជាតិកេនយ៉ា)៖ ២០០៥-២០០៨ លោកជាសាស្ត្រាចារ្យច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅសកលវិទ្យាល័យ ហុងកុង។

## ៣. ស្ថាប័នសន្ធិសញ្ញា

ជាថ្មីម្តងទៀត ស្ថាប័នសន្ធិសញ្ញាគឺជាស្ថាប័នដែលបង្កើតឡើងដោយសន្ធិសញ្ញាសិទ្ធិមនុស្សនីមួយៗ។ សន្ធិសញ្ញា ចងកាតព្វកិច្ចផ្លូវច្បាប់ដល់រដ្ឋនានាដែលទទួលយកដោយស្ម័គ្រចិត្ត និងអនុម័តដោយរដ្ឋសមាជិកនានាក្នុងក្របខ័ណ្ឌមហាសន្និបាតអង្គការសហប្រជាជាតិ។ ជាទូទៅរដ្ឋភាគីត្រូវជាប់កាតព្វកិច្ចស្នូលចំនួនបីតាមសន្ធិសញ្ញាសិទ្ធិមនុស្ស៖

- កាតព្វកិច្ច***គោរព៖*** មិនធ្វើអ្វីឱ្យប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិនានា ដោយជៀសវាងការរំលោភសិទ្ធិ
- កាតព្វកិច្ច***ការពារ៖*** គឺបង្ការការរំលោភសិទ្ធិនានា តាមរយៈការអនុម័តគោលនយោបាយ ច្បាប់ ឬលិខិតបទដ្ឋាននានាដើម្បីធានាការពារដល់ការអនុវត្តសិទ្ធិនានា
- កាតព្វកិច្ច***បំពេញ៖*** ចាត់វិធានការដើម្បីធានាការសម្រេចបានសិទ្ធិនានា

រហូតមកដល់ពេលនេះ សន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗទាំងអស់មាន៩ និងមានអមដោយពិធីសារបន្ថែមមួយ ឬច្រើន។ សន្ធិសញ្ញាសិទ្ធិមនុស្សទាំងនេះ រួមមាន៖

### ៣.១. អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥ និងចូលជាធរមាននៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៦៩។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៨៣។ អនុសញ្ញានេះ បង្កើតស្ថាប័នសន្ធិសញ្ញាមួយ តាមមាត្រា៨ គឺគណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មានសមាជិក១៨រូប។ រដ្ឋភាគីជាប់កាតព្វកិច្ច

ត្រូវដាក់របាយការណ៍បឋមក្នុងរយៈពេល១ឆ្នាំ ក្រោយពីចូលជារដ្ឋភាគី និងរបាយការណ៍បន្ទាប់នៅរៀងរាល់ពីរឆ្នាំ។

## ៣.២ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។ កតិកាសញ្ញានេះ បង្កើតស្ថាប័នសន្ធិសញ្ញាមួយ តាមមាត្រា២៨ គឺគណៈកម្មាធិការសិទ្ធិមនុស្សមានសមាជិក១៨រូប។ រដ្ឋភាគីជាប់កាតព្វកិច្ច ត្រូវដាក់របាយការណ៍បឋមក្នុងរយៈពេល១ឆ្នាំ ក្រោយពីចូលជារដ្ឋភាគី និងរបាយការណ៍បន្ទាប់ នៅរៀងរាល់៤ឆ្នាំម្តង។

- ពិធីសារបន្ថែមទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយទាក់ទងនឹងការទទួលយកនីតិវិធីបណ្តឹងត្រូវបានអនុម័តដោយ មហាសន្និបាតអង្គការសហប្រជា-ជាតិ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។ កម្ពុជាបានចុះហត្ថលេខាលើពិធីសារបន្ថែមនេះ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤
- ពិធីសារបន្ថែមទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយសំដៅលុបបំបាត់ទោសប្រហារជីវិតត្រូវបានអនុម័តដោយមហា សន្និបាតអង្គការសហ-ប្រជាជាតិនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៨៩ និងចូលជាធរមាននៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩១។ កម្ពុជាមិនទាន់បានផ្តល់សច្ចាប័ននៅឡើយទេ។

## ៣.៣ កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។ កតិកាសញ្ញានេះបានប្រគល់តួនាទីឱ្យក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ជាអ្នកឃ្លាំមើលការអនុវត្តកតិកាសញ្ញានេះ តាមមាត្រា១៦ និងមាត្រា១៧។ រហូតដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៨៥ ទើបគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ត្រូវបានបង្កើតឡើង ដើម្បីអនុវត្តមុខងារនេះតាមសេចក្តីសម្រេចលេខ១៩៨៥/១៧ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម។ គណៈកម្មាធិការនេះមានសមាជិក១៨រូប។ រដ្ឋភាគីជាប់កាតព្វកិច្ចត្រូវដាក់របាយការណ៍បឋមក្នុងរយៈពេល១ឆ្នាំ ក្រោយពីចូលជារដ្ឋភាគី និងរបាយការណ៍បន្ទាប់ នៅរៀងរាល់៥ឆ្នាំម្តង។

- ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទាក់ទងនឹងការទទួលយកនីតិវិធីបណ្តឹងត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជា-

ជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ និងចូលជាធរមាននៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៣។ កម្ពុជាមិនទាន់បានផ្តល់សច្ចាប័ននៅឡើយទេ។

## ៣.៤ អនុសញ្ញាអន្តរជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ និងចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ អនុសញ្ញានេះ បង្កើតស្ថាប័នសន្ធិសញ្ញាមួយ តាមមាត្រា១៧ គឺគណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទមានសមាជិក១៨រូប។ រដ្ឋភាគីជាប់កាតព្វកិច្ចត្រូវដាក់របាយការណ៍បឋមក្នុងរយៈពេល១ឆ្នាំ ក្រោយពីចូលជារដ្ឋភាគី និងរបាយការណ៍បន្ទាប់នៅរៀងរាល់៤ឆ្នាំ។

- ពិធីសារបន្ថែមនៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី៦ តុលា ឆ្នាំ១៩៩៩ និងចូលជាធរមាន នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០។ ជាពិធីសារបន្ថែមមួយដែលបើកសិទ្ធិឱ្យមានការប្តឹងផ្ទាល់ទៅគណៈកម្មាធិការស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងនារីភេទ។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៣ តុលា ឆ្នាំ២០១០។

## ៣.៥ អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ និងចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ អនុសញ្ញានេះ បង្កើតស្ថាប័នសន្ធិសញ្ញាមួយ តាមមាត្រា១៧ គឺគណៈកម្មាធិការប្រឆាំងទារុណកម្ម មានសមាជិក១០រូប។ រដ្ឋភាគីជាប់កាតព្វកិច្ច ត្រូវដាក់របាយការណ៍បឋមក្នុងរយៈពេល១ឆ្នាំ ក្រោយពីចូលជារដ្ឋភាគី និងរបាយការណ៍បន្ទាប់ នៅរៀងរាល់៤ឆ្នាំម្តង។

- ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្មនិងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ និងចូលជាធរមាននៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦។ គឺជាពិធីសារបន្ថែមមួយដែលមិនបានបង្កើតនីតិវិធីបណ្តឹងទេ

តែបានបង្កើតអនុគណៈកម្មាធិការបង្ការទារុណកម្មដែលមានតួនាទី និងអាណត្តិចុះទៅត្រួតពិនិត្យកន្លែងដកហូតសេរីភាពទាំងអស់របស់រដ្ឋភាគី។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧ ហើយអនុគណៈកម្មាធិការបង្ការទារុណកម្ម ធ្លាប់ចុះមកទស្សនកិច្ចកម្ពុជាយើងចំនួន២ដងរួចមកហើយ។

## ៣.៦ អនុសញ្ញាស្តីពីសិទ្ធិកុមារ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ និងចូលជាធរមាននៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩០។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ អនុសញ្ញានេះ បង្កើតស្ថាប័នសន្ធិសញ្ញាមួយ តាមមាត្រា៤២ គឺគណៈកម្មាធិការស្តីពីសិទ្ធិកុមារ មានសមាជិក១០រូប។ រដ្ឋភាគីជាប់កាតព្វកិច្ច ត្រូវដាក់របាយការណ៍បឋមក្នុងរយៈពេល២ឆ្នាំ ក្រោយពីចូលជារដ្ឋភាគី និងរបាយការណ៍បន្ទាប់ នៅរៀងរាល់៥ឆ្នាំម្តង។

- ពិធីសារបន្ថែមទី១នៃអនុសញ្ញាស្តីពី សិទ្ធិកុមារពាក់ព័ន្ធនឹងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០ និងចូលជាធរមាននៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤។
- ពិធីសារបន្ថែមទី២នៃអនុសញ្ញាស្តីពី សិទ្ធិកុមារពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងរូបភាព/សម្ភារៈអាសអាភាសកុមារ ត្រូវបានអនុម័តដោយ មហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០ និងចូលជាធរមាននៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២។
- ពិធីសារបន្ថែមទី៣ នៃអនុសញ្ញាស្តីពី សិទ្ធិកុមារពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹង ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១ និងចូលជាធរមាននៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៤។ កម្ពុជាមិនទាន់បានផ្តល់សច្ចាប័ននៅឡើយទេ។

### ៣.៧ អនុសញ្ញាស្តីពីការការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូបនិងសមាជិកគ្រួសាររបស់ពួកគេ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩០ និងចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៣។ កម្ពុជាបានចុះហត្ថលេខា នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤។ អនុសញ្ញានេះបង្កើតស្ថាប័នសន្ធិសញ្ញាមួយ តាមមាត្រា៧២ គឺគណៈកម្មាធិការសម្រាប់ការពារសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសាររបស់ពួកគេមានសមាជិក១៤រូប។ រដ្ឋភាគីជាប់កាតព្វកិច្ច ត្រូវដាក់របាយការណ៍បឋមក្នុងរយៈពេល១ឆ្នាំ ក្រោយពីចូលជារដ្ឋភាគី និងរបាយការណ៍បន្ទាប់នៅរៀងរាល់៥ឆ្នាំម្តង។

### ៣.៨ អនុសញ្ញាស្តីពីសិទ្ធិជនពិការ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ និងចូលជាធរមាននៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨។ កម្ពុជាក្លាយជារដ្ឋភាគីនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។ អនុសញ្ញានេះ បង្កើតស្ថាប័នសន្ធិសញ្ញាមួយ តាមមាត្រា៣៤ គឺគណៈកម្មាធិការស្តីពីសិទ្ធិជនពិការ មានសមាជិក១៨ រូប។ រដ្ឋភាគីជាប់កាតព្វកិច្ចត្រូវដាក់របាយការណ៍បឋមក្នុងរយៈពេល២ឆ្នាំ ក្រោយពីចូលជារដ្ឋភាគី និងរបាយការណ៍បន្ទាប់ នៅរៀងរាល់៤ឆ្នាំម្តង។

- ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ និងចូលជាធរមាននៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០០៨។ កម្ពុជាបានចុះហត្ថលេខា នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០០៧។

### ៣.៩ អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ

ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៦ និងចូលជាធរមាននៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១០។ កម្ពុជាក្លាយជារដ្ឋភាគី នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣។ អនុសញ្ញានេះ បង្កើតស្ថាប័នសន្ធិសញ្ញាមួយ តាមមាត្រា២៦ គឺគណៈកម្មាធិការទទួលបន្ទុកការបាត់ខ្លួនដោយបង្ខំ មានសមាជិក១០រូប។ រដ្ឋភាគីជាប់កាតព្វកិច្ចត្រូវដាក់របាយ-ការណ៍រៀងរាល់២ឆ្នាំម្តង ក្រោយពីចូលជារដ្ឋភាគី។

ដូច្នេះ តាមសន្ធិសញ្ញាទាំង៩ខាងលើ ស្ថាប័នសន្ធិសញ្ញាក៏ត្រូវមាន៩ស្ថាប័នដែរ ដោយបូករួមនឹងអនុគណៈកម្មាធិការបង្ការទារុណកម្ម ដែលបង្កើតឡើងដោយពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងទារុណកម្មផង សរុបទាំងអស់មានស្ថាប័នសន្ធិសញ្ញាចំនួន១០។

ជារួមស្ថាប័នសន្ធិសញ្ញាមានសមាសភាពជា

- អ្នកជំនាញឯករាជ្យដែលបានចាត់តាំង និងជ្រើសតាំងដោយរដ្ឋភាគីសម្រាប់អាណត្តិ៤ឆ្នាំ។
- សមាជិកភាព៖ ចាប់ពី១០ ទៅ ២៥នាក់ អាស្រ័យតាមគណៈកម្មាធិការនីមួយៗ។ បច្ចុប្បន្នមានសមាជិកសរុបចំនួន១៧២នាក់ ក្នុងស្ថាប័នសន្ធិសញ្ញាចំនួន១០។
- លក្ខណៈវិនិច្ឆ័យ៖ ជំនាញ ការចែងចែកស្មើគ្នាតាមភូមិសាស្ត្រ ភាពជាតំណាងនៃប្រព័ន្ធច្បាប់ចម្បងៗ និងទម្រង់ផ្សេងៗគ្នានៃអារ្យធម៌ និងភាពជាតំណាងយេនឌ័រដែលមានតុល្យភាពគ្នា
- មិនយកប្រាក់បៀវត្ស ហើយបម្រើការផ្អែកលើសមត្ថភាពរបស់ខ្លួនផ្ទាល់

ស្ថាប័នសន្ធិសញ្ញាទាំងនេះ ត្រូវបានបង្កើតឡើងដើម្បីឃ្លាំមើលការអនុវត្តកាតព្វកិច្ចតាមសន្ធិសញ្ញារបស់រដ្ឋភាគីតាមរយៈ៖

- ការពិនិត្យរបាយការណ៍របស់រដ្ឋភាគី
- ការពិនិត្យលើបណ្តឹង
- ការចុះទៅទស្សនកិច្ចរដ្ឋភាគីតាមរយៈបណ្តឹង។ ពេលទទួលបានបណ្តឹង ស្ថាប័នសន្ធិសញ្ញាអាចបើកការស៊ើបសួរ។ ការស៊ើបសួរអាចធ្វើបានលើឯកសារភស្តុតាងដែលផ្តល់ឱ្យ ឬចុះទៅទស្សនកិច្ចដល់ទីកន្លែង របស់រដ្ឋភាគី។ បើរដ្ឋភាគីមិនអនុញ្ញាត ការចុះទៅស៊ើបសួរដល់កន្លែងក៏មិនអាចធ្វើបានដែរ។

` ក្រៅពីនេះ ស្ថាប័នសន្ធិសញ្ញា មានកិច្ចការពីរធំទៀត គឺការពិគ្រោះយោបល់លើប្រធានបទដែលជាកង្វល់របស់ខ្លួន និងការអនុម័តសេចក្តីពន្យល់ទូទៅនៃបទប្បញ្ញត្តិនានារបស់សន្ធិសញ្ញាដែលខ្លួនទទួលបន្ទុក។

ចំពោះយន្តការបណ្តឹងតាមស្ថាប័នសន្ធិសញ្ញា គណៈកម្មាធិការនីមួយៗអាចពិចារណាលើពាក្យបណ្តឹងរបស់បុគ្គលដែលជឿថាសិទ្ធិរបស់ខ្លួនត្រូវបានគេរំលោភបំពាន។ លក្ខខណ្ឌទូទៅនៃការទទួលយកបាននៃបណ្តឹង៖

- រដ្ឋត្រូវតែជារដ្ឋភាគីនៃសន្ធិសញ្ញានោះ
- រដ្ឋត្រូវតែជារដ្ឋភាគីដែលបានយល់ព្រមទទួលយកនីតិវិធីបណ្តឹងលក្ខណៈជាបុគ្គល

- ការប្រើប្រាស់អស់មធ្យោបាយ ឬលទ្ធភាពក្នុងការដោះស្រាយបណ្តឹងនេះនៅថ្នាក់ជាតិ ឬនៅក្នុងស្រុក ឬការដោះស្រាយនោះ ប្រើពេលយូរហួសហេតុពេក។
- មិនធ្លាប់ប្តឹងទៅយន្តការអន្តរជាតិណាមួយ ឬស្ថាប័នសន្ធិសញ្ញាអន្តរជាតិផ្សេងទៀត
- ការរំលោភបំពាននេះ ត្រូវតែកើតឡើងនៅពេលដែលរដ្ឋនោះក្លាយជារដ្ឋភាគី ឬបានកើតឡើងហើយបន្តរហូតដល់ពេលរដ្ឋនោះក្លាយជារដ្ឋភាគី។
- និងមានលក្ខខណ្ឌជាច្រើនទៀត អាស្រ័យតាមលក្ខណៈវិនិច្ឆ័យរបស់សន្ធិសញ្ញានីមួយៗ។

ក្នុងចំណោមស្ថាប័នសន្ធិសញ្ញាទាំង១០ មានតែអនុគណៈកម្មការបង្ការទារុណកម្ម (SPT) មួយគត់ដែលមិនទទួលពាក្យបណ្តឹង។ វាជាស្ថាប័នមួយបង្កើតឡើងដោយពិធីសារបន្ថែម នៃអនុសញ្ញាប្រឆាំងទារុណកម្ម មានអាណត្តិការងារចុះទៅពិនិត្យមើលទីកន្លែងដកហូតសេរីភាពទាំងអស់នៅគ្រប់រដ្ឋភាគី ក្នុងគោលបំណងបង្ការទារុណកម្ម។ ទីកន្លែងដកហូតសេរីភាពមានដូចជាពន្ធនាគារ មណ្ឌលឃុំខ្លួនរបស់នគរបាលយុត្តិធម៌ មណ្ឌលសង្គមកិច្ច មណ្ឌលបន្សាបគ្រឿងញៀន មន្ទីរពេទ្យឆ្កួត កន្លែងដាក់វិន័យ-ទណ្ឌកម្មនៅតាមសាលា...។ល។



<u>ឯកសារយោង៖</u>


- http://www.un.org/en/index.html
- http://www.ohchr.org/EN/pages/home.aspx
- http://cambodia.ohchr.org/
- ធម្មនុញ្ញសហប្រជាជាតិ
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍
- អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ
- អនុសញ្ញាស្តីពីសិទ្ធិកុមារ
- អនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ
- អនុសញ្ញាស្តីពី ការការពារពលករទេសន្តរប្រវេសន៍គ្រប់រូប និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ
- អនុសញ្ញាស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ

# សកម្មភាពរបស់គណៈមេធាវី
# នៃព្រះរាជាណាចក្រកម្ពុជា

# ១. ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ១.១ ទំនាក់ទំនងជាតិ

### ការចូលជួបសម្តែងការគួរសម ជាមួយសម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី

នៅវេលាម៉ោង ៤ រសៀល នាថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រមុខរដ្ឋស្តីទី បានអនុញ្ញាតឱ្យលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី អគ្គលេខាធិការ អគ្គលេខាធិការរង គណៈមេធាវី ចូលជួបសម្តែងការគួរសមនៅវិមានរដ្ឋចំការមន។

ទន្ទឹមនឹងនេះ លោកមេធាវី សួន វិសាល ក៏បានរាយការណ៍ជូនសម្តេចវិបុលសេនាភក្តី ផងដែរ អំពីកិច្ចខិតខំប្រឹងប្រែងរបស់គណៈមេធាវីក្នុងការជួយការពារក្តីជូនជនក្រីក្រដោយឥតយកកម្រៃ។

ឆ្លើយតបទៅនឹងសកម្មភាពយ៉ាងសកម្ម និងជោគជ័យរបស់គណៈមេធាវីក្នុងអាណត្តិទី១១នេះ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រមុខរដ្ឋស្តីទី បានសម្តែងនូវការគាំទ្រ និងជម្រុញឱ្យគណៈមេធាវីបន្តកិច្ចការងារទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងបុព្វហេតុសង្គម បុព្វហេតុជាតិ និងមាតុភូមិនៃព្រះរាជាណាចក្រកម្ពុជា ហើយសម្តេចបានចូលរួមចំណែកថវិកាចំនួន៥០លានរៀលជូនគណៈមេធាវីដើម្បីចាត់ចែង និងប្រើប្រាស់ជាប្រយោជន៍សង្គម។ ទន្ទឹមនឹងនេះ សម្តេចវិបុលសេនាភក្តីបានមានប្រសាសន៍គាំទ្រមហាសន្និបាតគណៈមេធាវីលើកទី២២ ដែលនឹងគ្រោងធ្វើឡើងនៅសណ្ឋាគារសុខាភ្នំពេញនាថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ ខាងមុខនេះ។

ឆ្លើយតបទៅនឹងទឹកចិត្តដ៏ថ្លៃថ្លារបស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តំណាងឱ្យសមាជិក-សមាជិកាគណៈមេធាវីទាំងអស់បានគោរពថ្លែងអំណរគុណចំពោះ **សម្តេចវិបុលសេនាភក្តី** និងបានប្តេជ្ញាចិត្តបន្តរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក៏ដូចជា អង្គនីតិប្បញ្ញត្តិក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ។



## ក្រសួងមហាផ្ទៃបានឯកភាពតាមការស្នើសុំរបស់ប្រធានគណៈមេធាវី

ក្រោយពីការជួបសំដែងការគួរសមរបស់លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី ជាមួយ**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧មក។ កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧ លោកប្រធានគណៈមេធាវី បានដាក់សំណើរជាផ្លូវការស្នើសុំកិច្ចសហការរវាងក្រសួងមហាផ្ទៃ និងគណៈមេធាវី ដែលនៅក្នុង សំណើនោះផ្តោតសំខាន់លើការអនុញ្ញាតឲ្យមេធាវីអាចថតសំណុំរឿង បានជួបកូនក្តី និងអាចអម

កូនក្តីក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌បាន។ ឆ្លើយតបនឹងសំណើទាំងនេះ នៅថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១៧ ក្រសួងមហាផ្ទៃបានយល់ព្រមទាំងស្រុង លើសំណើរបស់លោកប្រធានគណៈមេធាវី ចំពោះកិច្ចសហការគ្នារវាងក្រសួងមហាផ្ទៃ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានគណៈមេធាវី**

មេធាវី សុន ទិសាល

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី សាំង ចន្ទ្រា:
២-មេធាវី អ៊ឹង គិរិយា
៣-មេធាវី កែត យី
៤-មេធាវី អ៊ឹម ប៉ូលី
៥-មេធាវី ខៀវ សំបុរ
៦-មេធាវី ជា សុកខួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជុ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីម សុវណ្ណា
១៤-មេធាវី ឈឹម តិរមៀ
១៥-មេធាវី សំ សុគង់
១៦-មេធាវី ឧង មានឌួ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម ទិស្សុត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ ទិសាល
២២-មេធាវី ហូ លីហួច
២៣-មេធាវី ម៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន ទិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ

លេខ ២៣៤២ /គម/១៧

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** ÷ សូមគោរពស្នើសុំកិច្ចសហការរវាងក្រសួងមហាផ្ទៃ និងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

**យោង** ÷ ស្មារតីនៃកិច្ចជំនួបសម្តែងការគួរសម **សម្តេចក្រឡាហោម** កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមអនុញ្ញាតគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា ខ្ញុំបាទប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចក្រឡាហោម** ដែលបានអនុញ្ញាតឱ្យប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចូលជួបសម្តែងការគួរសមកាលពីរសៀលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧ និងបានផ្តល់ឱកាសឱ្យខ្ញុំបាទបានរាយការណ៍ជូន **សម្តេចក្រឡាហោម** ពីសកម្មភាពការងារ និងកំណែទម្រង់នានារបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងអាណត្តិទី១១នេះ ជាពិសេស បានផ្តល់ឱកាសឱ្យខ្ញុំបាទបានជម្រាបជូន **សម្តេចក្រឡាហោម** ពីបញ្ហាប្រឈមនានាក្នុងការអនុវត្តវិជ្ជាជីវៈមេធាវីកន្លងមក។

អនុវត្តតាមអនុសាសន៍ណែនាំរបស់ **សម្តេចក្រឡាហោម** និងដើម្បីរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា សូមគោរពស្នើសុំកិច្ចសហការជាមួយក្រសួងមហាផ្ទៃដូចខាងក្រោម៖

១- គោរពស្នើសុំអនុញ្ញាតឱ្យមេធាវីបានជួបកូនក្តី និងអាចអមកូនក្តីក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ ~

អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

២- គោរពស្នើសុំអនុញ្ញាតឱ្យមេធាវីបានថតសំណុំរឿងពាក់ព័ន្ធនឹងកូនក្ដីក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ។

៣- គោរពស្នើសុំកិច្ចសហការក្នុងការអនុញ្ញាតឱ្យមេធាវីបានជួបប្រាស្រ័យទាក់ទងការងារជាមួយកូនក្ដីដែលជាប់ក្នុងពន្ធនាគារ តាមនីតិវិធីច្បាប់ជាធរមាន ។

៤- គោរពស្នើសុំកិច្ចសហការក្នុងការអនុញ្ញាតឱ្យមេធាវីបានជួយបណ្ដុះបណ្ដាលមន្ត្រីនគរបាលយុត្តិធម៌ ពីច្បាប់ពាក់ព័ន្ធនានានៅរាជបណ្ឌិតសភានគរបាល ។

៥- គោរពស្នើសុំ **សម្ដេចក្រឡាហោម** ជួយគាំទ្រចំពោះសំណើសុំបន្ថែមកញ្ចប់ថវិការាជរដ្ឋាភិបាលសម្រាប់ការពារក្ដីជូនជនក្រីក្រ ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្ដេចក្រឡាហោម** មេត្តាពិនិត្យសម្រេចតាមសំណើដោយសេចក្ដីអនុគ្រោះបំផុត និងមានមតិណែនាំដ៏ខ្ពង់ខ្ពស់ ។

សូម **សម្ដេចក្រឡាហោម** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧

**ប្រធាន**

មេធាវី សុខ_វិសាល

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ...១៦១៧...សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៧

**ជម្រាបជូន**

**ឯកឧត្តម ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ**: ស្ដីពីសំណើស្នើសុំកិច្ចសហការរវាងក្រសួងមហាផ្ទៃ និងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

**យោង** : - បំណាររដ៏ខ្ពង់ខ្ពស់របស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧

- លិខិតលេខ ២៦៤២/គម/១៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម ប្រធាន** ជ្រាបថា ក្រសួងមហាផ្ទៃ ឯកភាពចំពោះសំណើរបស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំកិច្ចសហការជាមួយក្រសួងមហាផ្ទៃ។ ដោយឡែក ចំពោះការស្នើសុំបន្ថែមកញ្ចប់ថវិកាសម្រាប់ការពារក្ដីជូនជនក្រីក្ររបស់គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ សូមគាំទ្រជានិច្ចនូវរាល់សកម្មភាពការងារការពារក្ដីជូនជនក្រីក្រ ប៉ុន្តែរាល់ការសម្រេចលើសំណើនេះ ជាសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា** ជ្រាបតាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ៕

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ព្រុំ សុខា

ចម្លងជូន:
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ (ដើម្បីជូនជ្រាប)
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានពន្ធនាគារ
- បណ្ឌិត្យសភាននគរបាលកម្ពុជា (ដើម្បីជាសមត្ថកិច្ច)
- ឯកសារ-កាលប្បវត្តិ

ទីស្ដីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

## សកម្មភាពលោកប្រធាន និងប្រតិភូគណៈមេធាវី ចុះពិភាក្សាការងារជាមួយលោកប្រធានសាលាដំបូងខេត្តព្រៃវែង និងខេត្តស្វាយរៀង

នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូគណៈមេធាវី រួមមានលោកមេធាវី អ៊ឹង គិរិយា លោកមេធាវី សេង សុខឃីម និងលោកមេធាវី ថាន ផានិត សមាជិកក្រុមប្រឹក្សាគណៈមេធាវី ធ្វើដំណើរទៅកាន់សាលាដំបូងខេត្តព្រៃវែង និងខេត្តស្វាយរៀង ដើម្បីប្រជុំពិភាក្សាការងារជាមួយលោកប្រធានតុលាការខេត្ត ព្រះរាជអាជ្ញា និងមេធាវីប្រចាំខេត្ត ពាក់ព័ន្ធនឹងបញ្ហាប្រឈមក្នុងការប្រកបវិជ្ជាជីវៈមេធាវី ការការពារក្តី ក្នុងវិស័យយុត្តិធម៌ព្រមទាំងកិច្ចសហការផ្សេងៗទៀត។



## លោកប្រធានគណៈមេធាវីពិភាក្សាការងារជាមួយលោកប្រធានតុលាការខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ

នាថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូគណៈមេធាវី រួមមានលោកមេធាវី ជូ ចាន់ធីរ៉ា លោកមេធាវី វ៉ា ពិសី និងលោកមេធាវី លីវ សុវណ្ណា សមាជិកក្រុមប្រឹក្សាគណៈមេធាវី ព្រមទាំងលោកមេធាវី ពេជ្រ សូរិយា សមាជិកគណៈមេធាវីបានធ្វើដំណើរទៅកាន់សាលាដំបូងខេត្តកំពង់ស្ពឺ

និងខេត្តព្រះសីហនុ ដើម្បីប្រជុំពិភាក្សាការងារជាមួយលោកប្រធានតុលាការខេត្ត ព្រះរាជអាជ្ញា និងមេធាវីប្រចាំខេត្ត ពាក់ព័ន្ធនឹងបញ្ហាប្រឈមក្នុងការប្រកបវិជ្ជាជីវៈមេធាវី ការការពារក្តីជូនជនក្រីក្រ ព្រមទាំងកិច្ចសហការផ្សេងៗទៀត។




### ប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការបង្កើតគណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ាន

នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រតិភូគណៈមេធាវី រួមមានលោកស្រីមេធាវី សៅ កញ្ញា សមាជិកក្រុមប្រឹក្សាគណៈមេធាវី និងលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី ចូលរួមប្រជុំពិភាក្សាការងារជាមួយតុលាការកំពូល ពាក់ព័ន្ធនឹងសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ាន។



## ១.២ ទំនាក់ទំនងអន្តរជាតិ

### លោក មេធាវី សួន វិសាល បានដឹកនាំគណៈប្រតិភូ ចូលរួមសន្និសីទ LAWASIA លើកទី៣០ ឆ្នាំ ២០១៧ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន

ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំគណៈប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមសន្និសីទ LAWASIA លើកទី៣០ ឆ្នាំ២០១៧ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ដើម្បីប្រជុំពិភាក្សាពីបញ្ហានានា ដែលវិជ្ជាជីវៈមេធាវីនៅក្នុងតំបន់កំពុងប្រឈម ហើយសហការគ្នារកដំណោះស្រាយ និងធ្វើយ៉ាងណាលើកកម្ពស់គោលការណ៍នីតិរដ្ឋនៅក្នុងតំបន់។

នៅក្នុងវេទិកានៃសន្និសីទនេះផងដែរ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានថ្លែងផ្សព្វផ្សាយពីវិជ្ជាជីវៈមេធាវីនៅកម្ពុជា ក្នុងគោលដៅលើកកម្ពស់កិត្យានុភាពមេធាវីកម្ពុជាលើឆាកអន្តរជាតិ ហើយជាកិត្តិយស គណៈមេធាវីនៃព្រះរាជា-ណាចក្រកម្ពុជា ត្រូវបានចាត់តាំងឲ្យដឹកនាំសន្និសីទ LAWASIA សម្រាប់ឆ្នាំ ២០១៨ ដែលនឹងគ្រោងធ្វើឡើងនៅខេត្តសៀមរាប ។




**ជំនួបពិភាក្សាការងាររវាងគណៈមេធាវី ជាមួយគណៈកម្មាធិការ កាកបាទក្រហមអន្តរជាតិ (ICRC)**

នាព្រឹកថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងលោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី និងលោកមេធាវី ប៊ុន ណារីណា អគ្គលេខាធិការរងគណៈមេធាវី បានទទួលជួបពិភាក្សាការងារជាមួយ ICRC ពាក់ព័ន្ធនឹងការការពារក្តីជូនជនក្រីក្រ ព្រមទាំងកិច្ចសហការផ្សេងៗទៀតនាថ្ងៃអនាគត។



## លោកប្រធានគណៈមេធាវីចូលរួមកិច្ចប្រជុំក្រុមស្រាវជ្រាវច្បាប់ថ្នាក់តំបន់

កាលពីថ្ងៃទី៧ និងទី៨ ខែកញ្ញា ឆ្នាំ២០១៧ លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី និងលោកមេធាវី វ៉ា ពិសី សមាជិកក្រុមប្រឹក្សាគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានចូលរួម កិច្ចប្រជុំលើកទី៣ នៃក្រុមការងារស្រាវជ្រាវច្បាប់ថ្នាក់តំបន់នៃគម្រោងគាំពារកុមារ (ការប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារ ក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍) ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌ សហការជាមួយការិយាល័យអង្គការសហប្រជាជាតិស្តីពី គ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC)។ សិក្ខាសាលានេះ បានប្រព្រឹត្តទៅ នៅខេត្តសៀមរាប ក្រោមអធិបតីភាពរបស់ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

កិច្ចប្រជុំនេះមានអ្នកចូលរួមចំនួន៧០នាក់ ដែលជាតំណាងមកពីប្រទេសមហាអនុ-តំបន់ទន្លេមេគង្គ (កម្ពុជា ឡាវ វៀតណាម និងថៃ) តំណាងអង្គទូត អ្នកជំនាញការអន្តរជាតិ និងតំណាងក្រសួងជាច្រើនផ្សេងៗបានចូលរួមក្នុងកិច្ចប្រជុំនេះផងដែរ។







## លោកប្រធានគណៈមេធាវីចូលរួមសន្និសីទ និងកិច្ចពិភាក្សាច្បាប់ពាណិជ្ជកម្មនៅក្នុងតំបន់

កាលពីថ្ងៃទី ៤ និងទី៥ ខែសីហា ឆ្នាំ២០១៧ ក្នុងនាមជាប្រធានសមាគមន៍ច្បាប់អាស៊ាន នៃប្រទេសកម្ពុជា លោកមេធាវី សួន វិសាល និងជាប្រធានគណៈមេធាវី ត្រូវបានអញ្ជើញចូលរួមសន្និសីទ និងកិច្ចពិភាក្សាច្បាប់ពាណិជ្ជកម្មនៅក្នុងតំបន់។ អង្គសន្និសីទនេះបានប្រព្រឹត្តឡើង នៅទីក្រុង បាងកក ប្រទេសថៃ។




## ២. សិក្ខាសាលា

### សិក្ខាសាលាស្តីពី "កិច្ចបង់ពន្ធកាតព្វ"

កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ៨:០០ ព្រឹក នៅទីស្នាក់ការគណៈមេធាវី បានរៀបចំសិក្ខាសាលាស្តីពី "កាតព្វកិច្ចបង់ពន្ធ" ក្រោមអធិបតីភាព លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម អ៊ូ វ៉ាស៊ី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ តំណាងឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

វាគ្មិនធ្វើបទបង្ហាញ រួមមានឯកឧត្តម វ៉ាន់ ពុទ្ធិពល អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ លោកចៅក្រមតុលាការកំពូល គង់ តារាឆាត និងលោកមេធាវី អ៊ីវ ប៉ូលី សមាជិកក្រុមប្រឹក្សាគណៈមេធាវី។ សមាសភាពចូលរួមអង្គសិក្ខាសាលារួមមានសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី និងសមាជិក-សមាជិកាគណៈមេធាវី សរុបចំនួន២០៥រូប។ អង្គសិក្ខា-សាលាបានផ្លាស់ប្តូរយោបល់ពាក់ព័ន្ធនឹងប្រធានបទ និងបានលើកជាសំណួមពរមួយចំនួនជូនឯកឧត្តម វ៉ាន់ ពុទ្ធិពល អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិចារណាលើទិដ្ឋភាពច្បាប់ពាក់ព័ន្ធនានា។ សិក្ខាសាលានេះ បានបញ្ចប់នៅវេលា ម៉ោង ១២:៣០ ក្រោមបរិយាកាសស្និតស្នាល និងយោគយល់។

## ៣. សេចក្តីជូនដំណឹងអំពីបណ្ណាល័យច្បាប់នៃគណៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនមេធាវីជាសហភាតាទាំងអស់ និងសាធារណជនទូទៅថា គណៈមេធាវីបានរៀបចំបណ្ណាល័យអេឡិចត្រូនិចដែលចងក្រងអត្ថបទច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងអត្ថបទផ្សេងៗ ព្រមទាំងព្រឹត្តិបត្រមេធាវី ដើម្បីជាគុណប្រយោជន៍ដល់ការស្រាវជ្រាវអត្ថបទទាំងនោះ។ នេះជាការសម្រេចបាននូវសកម្មភាពទី២ ស្តីពីការផ្សព្វផ្សាយវិជ្ជាជីវៈមេធាវី នៃទិសដៅទី២ ស្តីពី ការពង្រឹង និងការពារវិជ្ជាជីវៈមេធាវីនៃផែនការសកម្មភាពរបស់គណៈមេធាវីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៨។

អស់លោក លោកស្រីជាសហភាតាទាំងអស់ ព្រមទាំងសាធារណជនអាចចូលទៅកាន់គេហទំព័រ http://www.bakc.org.kh/ រួចចុចលើមីនុយ "បណ្ណាល័យ" និង "ព្រឹត្តិបត្រ" ដើម្បីស្វែងរកឯកសារច្បាប់ និងអត្ថបទវិភាគនានា។ ចំពោះបណ្ណាល័យច្បាប់ អស់លោក លោកស្រីអាចចុចលើមីនុយនេះ រួចយកព្រួញចង្អុលទៅលើវិស័យនៃច្បាប់ណាមួយរួចបន្តចង្អុលទៅរកច្បាប់ អនុក្រឹត្យ ឬប្រកាស នៅក្នុងវិស័យនោះ។ អត្ថបទច្បាប់, អនុក្រឹត្យ, ឬប្រកាសនោះនឹងត្រូវបង្ហាញលើបញ្ជីមួយ។ ឧទាហរណ៍ បើសិនជាអស់លោក លោកស្រីចង់ស្វែងរកច្បាប់ទាក់ទងនឹងវិស័យពាណិជ្ជកម្ម និង ក្រុមហ៊ុន អស់លោកលោកស្រីអាចចង្អុលទៅតាមដំណាក់ការដែលបង្ហាញក្នុងរូបនៅខាងចុងសេចក្តីជូនដំណឹងនេះ រួចចុចកូនកណ្តុរឆ្វេងដើម្បីឲ្យបង្ហាញបញ្ជីច្បាប់ទាំងអស់ដែលបានអនុម័តចាប់តាំងពីឆ្នាំ១៩៩៣ រហូតដល់បច្ចុប្បន្នទាក់ទងនឹងវិស័យនោះ។

យើងបានចែកជាវិស័យធំៗចំនួន ២១ និងវិស័យផ្សេងៗ។ នៅពេលចង់ដឹងច្បាប់ណាមួយ យើងអាចស្មានថាច្បាប់នោះនៅក្នុងវិស័យណា រួចយើងចូលទៅក្នុងវិស័យនោះ។ បើសិនជាមិនឃើញនៅក្នុងវិស័យនោះ យើងអាចស្វែងរកក្នុងវិស័យមួយទៀតដែលស្រដៀងគ្នា។ បើសិនជាមានការលំបាកក្នុងការកំណត់វិស័យដែលត្រូវស្វែងរក អស់លោក លោកស្រីអាចស្វែងរកតាមពាក្យគន្លឹះដើម្បីស្វែងរកអត្ថបទណាមួយក្នុងគេហទំព័ររបស់គណៈមេធាវី។ ឧទាហរណ៍ លោកអ្នកអាចសាកដាក់ពាក្យអាស៊ាន នៅក្នុងប្រអប់ស្វែងរក នៅខាងស្តាំផ្នែកលើនៃគេហទំព័រ ដើម្បីស្វែងរកអត្ថបទច្បាប់ណាខ្លះដែលទាក់ទងនឹងអាស៊ាន។ ពេលសរសេរពាក្យគន្លឹះចប់ វានឹងបង្ហាញបញ្ជីអត្ថបទដែលមានពាក្យ "អាស៊ាន" រួចលោក លោកស្រីអាចចុចលើពាក្យ "ស្វែងរក" នោះបង្ហាញ "លទ្ធផលដែលរកឃើញសរុបចំនួន៖ " ដែលរាយបញ្ជីឈ្មោះអត្ថបទទាំងអស់ដែលមានពាក្យ "អាស៊ាន"។ បញ្ជីទាំងនោះរាយឈ្មោះអត្ថបទទៅតាមកាលប្បវត្តិលំដាប់ចុះក្រោម មានន័យថា ពីឆ្នាំក្រោយបង្អស់ទៅឆ្នាំមុនបង្អស់។

ខ្ញុំសង្ឃឹមថា បណ្ណាល័យច្បាប់នេះ នឹងបានបម្រើសេចក្តីត្រូវការក្នុងការស្រាវជ្រាវរបស់អស់លោក និងលោកស្រី និងរួមចំណែកក្នុងការកសាងចំណេះដឹងខាងច្បាប់ និងនីតិរដ្ឋនៅប្រទេសកម្ពុជា។ យើងនឹងប្រឹងប្រែងកសាងបណ្ណាល័យនេះឲ្យរឹតតែប្រសើរថែមទៀត។ ឆ្លៀតឱកាសនេះខ្ញុំសូមថ្លែងអំណរគុណដល់សហការីរបស់ខ្ញុំដែលបានអត់ធ្មត់ដើម្បីធ្វើឲ្យបណ្ណាល័យនេះកើតឡើង មានលោក **កុយ នាម លោក កែ ប៊ុនធឿន លោក វ៉ា សំរិត លោក ហួត សុវណ្ណកញ្ញា គុណ ថាវី លោកស្រី រី ផល្លា កញ្ញាគឹម រ័ត្នានិមល និងលោក វ៉ាត ចាន់ថា។**

ធ្វើនៅថ្ងៃទី ២៩ កញ្ញា ២០១៧

សួន វិសាល

ប្រធានគណៈមេធាវី

## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោក កែ ប៊ុនធឿន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី សេង សុខឃីម | អនុប្រធាននាយកដ្ឋាន |
| ៣. លោកស្រីមេធាវី លឹម ច័ន្ទលីដា | អនុប្រធាននាយកដ្ឋាន |
| ៣-លោកមេធាវី ម៉ៃ ច័ន្ទសត្យា | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី ວ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ |
| ៥-លោកមេធាវី ហួត សុវណ្ណា | បុគ្គលិកស្ម័គ្រចិត្ត |
| ៥-លោកស្រី រី សុផល្លា | បណ្ណារក្ស |
| ៦- កញ្ញា គឹម រ័ត្ននិមល | រដ្ឋបាលទូទៅ |
| ៧. លោក ວ៉ាត ចន្ថា | អ្នកហាត់ការ |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

សម្តេចពិបុលសេនាភក្តី សាយ ឈុំ

លោកមេធាវី ឆ បូណាវី

លោកមេធាវី សារិន ដេណូវ៉ា

DFDL

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

អាសយដ្ឋានអគារកាច់ជ្រុងផ្លូវលេខ ១១២៩ កែងផ្លូវ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ : (៨៨៥-២៣) ៦២២ ៧០៧០ អ៊ីម៉ែល : info@bakc.org.kh គេហទំព័រ : www.bakc.org.kh